ជីវិតរស់នៅប្រចាំថ្ងៃ

ភាគទី២

ប្រមូលរៀបរៀងដោយ

ខ្ញុំព្រះករុណា អាត្មាភាព

មនោរថ យ៉ុន តារា

ព.ស.២៥៥៨ គ.ស.២០១៥

ឈ្មោះសៀវភៅ: **ជីវិតរស់នៅប្រចាំថ្ងៃ ភាគទី ២**

រៀបរៀងដោយ: សាមណេរ **មនោរថ យ៉ុន តារា**

ផ្ទៀងផ្ទាត់ដោយ:

ភិក្ខុ **មធុរភាណកោ ខេង ឡុងហាន** (វិនយាចារ្យវត្តនិគ្រោធវ័ន)

ភិក្ខុ **ធរប្បញ្ញោ អ៊ុន ពិសី** (វិនយាចារ្យវត្តនិគ្រោធវ័ន)

សាមណេរ **មនោរថ យ៉ុន តារា** (និស្សិតសាកលវិទ្យាល័យបៀលប្រាយ)

ឧបាសក **ស្វាយ ហៃ** (អគ្គនាយក ACLEDA BANK ខណ្ឌឫស្សីកែវ)

យុវតី **មូ ចន្ទធតី** (និស្សិតសាកលវិទ្យាល័យបញ្ញាសាស្ត្រ)

យុវតី **ខន សុខនាង** (និស្សិតសាកលវិទ្យាល័យ ROOL)

ជំនួយការបោះពុម្ពដោយ:

ឧបាសក **ស្វាយ ហៃ**	ឧបាសិកា **សន សារ៉ុម**
ឧបាសិកា **រិន ថារ៉ាត់**	ឧបាសិកា **ថៃខ ស្រីណោត**
ឧបាសិកា **ឈុន ឆារ៉ា**	យុវជន **សំរិត បូរវិឬទ្ធស្សាល**

ស្ថានទីធ្វើ: **វត្តនិគ្រោធវ័ន** (**គល់ទនឹង**) ភូមិកោះក្របី សង្កាត់ព្រែកថ្មី ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ

បោះពុម្ពលើកទី១ ៥០០ ក្បាល

កាលបរិច្ឆេទ: ព.ស.២៥៥៨ គ.ស.២០១៥

ធម្មទានដោយ: ពុទ្ធបរិស័ទទូទៅ

រក្សាសិទ្ធិដោយ: រោងពុម្ព **ម៉ៅ ផុន** (**ពុយ**)

មាតិកា

ឈ្មោះមាតិកា ទំព័រ

អារម្ភកថា I

ជីវិតរស់នៅប្រចាំថ្ងៃ ១

ការពោលរៀបរាប់ អំពីជីវិត ១

១.បញ្ហាផ្លូវចិត្ត ជំងឺផ្លូវចិត្ត និងការថែទាំ ១៩

ផ្នែកទី១

ការតានតឹងចិត្ត

តើការតានតឹងចិត្តគឺជាអ្វី ? ២០

បុព្វហេតុនៃការតានតឹងចិត្ត ២១

អាការៈនៅពេលមានការតានតឹងចិត្ត ២២

មធ្យោបាយបំបាត់ការតានតឹងចិត្ត ២៣

ផ្នែកទី២

ការធ្លាក់ទឹកចិត្ត និង ជំងឺធ្លាក់ទឹកចិត្ត ២៥

បុព្វហេតុនៃការធ្លាក់ទឹកចិត្តនិងជំងឺធ្លាក់ទឹកចិត្ត ២៦

អាការៈនៃការធ្លាក់ទឹកចិត្ត និង ជំងឺធ្លាក់ទឹកចិត្ត ២៨

មធ្យោបាយដោះស្រាយចំពោះអ្នកធ្លាក់ទឹកចិត្ត ២៩

១. ផ្តល់ការប្រឹក្សា ៣០

២. ការព្យាបាល ៣០

៣. គាំទ្រពីគ្រួសារ និង សហគមន៍ ៣០

ផ្នែកទី ៣

ផលប៉ះពាល់នៃគ្រឿងញៀនចំពោះផ្លូវចិត្ត និងផ្លូវកាយ

តើគ្រឿងញៀនជាអ្វី ? ៣២
បុព្វហេតុដែលនាំឲ្យយុវវ័យប្រឡូកក្នុងគ្រឿងញៀន.................. ៣៣
ផលប៉ះពាល់នៃគ្រឿងញៀនចំពោះផ្លូវចិត្ត.............................. ៣៤
ផលប៉ះពាល់នៃគ្រឿងញៀនចំពោះផ្លូវកាយ ៣៥
ផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀតរបស់គ្រឿងញៀន............... ៣៥
យុវជនគួរជៀសវាងពីថ្នាំញៀន ៣៦
២. ចង់ឲ្យជីវិតមានសេចក្ដីសុខ.. ៣៧
៣. ការបញ្ជ្រាបកម្មទស្សនៈទៅក្នុងសង្គម ៣៩
៤. សុខរបស់គ្រហស្ថ ៤២
សុខរបស់គ្រហស្ថមាន ៤យ៉ាងគឺ ៤២
ធម្មសម្បត្តិ ៣ ប្រការគឺ ៤៥
៥. សីលធម៌គ្រួសារ... ៤៨
គុណរបស់ទាន... ៦៣

សិក្សាព្រះសូត្រ

ពោធិវគ្គ ទី១ .... ៦៨
ពុទ្ធោ នាគលំព្រះពោធិព្រឹក្ស ៩៨

នាទីកំណាព្យ

ការសិក្សានិងស្នេហា ១០២
សុខពិតប្រាកដ ១០៣
ពាក្យរំលឹកគុណគ្រូ... ១០៤
ព្រះព្រហ្មរបស់កូន ១០៨
ឈ្មោះសប្បុរសជន ១០៩

អារម្ភកថា

សៀវភៅ **ជីវិតរស់នៅប្រចាំថ្ងៃ ភាគទី១** បានបោះពុម្ភចែកចាយកន្លងទៅពីរឆ្នាំមុន ដោយសទ្ធាជ្រះថ្លារបស់ពុទ្ធបរិស័ទច្រើននាក់ ។ ដោយការរៀបរៀងសៀវភៅនោះ មានការខុសផ្លែកពីគ្នាដូចជាអ្នកអានតាំងពីភាគទី១មកនោះ ប៉ុន្តែសៀវភៅដែលខ្ញុំប្រមូលរៀបរៀងភាគទី២ពន្យល់ពីជីវតរបស់យើងផ្ទាល់ ក៏ដូចជាការពន្យល់មិនឲ្យយុវជនបះពាល់នឹងថ្នាំញៀន ហើយក៏បានស្រាវជ្រាវទាក់ទងនឹងថ្នាំញៀនមកដាក់ក្នុងសៀវភៅនេះផងដែរ ដោយងាយស្រួលឲ្យយើងស្គាល់ ហើយក៏ជៀសវាងឲ្យស្វាយអំពីថ្នាំទាំងនោះ ។ ម្យ៉ាងទៀតខ្ញុំបានលើកព្រះសូត្រមកដាក់ក្នុងសៀវភៅនេះផងដែរ ។

ខ្ញុំព្រះករុណា អាត្មាភាពសូមត្រេកអរនូវកងមហាកុសលចេតនាព្រះករុណាគុណម្ចាស់គ្រប់ព្រះអង្គ ញាតិញោមពុទ្ធបរិស័ទគ្រប់គ្នាដែលបានអានក៏ដូចជាការបដិបត្តិផង ។ ហើយខ្ញុំក៏សូមអនុមោទនានូវកុសលរបស់អ្នកដែលបានបរិច្ចាគប្រាក់បោះពុម្ភសៀវភៅភាគទី២នេះ និង កុសលក្នុងការចាត់ចែងជួយគ្រប់យ៉ាង ដើម្បីឲ្យសម្រេចជាសន្លាពរមកនេះ ។

វត្តបទុមវតី កុដិលេខ៣៦ ថ្ងៃព្រ.ហ ៨រោច ខែផល្គុន ឆស័ក ព.ស.២៥៥៨

សាមណេរ មនោរថ យ៉ូន តារា

ជីវិតរស់នៅប្រចាំថ្ងៃ

ខ្ញុំព្រះករុណាសូមពោលអំពីជីវិតជាមុនសិន ព្រោះថានៅក្នុងសៀវភៅ ជីវិតរស់នៅប្រចាំថ្ងៃភាគ១ មិនបានពោលអំពីពាក្យថាជីវិតនោះទេ ខ្ញុំសូមពោលដូចតទៅ ៖

ការពោលរៀបរាប់ អំពីជីវិត

ពាក្យថា **ជីវិត** នេះបើគេពុំបានគិតឬប្រើគំនិត ដើម្បីស្វែងយល់ឲ្យដល់ជម្រៅអំពីអត្ថន័យនៃពាក្យនេះទេ គេហាក់ដូចជាបានយល់ស្គាល់ ដឹងពាក្យនេះប្រាកដច្បាស់ណាស់ទៅហើយ គឺគេគ្រាន់តែឲ្យន័យទៅលើពាក្យថា "**ជីវិត**" នេះគឺត្រឹមតែការរស់នៅប៉ុណ្ណោះ ឃើញជាការស្រេច ដោយមិនចាំបាច់ទៅមានចម្ងល់និងធ្វើជាការស្រាវជ្រាវឲ្យបានដឹងយល់ស្គាល់អ្វីទៀតនោះទេ ។

ប៉ុន្តែបើគេបានសិក្សាស្វែងយល់អំពីពាក្យថា **ជីវិត** នេះទៅតាមអត្ថន័យនិងជម្រៅ គេរឹងរឹតតែមានចម្ងល់ច្រើនណាស់ទៅទៀតអំពីពាក្យថា **ជីវិត** ព្រមទាំងបញ្ហាដែលកើតមានជុំវិញជីវិតនេះជាអនេកប្បការទាំងផ្នែក **ទស្សនៈវិជ្ជា** និង **បរមត្ថវិជ្ជា** ។

ទស្សនៈវិជ្ជា បានដល់ ការសិក្សាស្វែងយល់ទៅតាមការឃើញ ឬការស្រាវជ្រាវខាងផ្នែកសម្ភារៈនិយមដោយផ្អែកទៅលើចំណេះដឹងនិងក្បួនវិជ្ជាសាស្ត្រផ្សេងៗ ដូចជាការសិក្សាឲ្យបានចេះដឹងយល់ស្គាល់ អំពីលក្ខណៈនិងការប្រែប្រួលផ្លាស់ប្តូរនៃជីវិតនេះទៅតាមកាលវេលា ដូចជាការរស់នៅ ឬការប្រព្រឹត្តទៅព្រមនៃរូបរាងកាយរបស់សត្វទាំងឡាយ ដោយមានការដកដង្ហើមចេញចូល ចេះស្រេកឃ្លាន ពោលពាក្យនិយាយស្តី សើចយំស្រឡាញ់ ស្អប់ ចេះប្រកបកិច្ចការផ្សេងៗទៅតាមសញ្ញាតិញ្ញាណរបស់ខ្លួន ឬគេអាចសំគាល់បានដោយចលនាឥរិយាបថទាំងបួនមានការដេក ដើរ ឈរ អង្គុយ ដែលផ្ទុយអំពីសេចក្តីស្លាប់ ហ្នឹងហើយហៅថា **ជីវិត** ឬថា ជីវិតមនុស្ស ជីវិតសត្វមានចិត្តវិញ្ញាណ មានឥរិយាបថប្រព្រឹត្តទៅនោះឯង ។

តាមទស្សនៈ (ការយល់ឃើញ) របស់អ្នកស្រាវជ្រាវខ្លះគេតែងសម្គាល់ថា <u>រុក្ខជាតិ តិណជាតិ វល្លិជាតិ ផលជាតិ</u>[១]ទាំងនោះសុទ្ធសឹងតែមានវិញ្ញាណ មានជីវិតទៅតាមប្រភេទតូចធំ តិចច្រើនដោយគេបានសម្គាល់ទៅតាមលក្ខណៈចលនា ការផ្លាស់ប្តូរទៅតាមកាលវេលានៃរុក្ខាលតាជាតិនោះៗ ។ ដូចជាចេះបឺតស្រូបយកទឹកជីវជាតិ ធាតុអាកាសកម្តៅថ្ងៃ មក

[១] រុក្ខជាតិ គឺ ដើមឈើ, តិណជាតិ គឺ ដើមស្មៅ, វល្លិជាតិ គឺ វល្លិ, ផលជាតិ គឺ ផ្លែ,

ចិញ្ចឹមបណ្តុះដើមមែកធាង ស្លឹកត្រួយ ផ្លែផ្កា ឲ្យលូតលាស់ដុះដាល បែកមែកសាខាត្រសុំត្រសាយ ធំខ្ពស់ទៅបាន ។

រុក្ខជាតិគ្រប់ជំពូក ហាក់បីដូចជាមានជីវិតមានវិញ្ញាណទទួលដឹងនូវកម្តៅធាតុអាកាសនៅពេលណាមានកម្តៅខ្លាំង ឬធាតុអាកាសក្តៅខុសប្រក្រតីក៏សម្រេបស្លឹកស្វិតស្រពោន វេលាមានទឹកសន្សើម ឬ មានភ្លៀងបង្អុលចុះមក ក៏ខំលូតលាស់បញ្ចេញសម្រស់ព្រមទាំងស្លឹក ផ្លែ ផ្កាស្រស់បំព្រងគួរឲ្យគយគន់ពិតពិលរមិលមើល ។

មានរុក្ខាលតាជាតិ[២]ប្រភេទខ្លះទៀត ដូចជាបន្លាប្រខ្លប[៣]ជាដើម ជារុក្ខជាតិមានដើមរៀវតូចឆ្មារ ស្រដៀងនឹងវល្លិមានបន្លាខ្លីទន់ មានពណ៌ស្វាយច្រើនដុះជាគុម្ពនៅលើដីទួល ឬតាមភ្លឺស្រែ រុក្ខជាតិប្រភេទនេះ នៅពេលគេដើរទៅប៉ះ ឬពាល់ត្រូវក៏មានចលនាស្លឹក ក្តោបរមូរសម្រេបចូលគ្នាភ្លាម ហាក់បីដូចជាមានជីវិតវិញ្ញាណទទួល ដឹងសម្ពស្សដូច្នោះដែរ ។

មានរុក្ខជាតិច្រើនប្រភេទទៀត នៅពេលព្រលប់មានស្លឹកក្តោបសម្រេបចូលគ្នា ហាក់បីដូចជាត្រូវការសម្រាកសម្រាន្តក្នុងរាត្រីកាលដែរ ។ ឯ

---

[២] វល្លិ៍គ្រប់ប្រភេទ

[៣] តាមគ្រាមភាសា ខ្លះហៅថា បន្លាប្រក្រាប, ប្រខ្លប ឬមខ្លប

រុក្ខាលតាជាតិខ្លះទៀតខំលូតលាស់បោះទងបញ្ចេញត្រួយថ្កក់តោងវារឡើង ទ្រើង ។

តាមទស្សនីយភាពដូចពោលរៀបរាប់មកនេះ ទើបធ្វើឲ្យលោកអ្នកស្រាវជ្រាវខ្លះ បានពោលអះអាងសម្តែងបញ្ជាក់អំពី ជីវិតវិញ្ញាណនិងការវិវដ្តន៍នៃជីវិតវិញ្ញាណទៅតាមកាលវេលា ។

ពួកគេបានពោលអះអាងថា រុក្ខាលតាជាតិគ្រប់ប្រភេទសុទ្ធសឹងតែមានជីវិតវិញ្ញាណ ប៉ុន្តែវិញ្ញាណ គឺការដឹងនោះជាវិញ្ញាណតូចល្អិត កើតមានតិចតួចស្តួចស្តើង ។ បានជាគេពោលដូច្នេះ ព្រោះតាមការសង្កេតឃើញមានសត្វដង្កូវប្រភេទខ្លះកើតចេញពីសំបកឈើ ឬស្លឹកឈើ ។ សត្វអន្ទង់ក្លាយចេញពីដើមត្រស់ពាក់កណ្តាលមានក្បាលខ្លួនជាសត្វអន្ទង់ ពាក់កណ្តាលមានសភាពជាដើមត្រស់ ។ សត្វដង្កូវទឹកកើតចេញពីទឹកហើយដុះស្លាបប្រែក្លាយទៅជាមូស ។ សត្វដង្កូវដុះស្លាបប្រែរូបទៅជាមេអំបៅ ។ មិនតែប៉ុណ្ណោះគេថែមទាំងហ៊ាននិយាយថា កាលពីដើមសត្វស្វាក្លាយមកជាមនុស្ស ឬថាមនុស្សបានប្រែរូបរាងកាយក្លាយមកអំពីសត្វស្វា ។

ការពោលដូច្នេះ គឺចង់បញ្ជាក់អំពីលក្ខណៈនៃការឃើញដឹងយល់ស្គាល់អំពីចលនា ការប្រែប្រួល ផ្លាស់ប្តូរនៃរូបធាតុនិងវិញ្ញាណធាតុ តាំងតែពីតូចល្អិតដែលវិវដ្តន៍ទៅតាមកាលវេលាមានតំណតភ្ជាប់គ្នាមិនដាច់ អំពី

សភាពមួយទៅកាន់សភាពមួយ រហូតឲ្យគេមានសេចក្ដីយល់ឃើញថា រុក្ខាលតាជាតិប្រភេទទាំងអស់សុទ្ធសឹងតែមានវិញ្ញាណ ទើបគេប្រើពាក្យថា ដើមឈើងាប់ដើមឈើរស់ដូច្នេះជាដើម ។

ការពោលរៀបរាប់អំពីអត្ថន័យខ្លះនៃជីវិតប៉ុណ្ណោះនេះ គ្រាន់តែបញ្ជាក់ទៅតាមផ្នែកម្យ៉ាងនៃទស្សនវិជ្ជា គឺការស្រាវជ្រាវ និងការពោលស្ដីនិយាយទៅតាមលោកវោហារ ជាសាមញ្ញភាសា ឬជាគ្រាមភាសា ហាក់បីដូចជានិយមន័យត្រឹមតែប៉ុណ្ណោះឃើញថា ជាការគ្រប់គ្រាន់ណាស់ទៅហើយ ។ ដូច្នេះសូមលោកអ្នកអានទាំងឡាយងាកបែរមកសិក្សាពាក្យថា ជីវិត នេះតាមលំអាននៃព្រះពុទ្ធសាសនាម្ដងវិញ ដែលចាត់ថាជាផ្នែកបរមត្ថ វិជ្ជាដែលបរមនេះបានដល់ អត្ថដ៏ឧត្ដម ន័យដ៏ក្រៃលែងសេចក្ដីពិត។

បរមត្ថវិជ្ជា ឬ បរមត្ថធម៌ តាមព្រះពុទ្ធដីការបស់ព្រះអង្គទ្រង់សម្ដែងក្នុង **គម្ពីរព្រះអភិធម្ម** ពាក្យថា **ជីវិត** នេះគឺជា **ធម៌បរមត្ថ** មានន័យសុខុមលម្អិត ប្រណិត ពិតក្រៃលែងល្អិតល្អន់ក្បោះក្បាយ ទូលំទូលាយ ជ្រាលជ្រៅជាទីបំផុត ។

ក្នុង **អភិធម្មសង្គណី** ពាក្យថា **ជីវិត** នេះសំដៅយកតែជីវិតមនុស្សសត្វដែលមានចិត្តវិញ្ញាណ ជាសហជាតប្បច្ច័យពុំបានសម្ដែងរាប់បញ្ចូលដល់រុក្ខាលតាជាតិអ្វីនោះទេ ។

ព្រោះពាក្យថា **ជីវិត** នេះជាភាសាបាលី ឬសំស្រ្កឹត ប្រែជាភាសាខ្មែរ បានដល់កិរិយារស់នៅ ដូចបទវិគ្គហថា **ជីវិយតេតិ=ជីវិតំ** ប្រែថា ធម្មជាតិជាគ្រឿងរស់នៅនៃសត្វ ធម្មជាតិជាទីប្រព្រឹត្តទៅនៃសម្បយុត្តធម្មហៅថា **ជីវិត**។

ក្នុងអភិធម្មបិដក គម្ពីរវិភង្គ បឋមភាគ ៨០ ទំព័រ២៤៨ លេខឃ្នាប២៣៨ ពោលថា

តត្ថ កតមំ ជីវិតិន្ទ្រិយំ ។ ទុវិធេន ជីវិតិន្ទ្រិយំ អត្ថិ រូបំ ជីវិតិន្ទ្រិយំ អត្ថិ អរូបំ ជីវិតិន្ទ្រិយំ ។

ជីវិតិន្ទ្រិយ តើដូចម្ដេច ។ ជីវិតិន្ទ្រិយមានប្រការពីរ គឺ រូបជីវិតិន្ទ្រិយ១ អរូបជីវិតិន្ទ្រិយ១ ។

តត្ថ កតមំ រូបំ ជីវិតិន្ទ្រិយំ ។ យោ តេសំ រូបំនំ ធម្មានំ អាយុ ឋិតិ យបនា យាបនា ឥរិយនា វត្តនា បាលនា ជីវិតំ ជីវិតិន្ទ្រិយំ ឥទំ វុច្ចតិ រូបំ ជីវិ-តិន្ទ្រិយំ ។

បណ្ដាជីវិតិន្ទ្រិយទាំងនោះ រូបជីវិតិន្ទ្រិយ តើដូចម្ដេច ។ អាយុ ការឋិតនៅ ការតាំងនៅ ការញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តិទៅ ការរក្សា ការរស់នៅ ធម្មជាតិជាធំក្នុងការរស់នៅណា នៃធម៌ដែលមានរូបទាំងនោះ នេះហៅថា រូបជីវិតិន្ទ្រិយ ។

តត្ថ កតមំ អរូបំ ជីវិតិន្ទ្រិយំ ។ យោ តេសំ អរូបំនំ ធម្មានំ អាយុ ឋិតិ យបនា យាបនា ឥរិយនា វត្តនា បាលនា ជីវិតំ ជីវិតិន្ទ្រិយំ ឥទំ វុច្ចតិ អរូបំ ជីវិតិន្ទ្រិយំ ។

បណ្ដាជីវិតិន្ទ្រិយទាំងនោះ អរូបជីវិតិន្ទ្រិយ តើដូចម្ដេច ។ អាយុ ការឋិតនៅ ការតាំងនៅ ការញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ការរំកិលទៅ ការប្រព្រឹត្តិទៅ ការរក្សា ការរស់នៅ ធម្មជាតិជាធំក្នុងការរស់នៅណា នៃធម៌ដែលមិនមានរូបទាំងនោះ នេះហៅថា អរូបជីវិតិន្ទ្រិយ ។

ដូច្នេះពាក្យថា **ជីវិត** ក្នុង **គម្ពីរវិភង្គ** ចាត់ថាជារូបធម៌ផង ចាត់ថាជានាមធម៌ផង ។ ក្នុងចំណែកនៃរូបធម៌មានទាំងអស់២៨ ជីវិតចាត់ថាជាចំណែកនៃរូបមួយដែរ ព្រោះធម្មជាតិជាធំក្នុងការអនុបាលរក្សារូបដទៃ ឲ្យមានការតាំងនៅ និងប្រព្រឹត្តទៅបាន ។

ក្នុងចេតសិក ៥២ដួង **ជីវិត**ចាត់ថាជា នាមរូប ត្រង់ចំណុចទី៦ ក្នុងសព្វចិត្តសាធារណចេតសិក ជីវិតជាធំ ក្នុងការរក្សាសម្បយុត្តធម៌(ប្រកបជាមួយធម៌) ឲ្យប្រព្រឹត្តទៅក្នុងឱកាសដែលកើតឡើងតម្រង់នៅរហូតដល់ការរលត់ទៅវិញ ។

តាមសេចក្ដីដូចបានរៀបរាប់មក បញ្ជាក់ឲ្យឃើញថា ជីវិតពុំមែនកើតឡើងដោយឯកឯងនោះទេ ជីវិតជាសហជាតប្បច្ច័យ កើតឡើងបាន

ដោយអាស្រ័យហេតុ និងបច្ច័យ ជីវិតជាអតីតក្តី ជាអនាគតក្តី ជាបច្ចុប្បន្នក្តី ដែលកើតឡើងបានដោយអាស្រ័យហេតុមាន **អវិជ្ជា តណ្ហា ឧបាទាន កម្ម** ជាដើម ។

ជីវិតកើតឡើងដោយហេតុបច្ច័យណា រមែងរលត់ទៅវិញដោយហេតុបច្ច័យនោះ ជីវិតអតីតកើតឡើងហើយ ក៏រមែងរលត់ទៅវិញក៏ជាជីវិតអតីតដែរ មិនមែនជាជីវិតបច្ចុប្បន្ន ជីវិតបច្ចុប្បន្នកើតឡើងហើយ ក៏រមែងរលត់ទៅវិញក៏ជាជីវិតបច្ចុប្បន្នដែរ មិនមែនជាជីវិតអនាគត ជីវិតអនាគតដែលនឹងកើតឡើងហើយ ក៏រមែងរលត់ទៅវិញក៏ជាជីវិតអនាគត មិនមែនជាជីវិតបច្ចុប្បន្ន ។

ជីវិតមិនទៀងទាត់ ផ្លាស់ប្តូរគ្នាទៅតាមហេតុបច្ច័យ ពេលខ្លះជីវិតជាហេតុ ពេលខ្លះជីវិតជាផល ជីវិតជារូប ជីវិតជានាម ពោលទៅតាមបញ្ចក្ខន្ធ (ខន្ធ ៥) គឺមាន រូបក្ខន្ធ១ វេទនាខន្ធ១ សញ្ញាខន្ធ១ សង្ខារក្ខន្ធ១ វិញ្ញាណក្ខន្ធ១ ចាត់ជាចង្កោម ជាក្រុម គំនរនៃរូបធម៌ និងនាមធម៌ ។ ក្នុង**គម្ពីរព្រះអភិធម្ម** រូបទាំង២៨(មានមហាភូតរូប៤ជាដើម) ចាត់ចូលក្នុងរូបក្ខន្ធ ចិត្ត៨៩ដួង ចាត់ចូលក្នុងវិញ្ញាណក្ខន្ធ ចេតសិក៥២ដួង ចាត់ចូលក្នុងសញ្ញាខន្ធ វេទនាចាត់ចូលក្នុងវេទនាខន្ធ នៅសល់ចេតសិក៥០ដួងទៀត ចាត់ចូលសង្ខារក្ខន្ធ ។

ដូច្នេះពាក្យថា **ជីវិតជាបរមត្ថធម៌** ជាសភាវពិត ប្រព្រឹត្តទៅរួមដោយរូបធម៌ និងនាមធម៌ មានមហាភូតរូប៤ រួមដោយចិត្តវិញ្ញាណ ខន្ធ ធាតុ អាយតន ឥន្ទ្រិយ ។ ជាសង្ខតបច្ច័យមានការកើតឡើង និងរលត់ទៅវិញយ៉ាងឆាប់រហ័សជាទីបំផុត ។

ក្នុងរូបរាងកាយនៃសព្វសត្វទាំងឡាយ ដែលចាត់ថាមានជីវិត គឺសំដៅត្រង់កំពុងមានចលនាប្រព្រឹត្តទៅដូចជា ដេក ដើរ ឈរ អង្គុយ និយាយស្តី សើចយំ ស្រេចឃ្លាន ប្រកបការងារតាមនាទីខ្លួនទទួលដឹងអារម្មណ៍ដែលជាសុខ ជាទុក្ខ សោមនស្ស ទោមនស្ស ជាឧបេក្ខា នេះឯងហើយចាត់ថាមានជីវិត គឺការរស់នៅ ទើបតម្រូវឲ្យមានពាក្យសម្តីជាច្រើនសន្ធឹកសន្ធាប់រាប់មិនអស់ សម្រាប់ប្រើជាមួយជីវិតនេះដូចជា **អត្ត** ជាភាសាបាលី **អាត្មា ឬអាត្ម័ន** ជាភាសាសំស្ក្រឹត ប្រែថា "ខ្លួន" សំដៅដល់ជីវិត, **បាណ ឬប្រាណ** បានដល់ការរស់នៅ ឬការប្រព្រឹត្តទៅនៃជីវិត ។

នៅមានពាក្យសំដីជាច្រើនទៀតជាលោកវោហារ ការសន្មត ឬសម្មតិបញ្ញត្តិ ជាអវិជ្ជមានបញ្ញត្តិ គឺគ្រាន់តែជាការកំណត់កត់ចំណាំចាំសម្គាល់ក្នុងការនិយាយពោលស្តី សម្រាប់ជីវិតប្រចាំថ្ងៃដូចជា ភូមិឋានប្រទេសជាតិ ភាសា អក្ខរៈ ព្យញ្ជនៈ ។ ឈ្មោះប្រទេស ជាតិ មនុស្ស សត្វបុគ្គល របស់សម្ភារៈនិមួយៗ ចាត់ថាជាបញ្ញត្តិ មិនជាសភាវធម៌ពិត គ្រាន់

តែប្រឌិតកំណត់ឲ្យបានជាឈ្មោះ ជាពាក្យសម្ដី កំណត់ចំណាំក្នុងការនិយាយពោលស្ដី ប្រាស្រ័យហៅ ទំនាក់ទំនងរវាងគ្នាទៅវិញទៅមក តាមសង្គមគ្រួសារ ភាសាជាតិ ប្រទេសតែរៀងៗខ្លួន ។

បញ្ញត្តិទាំងឡាយ ទោះជាវិជ្ជមានបញ្ញត្តិក្ដី អវិជ្ជមានបញ្ញត្តិក្ដី ដែលកើតមានឡើង ក៏ព្រោះតែមានមនុស្សសត្វកើតឡើងមានជីវិតប្រព្រឹត្តទៅក្នុងលោក បើពុំនោះសោតក៏គ្មានបញ្ញត្តិសម្រាប់ពោលស្ដីឲ្យយល់ស្គាល់អ្វីៗក្នុងលោកនេះដែរ ។

សត្វលោកស្រឡាញ់ជីវិតខ្លួន

ពាក្យថា **សត្វលោក** ចែកចេញជា ២ស័ព្ទគឺ ៖ សត្វជា ស័ព្ទមួយ១ លោកជាស័ព្ទ១ ។

សត្ត ឬសត្វ (ជាភាសាបាលី ឬសំស្ក្រឹត) ប្រែជាភាសាខ្មែរ បានដល់បុគ្គលអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ ក្នុងបំណង ក្នុងជីវិតខ្លួនប្រាណ ។ បើយោងទៅតាមន័យសេចក្ដី ពាក្យថា **សត្វ** សំដៅដល់សត្វមានជីវិត ៖ ក្សត្រិយ៍ក្ដី ព្រាហ្មណ៍ក្ដី វេស្សក្ដី សុទ្ទៈក្ដី គ្រហស្ថក្ដី បព្វជិតក្ដី ទេវតាក្ដី មនុស្សក្ដី តិរច្ឆានក្ដី រួមហៅថា **សត្វ** ។

លោក (ជាភាសាបាលី ឬសំស្ក្រឹត) ប្រែជាភាសាខ្មែរ បានដល់សភាវធម៌ដែលកើតឡើងហើយ តែងវិនាសទៅវិញជារឿយៗឬដែលបាត់ៗឃើញៗ គឺកើតមានហើយវិនាសបាត់ទៅ ហើយក៏កើតឡើងតាមកាលសម័យ ។ បើយោងទៅតាមន័យសេចក្តី ពាក្យថា លោក សំដៅដល់អបាយលោក មនុស្សលោក ទេវលោក ខន្ធលោក ធាតុលោក អាយតនលោក ។

លោកបី ឬ ត្រៃភព ឬ ត្រៃភូមិ សំដៅដល់ កាមភព រូបភព និងអរូភព ដែលមានបញ្ជាក់ន័យលម្អិតអំពីលោក មនុស្សលោក និងទេវលោកដូចខាងក្រោម ៖

លោក ជាទីអាស្រ័យនៅ នៃសត្វតិរច្ឆានក្តី អសុរកាយក្តី ប្រេតក្តី នរកក្តី ចាត់ថាជាអបាយភូមិ ៤ នៃកាមភព ព្រោះជាភូមិឋាននៃសេចក្តីវិនាស សូន្យចាកសេចក្តីចម្រើន មិនអាចសាងបុណ្យ កុសលបានរកសេចក្តីសុខគ្មានមានតែទុក្ខទារុណកម្មដែលកើតពីអកុសលវិបាក ជាបច្ច័យ ។

មនុស្សលោក លោកជា ទីអាស្រ័យនៃមនុស្ស ដែលចែកចេញទៅជាប្រទេស ជាតិ ភូមិឋាន ផ្សេងៗដោយឡែកពីគ្នា (ដែលចាត់ចូលក្នុងភូមិ១នៃកាមភព) ។

ទេវលោក លោកជាទីអាស្រ័យនៅនៃពពួកទេវតា មានកាមភូមិ១១ (ភូមិ១១ នៃកាមភព) អរូបភូមិ១៦ (ឬរូបភព១៦) អរូបភូមិ៤ (ឬអរូបភព៤) ដែលបានពោលក្នុងសៀវភៅភាគ១រួចហើយ ។

ទាំងនេះអាស្រ័យកម្ម ជាកុសល ជាអកុសល ដែលសត្វលោកបានធ្វើ ហើយកម្មនោះបានវិចិត្រតាក់តែងមក ដូចជាសត្វកើតក្នុងអបាយលោក ឬយមលោក កើតបានដោយអកុសលវិបាក ជាផលនៃអកុសលចិត្តទាំង ១២ដួង មានលោភមូលចិត្ត៨ដួង ទោសមូលចិត្ត២ដួង មោហមូលចិត្ត២ដួង ។ អកុសលមូលចិត្តទាំង១២ដួងនោះ មានអកុសលចេតសិកកើតរួមជាមួយគ្នា ជួយជាកម្លាំងឲ្យប្រព្រឹត្តអកុសលកម្មបថទាំង១០ប្រការ (មានកាយកម្ម ៣ វចីកម្ម ៤ មនោកម្ម ៣) ប្រកបដោយកម្លាំងចិត្តខ្លាំងក្លា ត្រេកអរសប្បាយរីករាយខ្លះ មានកម្លាំងចិត្តខ្សោយស្មើៗ ធ្វើនូវបាបកម្មដោយចេតនាខ្លួនឯងខ្លះ ដោយតាមគេបបួលណែនាំខ្លះ ដូច្នេះទើបកើតក្នុងភពឋាន មានខ្លួនប្រាណខុសដោយឡែកពីគ្នា ទាំងបានទទួលទារុណកម្មផ្សេងៗគ្នាដូច្នោះដែរ ។

លោកជាទីអាស្រ័យនៅនៃមនុស្សក្តី ទេវតាក្តី ឬថាកំណើតមនុស្ស កំណើតទេវតា កើតបានដោយកាមាវចរកុសលចិត្ត៨ដួង ដែល

មានកុសលចេតសិកកើតជាមួយ បំពេញនូវកុសលកម្មបថ១០(មានកាយកម្ម ៣ វចីកម្ម ៤ មនោកម្ម៣) ទៅតាមកម្លាំងនិងលចេតនាចិត្តរៀងៗខ្លួន ។

ពួកព្រហ្មមានរូប កើតបានដោយរូបាវចរកុសលឈាន៥ ព្រហ្មឥតរូប កើតបានដោយអរូបាវចរកុសលឈាន៤ ។

សត្វក្នុងអបាយលោកក្តី មនុស្សលោកក្តី ទេវលោកក្តី ព្រហ្មលោកក្តី រួមមកហៅថា **សត្វលោក** ព្រោះជាអ្នកជាប់ជំពាក់ក្នុងអារម្មណ៍ស្មើដូចគ្នា ។ បានដល់ចិត្តថ្លក់ជាប់ ប្រកាន់មាំប្រកាន់ខ្ជាប់ខ្ជួនទៅលើអារម្មណ៍មាន រូប សម្លេង ក្លិន រស ផោដ្ឋព្វៈ ជាប់ជំពាក់ត្រេតត្រអាល ចំពោះភព ភូមិឋាន ទ្រព្យសម្បត្តិ យសសក្តិ អំណាចតំណែង នាទីជីវិតរបស់ខ្លួន ។ សូម្បីតែពពួកសត្វ ដែលកើតក្នុងអបាយភូមិ ក៏គង់មានការប្រកាន់សោកស្តាយ ចំពោះជីវិតរបស់ខ្លួន ដោយមានការខកខូចតូចចិត្ត ត្បិតជាអំពើ អកុសលដែលខ្លួនបានធ្វើហើយនាំឲ្យសោយទុក្ខវេទនាដូច្នោះ ។

សត្វលោក ស្រឡាញ់ ពេញចិត្ត ជាប់ចិត្តតែនឹងជីវិតខ្លួន ដូច្នេះទើបព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះអង្គទ្រង់ត្រាស់យ៉ាងនោះថា

នត្ថិ អត្ត សមំ បេមំ

សេចក្តីស្រឡាញ់អ្វី ស្មើនឹងខ្លួនមិនមាន

ពាក្យថា ស្រឡាញ់ខ្លួន ជាប់ចិត្តពេញចិត្តខ្លួន សំដៅដល់ជីវិតនេះឯង ។ សត្វលោកកើតមកហើយ សមប្រាថ្នាក្តី មិនសមប្រាថ្នាក្តី គ្រប់តែជីវិតមានចិត្តស្រឡាញ់ ប្រកាន់ខ្ជាប់ខ្លួន មានទម្លាប់របស់ចិត្តមួយ គឺយកខ្លួនឯងជាធំ ដូច្នេះទើបធ្វើអ្វីៗដើម្បីខ្លួន ដោយការប្រារព្ធយកខ្លួនជាធំ មានចិត្តគិតពីប្រយោជន៍របស់ខ្លួន មុនជាងប្រយោជន៍អ្នកដទៃណាៗទាំងអស់ ។

អំពើ ឬកិច្ចការងារគ្រប់បែបយ៉ាង ដែលគេបានសាងឡើងក្នុងអត្តភាពជាមនុស្សក្តី ជាសត្វក្តី មានការសិក្សា ប្រកបមុខរបរចិញ្ចឹមជីវិត បំពេញការងារ ទៅតាមនាទីតំណែងគ្រប់យ៉ាងនោះ ក៏ព្រោះខ្លួនគេនោះឯង ។

បព្វជិតមិនសង្រួមមិនល្អ គ្រហស្ថឥតរបរមិនប្រសើរថ្លៃថ្នូរ!

ជីវិតកើតមកហើយ ពុំមែនត្រូវនៅព្រងើយ សោះអង្គើយ ប្រាសចាកការងារនោះទេ ជីវិតបាននាំមកនូវទម្ងន់អំរែក ដ៏មហាសែនធ្ងន់ ផ្ទុកបន្ទុបមកលើម្ចាស់ជីវិតសត្វលោក ជីវិតត្រូវការអាហារ ត្រូវការទីជម្រកជ្រកអាស្រ័យ ត្រូវការសំលៀកបំពាក់ ថ្នាំព្យាបាលរោគ ត្រូវការសេចក្តីសប្បាយរីករាយ ភាពស្និទ្ធស្នាល សេចក្តីស្រឡាញ់ និងភាពកក់ក្តៅ ។ តែអ្វីៗគ្រប់យ៉ាង មិនបានមកដោយឯងៗនោះទេ គឺត្រូវមានសេចក្តីព្យាយាម ធន់ទ្រាំ តស៊ូ ជួនកាលជីវិតបានសមស្របតាមសេចក្តីប្រាថ្នា ពេលខ្លះក៏ខុសខកបំណង ទាំងនេះជាចាំបាច់ណាស់ ដែលម្ចាស់ជីវិតត្រូវតែដឹងយល់ ស្គាល់នូវហេតុ

ការណ៍ និងព្យាយាមសម្របទៅតាមហេតុការណ៍នោះៗ បើមិនដូច្នោះទេ នឹងជួបប្រទះនូវបញ្ហាដែលជាផលវិបាកសម្រាប់ជីវិត ពិតមិនខាន ។

ព្រោះហេតុតែស្រឡាញ់ខ្លួន ទើបសត្វលោកធ្វើអ្វីៗទៅតាមចំណូលចំណង់របស់ខ្លួន បំពេញតែតាមតម្រូវការ បម្រើសេចក្តី ប្រាថ្នាខ្លួនជាធំ រហូតដល់ខ្លះច្រឡំវង្វេងលែងដឹងថាអ្វីជាកំហុសអកុសល អ្វីជាកុសល ជាបាបជាបុណ្យគុណទោស ក៏លែងទទួលស្គាល់ដឹងយល់អស់ ។

ដើម្បីបំពេញសេចក្តីត្រូវការនិងបម្រើតណ្ហារបស់ខ្លួន ធ្វើឲ្យមនុស្សខ្លះវង្វេងងងឹត មិនអាចទទួលស្គាល់ថា សភាវៈពិតយ៉ាងណា ដូចជាបុរសម្នាក់មានចិត្តជាប់ជំពាក់ ដោយសេចក្តីស្នេហាទៅលើនារីដែលមានសម្រស់ដ៏ស្រស់បំព្រង ដូចបុប្ផាកំពុងតែរីកមួយទង បុរសខំព្យាយាមលួងលោមដោយសំដីផ្អែមល្ហែម ថ្នាក់ថ្នមលោមចិត្តឲ្យនារីនោះអាណិតបាក់ចិត្តស្រឡាញ់ខ្លួន ។

យើងធ្លាប់ឮ ពាក្យគេពោលជាប្រចាំថា " ខ្ញុំស្រឡាញ់នារីនោះខ្លាំងណាស់, ស្រឡាញ់អស់ពីដួងចិត្ត, សូម្បីបូជាកាយថ្វាយជីវិតក៏ព្រមដែរ " ។ តែដល់ដឹងថា នារីនោះគេមិនស្រឡាញ់ខ្លួន គេបានប្រគល់ក្តីស្នេហ៍ ឲ្យដល់អ្នកផ្សេងរួចទៅហើយ ស្រាប់តែបុរសកំសត់ ផ្ទុះកំហឹងយ៉ាងខ្លាំង រហូតតាមចងអាឃាតព្យាបាទនឹងនារីនោះដោយប្រការផ្សេងៗ ។ នេះក៏ព្រោះអវិជ្ជា

តែបើគេមានស្មារតីរលឹកភ្លាមៗនោះ នឹងឃើញអំពីមហាគុណនៃឪពុកម្ដាយ ដែលបានចិញ្ចឹមថ្នាក់ថ្នមមើលថែតាំងពីចាប់កំណើតចេះក្រឡាប់ ចេះវា អង្គុយ តោង ឈរ ដើរ ជាដើម ។ បើឪពុកម្ដាយមិនបានមើលថៃតែមួយ ពេលណានោះ គេអាចស្លាប់គ្រោះថ្នាក់គ្រប់ពេលបាន ។ នេះជាមហាគុណ មួយចំណែកប៉ុណ្ណោះដូចបានរៀបរាប់ដោយមួយអន្លើដែលកូនគ្រប់ប្រាណ ត្រូវតបគុណជា "គុណធម៌របស់មនុស្ស" ។

អ្វីៗ(សង្ខារធម៌)ទាំងឡាយមិនទៀង ជាហេតុនាំឲ្យសត្វមានទុក្ខ

ភរិយាម្នាក់ បានពោលប្រាប់គេឯងថា " ខ្ញុំស្រឡាញ់ស្វាមីខ្ញុំណាស់, ស្រឡាញ់ដោយស្មោះអស់ពីដួងចិត្ត, ប្ដូរកាយរំលាយជីវិតរួមរស់ជាមួយគ្នា លុះគ្រាអវសាន មិនតែប៉ុណ្ណោះ ព្រមទាំងបានសច្ចាប្រាថ្នាឲ្យបានជួបគ្នាគ្រប់ៗជាតិទៀងផង ។

ដល់ក្រោយមក ស្រាប់តែបុរសជាស្វាមី បែកបែរចិត្តថ្មី ទៅយកស្ត្រីផ្សេងទៀតជាប្រពន្ធ ធ្វើឲ្យស្ត្រីដែលជាភរិយាដើមកើតមានសេចក្ដីក្ដៅក្រហាយ ខ្វល់ខ្វាយអន្ទះអន្ទែង ដេកពួនលែងសុខ នៅមិនស្រណុក លំអុករករឿងបង្កើតឡើងជាបញ្ហា ផ្អើលគេឯង ពេញទាំងស្រុក ។

បើតាមសេចក្ដីដូចពោលរៀបរាប់នេះ យើងតាំងជាសំណួរថា តើបុរសដែលស្រឡាញ់នារី, ស្ត្រីជាភរិយាដែលពោលថា ខ្លួនជាអ្នកស្រឡាញ់

ប្តីនោះ តើពិតជាដូច្នោះមែនឬទេ ? ចម្លើយគឺ ពុំមែនដូច្នោះទេ ! ព្រោះអ្នកទាំងពីរមានសេចក្តីស្រឡាញ់ក៏ពិតមែនហើយ តែសេចក្តីស្រឡាញ់នោះ គឺដើម្បីបម្រើគោលបំណងរបស់គេតែប៉ុណ្ណោះ ដើម្បីខ្លួនគេតែម្យ៉ាង យកអ្នកដទៃមកអាង ប្រាសចាកសេចក្តីពិត ដោយភាពងងឹត វង្វេង មាយាមិនព្រមទទួលស្គាល់នូវទោសកំហុសរបស់ខ្លួន ។

បុរសជាស្វាមីម្នាក់បានពោលឡើងថា"ខ្ញុំប្រច័ណ្ឌប្រពន្ធខ្ញុំណាស់" ។ ហើយស្ត្រីជាភរិយាក៏ពោលពាក្យនេះដូចគ្នាដែរ ។ អ្នកទាំងពីរបានពោលពាក្យដូចគ្នាថា " ការប្រច័ណ្ឌព្រោះតែខ្ញុំស្រឡាញ់គាត់ បាត់មុខមិនបាន " តើសម្តីបែបនេះត្រឹមត្រូវដែរឬទេ ? ពិតជាមិនត្រឹមត្រូវទេ ត្បិតពាក្យថា " ប្រច័ណ្ឌ" បានដល់ការប្រកាន់ជាប់ជំពាក់ហួងហែង បើដូច្នោះយើងសួរទៀតថា តើការប្រច័ណ្ឌនោះដើម្បីអ្នកណា ? ពុំមែនតែដើម្បីខ្លួនឯងទេឬ ?

ឧទាហរណ៍ថា ដែលបុរសម្នាក់បានពោលអះអាងថា " ខ្លួនស្នេហានារីម្នាក់នោះយ៉ាងអស់ពីចិត្តពីថ្លើម សូម្បីតែជីវិតហ៊ានលះបង់ដែរ បើដូច្នោះមែន ហេតុដូចម្តេចក្រោយពេលដែលបានដឹងថា នារីនោះគេមិនស្រឡាញ់ខ្លួន គេបានទៅប្រគល់ក្តីស្នេហ៍ឲ្យទៅបុរសផ្សេង ខ្លួនឯងបែរជាមានកំហឹងឆាបឆេះក្តៅក្រហាយនៅមិនបានទៅវិញ ។ បើដូច្នោះបញ្ជាក់បានថា " សម្តីបុរសនោះ គឺគ្រាន់តែជាការបោកប្រាសប៉ុណ្ណោះ កុំថាឡើយដល់ជីវិតខ្លួន

នោះ សូម្បីតែសេចក្ដីស្នេហាខ្លួន ក៏មិនអាចលះបង់ ដើម្បីបំពេញបំណងឲ្យដល់មនុស្សម្នាក់ ដែលខ្លួនបានពោលថាស្រឡាញ់ស្មោះបានផង ៉ ។

ដោយការជាប់ជំពាក់ ប្រកាន់ហួងហែង ស្រឡាញ់ពេញចិត្តចំពោះតែជីវិតខ្លួន ដូច្នេះហើយទើបធ្វើឲ្យសត្វលោកវង្វេងភ្លេចខ្លួន មិនបានព្យាយាមសម្រាលទម្ងន់ អម្រែកជីវិតខ្លួនឯងឲ្យបានធូរស្រាលទេ គឺបានខំព្យាយាមឆ្លៀតប្រមែប្រមូល ឱបក្រសោបស្រវាពីអ្នកដទៃ មកបន្ថែមពីលើខ្លួនឲ្យកាន់តែធ្ងន់ថែមទៀត ។

សត្វលោកស្រឡាញ់ខ្លួនជាជាងអ្វីៗពិតណាស់ ទោះបីជាខំស្រឡាញ់អ្នកដទៃ ឬខំប្រកបកិច្ចការអ្វីៗគ្រប់យ៉ាង ក៏ដើម្បីសាងលើកកម្ពស់ខ្លួនឲ្យបានថ្លៃថ្នូរ ។ ដោយការស្រឡាញ់ពេញចិត្តនឹងជីវិត ខំព្យាយាមរក្សាការពារ លើកកម្ពស់ឲ្យតម្លៃទៅលើជីវិតថា មានតម្លៃពិតមិនអាចនឹងកាត់ថ្លៃឬប្រមាណប៉ុណ្ណោះបាន ។

១.បញ្ហាផ្លូវចិត្ត ជំងឺផ្លូវចិត្ត និងការថែទាំ

នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ មនុស្សយើងគ្រប់ៗរូបតែងជួបបញ្ហាផ្សេងៗដែលធ្វើឲ្យមានការរំខានក្នុងអារម្មណ៍ និងបង្កឲ្យយើងមានការតានតឹងចិត្ត ។ ជាទូទៅ បញ្ហាខ្លះយើងអាចដោះស្រាយបាន ហើយការតានតឹងចិត្តក៏រសាយអស់ ។ ប៉ុន្តែបញ្ហាខ្លះ ស្មុគស្មាញពុំអាចដោះស្រាយ

បាន បណ្ដាលឲ្យការតានតឹងចិត្តកើតឡើងកាន់តែខ្លាំង និងរ៉ាំរ៉ៃ ធ្វើឲ្យស្ថានភាពផ្លូវចិត្តរបស់គេធ្លាក់ចុះ ហើយអាចបង្កឲ្យមានជំងឺផ្លូវចិត្តក្នុងកម្រិតស្រាល ឬធ្ងន់ខុសៗគ្នា ដូចជា ជំងឺថប់បារម្ភ ជំងឺធ្លាក់ទឹកចិត្តជាដើម ។

អ្នកដែលបានរស់ឆ្លងកាត់ព្រឹត្តិការណ៍ដ៏គួរឲ្យតក់ស្លុត ក្នុងសម័យសង្គ្រាមភាគច្រើនបានរងការប៉ះទង្គិចផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរជាបុគ្គល និងជារួម ធ្វើឲ្យស្ថានភាពផ្លូវចិត្តមានភាពអាប់អួ និងតានតឹងជាប្រចាំក្រោយសង្គ្រាម ។

បញ្ហាផ្លូវចិត្ត និងជំងឺផ្លូវចិត្តអាចកើតឡើងចំពោះមនុស្សគ្រប់វ័យ អាស្រ័យលើស្ថានភាពជាក់ស្ដែងនៃបញ្ហាដែលគេជួបប្រទះក្នុងជីវិត និងបរិយាកាសរស់នៅក្នុងសង្គម ។ បញ្ហាផ្លូវចិត្តបីប្រភេទដែលយុវជនតែងជួបប្រទះជាញឹកញាប់ក្នុងពេលបច្ចុប្បន្ននេះគឺ ៖

☞ ការតានតឹងចិត្ត

☞ ការធ្លាក់ទឹកចិត្ត

☞ បញ្ហាផ្លូវចិត្ត

ដែលបណ្ដាលមកពីផលប៉ះពាល់នៃគ្រឿងញៀន ។

ការយល់ដឹងពីមូលហេតុ និងផលវិបាកនៃបញ្ហា និងជំងឺផ្លូវចិត្ត គឺជាជំនួយយ៉ាងសំខាន់ធ្វើឲ្យយុវជនចេះថែទាំសុខភាពផ្លូវចិត្ត ដើម្បីញ៉ាំងឲ្យស្ថានភាពផ្លូវចិត្តរបស់ខ្លួនមានភាពល្អប្រសើរ និងជាកត្តារួមចំណែកធ្វើឲ្យ

ជីវិតរស់នៅប្រព្រឹត្តទៅប្រកបដោយសេចក្តីសុខផ្នែកអារម្មណ៍ ។ មាន៣ផ្នែកដែលគួរយល់ដឹង ៖

ផ្នែកទី១

ការតានតឹងចិត្ត

តើការតានតឹងចិត្តគឺជាអ្វី ?

ការតានតឹងចិត្ត គឺជាការប្រែប្រួល ឬប្រតិកម្មនៃអារម្មណ៍ដែលកើតមាននៅពេលបុគ្គលជួបប្រទះហេតុការណ៍ ឬក៏បញ្ហាលំបាកផ្សេងៗក្នុងជីវិតរស់នៅដែលត្រូវប្រឈមមុខដោះស្រាយ ។

បុព្វហេតុនៃការតានតឹងចិត្ត

ក្នុងការរស់នៅប្រចាំថ្ងៃ ជាទូទៅយើងតែងតែជួបប្រទះបញ្ហាជាច្រើនដែលជាបុព្វហេតុធ្វើឲ្យយើងតានតឹងដូចជា ទំនាស់ក្នុងគ្រួសារ ជីវភាពក្រលំបាក បន្ទុកការងារច្រើនហួសពេក ការមិនយល់ចិត្តគ្នា ការមិនចុះសម្រុងក្នុងការងារ ការបំពេញការងារពុំបានជោគជ័យ ការគិតព្រួយចំពោះហេតុការណ៍ក្នុងអនាគត និងជំងឺរ៉ាំរ៉ៃប្រចាំកាយជាដើម ។

ចំពោះយុវជនដែលកំពុងតែស្ថិតនៅក្នុងវ័យសិក្សា ជាទូទៅ គេអាចមានអារម្មណ៍តានតឹងនៅពេលជិតប្រឡង កំពុងប្រឡង ដឹងថាប្រឡងធ្លាក់

ពេលមិនចុះសម្រុងជាមួយមិត្តភក្តិ ជាមួយគូស្នេហ៍ ជាមួយគ្រួសារពេលទទួលការស្តីបន្ទោសពីអាណាព្យាបាល ឬពីគ្រូប្រចាំថ្នាក់ ពេលឪពុកម្តាយឬបងប្អូនឈ្លោះទាស់ទែងបែកបាក់គ្នា ពេលឪពុកម្តាយ អាណាព្យាបាល ឬសមាជិកក្នុងគ្រួសារសេពគប់គ្រឿងញៀនរហូតបាត់បង់ស្មារតី ហើយបង្កបញ្ហាអវិជ្ជមានផ្សេងៗក្នុងគ្រួសារ ពេលស្ថិតនៅក្នុងស្ថានភាពទីទ័លក្រ ខ្វះខាតប្រាក់កាសក្នុងការរៀនសូត្រ ភាពអត់ការងារធ្វើ រួមនឹងបញ្ហាផ្សេងៗជាច្រើនទៀត ។

អាការៈនៅពេលមានការតានតឹងចិត្ត

ក. អាការៈផ្នែកអារម្មណ៍ និងចិត្ត

នៅក្នុងពេលដែលយើងប្រឈមមុខនឹងបញ្ហា ស្មុគស្មាញដែលបង្កឲ្យមានការតានតឹងចិត្ត អារម្មណ៍របស់យើងមានការប្រែប្រួលដែលងាយនឹងធ្វើឲ្យយើងមួម៉ៅ ឆេវឆាវ ឆាប់ខឹងច្រឡោត នឿយណាយធុញថប់ក្នុងអារម្មណ៍ ភ្លេចភ្លាំងច្រើនខ្វាយខ្វល់គិតព្រួយច្រើន ពិបាកផ្ចង់អារម្មណ៍ក្នុងការបំពេញការងារ ស្រងូតស្រងាត់ ។ អាការៈឆាប់ខឹងច្រឡោតរឿយៗជំរុញឲ្យអ្នកតានតឹងចិត្តបង្កើតអំពើហិង្សា ។ ករណីនេះ ការចម្រើនចិត្តស្ងប់ និងមេត្តាធម៌ សំឡឹងមើលសេចក្តីល្អរបស់អ្នកផងនោះ ជាកុសលចិត្តដ៏ក្រៃលែង ជាសុខដ៏ធំដែលសត្វលោកត្រូវចម្រើនរឿយ ។

ខ. អាការៈផ្នែករាងកាយ

អស់កំលាំង ឈឺក្បាល ចុករោយសាច់ដុំ បរិភោគអាហារមិនបាន ទទួលទានដំណេកមិនលក់ ណែនទ្រូង ដង្ហើមផុតៗ ឆ្អល់ពោះ គ្មានអារម្មណ៍ផ្នែកផ្លូវភេទ ចំពោះស្ត្រីអាចមានរដូវពុំទៀងទាត់ ។

គ. អាការៈនៃអាកប្បកិរិយា

រសាប់រសល់ មិនរួសរាយរាក់ទាក់ អសកម្មក្នុងការបំពេញការងារផ្សេងៗ ងាយមានទំនាស់ជាមួយគេឯង ។ បុគ្គលខ្លះគិតខុសក៏យកបារីស្រា គ្រឿងញៀនផ្សេងៗធ្វើជាមធ្យោបាយបំបាត់ភាពតានតឹង ត្រូវនិយាយ ឬតាំងចិត្តថា "ទេ" ឬនៅឲ្យឆ្ងាយពីគ្រឿងញៀន និងអបាយមុខទាំងឡាយ។

មធ្យោបាយបំបាត់ការតានតឹងចិត្ត

នៅពេលដែលយើងមានអារម្មណ៍តានតឹង និងស្មុគស្មាញក្នុងចិត្ត យើងត្រូវខិតខំពង្រឹងផ្លូវចិត្តរបស់យើងឲ្យបាន រឹងមាំជាប្រចាំ ហើយគប្បីរកវិធីដោះស្រាយ ដើម្បីឲ្យការរស់នៅរបស់យើងប្រកបដោយស្ថានភាពល្អប្រសើរ ។ មធ្យោបាយបំបាត់ការតានតឹងផ្លូវចិត្តមានច្រើនបែបយ៉ាង ប៉ុន្តែយើងអាចអនុវត្តវិធីងាយៗមួយចំនួនដូចជា ៖

ក. រកវិធីដោះស្រាយល្អៗបណ្ដុះគំនិតសុទិដ្ឋិនិយមប្រកបដោយទស្សនៈវិជ្ជមានព្រមទាំងមានក្ដីសង្ឃឹមជានិច្ចចំពោះអនាគត ដូចជា ចម្រើនសេចក្ដីស្ងប់ក្នុងចិត្ត សម្លឹងតែសេក្ដីល្អពីអ្នកដទៃ មេត្តាធម៌ដល់សព្វសត្វជាដើម ។

ខ. ទទួលទានអាហារឲ្យទៀងទាត់ពេលវេលា សម្រាកឲ្យគ្រប់គ្រាន់ និងធ្វើកិច្ចការកម្សាន្តសប្បាយផ្សេងៗដែលយើងចូលចិត្តដូចជា ការថែសួន ថែច្បារដំណាំ ថែសត្វចិញ្ចឹម ឬធ្វើកិច្ចការផ្ទះផ្សេងៗ អានសៀវភៅមានប្រយោជន៍នានា ញញឹមដោយរំពៃក្នុងចិត្តអំពីគុណរបស់ឳពុកម្ដាយ ឬ សរសេររំលឹកគុណមាតាបិតាជាដើម ។ល។

គ. ជួបសំណេះសំណាលជាមួយមិត្តភក្ដិ ឬអ្នកដែលជិតស្និទ្ធបំផុត ដើម្បីនិយាយពីអារម្មណ៍មួហ្មងទាំងអស់ប្រាប់គ្នាទៅ វិញទៅមក ។

ឃ. ពិគ្រោះបញ្ហាជាមួយអ្នកដែលយើងទុកចិត្តនិងរាប់អានបំផុត ដើម្បីឲ្យគេជួយផ្ដល់កម្លាំងចិត្តក្នុងការដោះស្រាយបញ្ហាដែលយើងជួបប្រទះ ។

ង. ស្ដាប់ឱវាទឪពុកម្ដាយដែលទ្រទ្រង់តួគុណ និងជាព្រហ្មនៃកូនប្រុសស្រី ចាស់ព្រឹទ្ធាចារ្យ ឬព្រះសង្ឃ ឬស្ដាប់ព្រះធម៌ឱវាទរបស់ធម្មាចារ្យសប្បុរសនានា ។

ច. លេងកីឡា ស្តាប់ភ្លេង ទស្សនាភាពយន្ត រឿងកំប្លែង ការប្រគំតន្ត្រី ដើរកម្សាន្តលំហែកាយ ឬចូលរួមការងារសង្គមផ្សេងៗ ។

ឆ. សម្រាកមួយរយៈពីការសិក្សា ឬការងារ ហើយចាប់ផ្តើមឡើងវិញ ។

ជ. ព្យាយាមធ្វើលំហាត់សម្រាកចិត្តកាយ និង សមាធិ ដែលជាមធ្យោបាយហាត់រៀនគ្រប់គ្រងអារម្មណ៍ និងហាត់ពត់ចិត្តឲ្យមានភាព រឹងមាំ (សូមរងចាំអានបន្ថែមក្នុងជំពូកទី៣) ។

ឈ. ប្រតិបត្តិតាមជំនឿសាសនាដូចជាការបន់ស្រន់ សែនព្រេនជាដើម ប្រសិនបើយើងមានជំនឿ ។ ជំនឿនេះសោត គឺជាតួកិលេស ជាតួអកុសល ព្រោះមានអវិជ្ជាជាហេតុបច្ច័យ ។ ការជឿដោយគ្មានមូលដ្ឋានហេតុបច្ច័យ មិនប្រកបដោយយោនិសោមនសិការៈ ជាមង្គលភ្ញាក់ផ្អើលដែលកម្មនោះអាចនាំសត្វលោកទៅអបាយភូមិបាន ។

ផ្នែកទី២

ការធ្លាក់ទឹកចិត្ត និង ជំងឺធ្លាក់ទឹកចិត្ត

តើការធ្លាក់ទឹកចិត្ត និងជំងឺធ្លាក់ទឹកចិត្តគឺជាអ្វី ? ការធ្លាក់ទឹកចិត្ត និងជំងឺធ្លាក់ទឹកចិត្ត គឺជាការធ្លាក់ចុះនៃអារម្មណ៍ដែលនាំឲ្យមានភាពក្រៀមក្រំ

បាត់បង់ភាពសប្បាយ រីករាយ និងបាត់បង់ចំណាប់អារម្មណ៍ទៅលើអ្វីៗជុំវិញខ្លួន ។

បុព្វហេតុនៃការធ្លាក់ទឹកចិត្តនិងជំងឺធ្លាក់ទឹកចិត្ត

មនុស្សយើងអាចកើតមានការធ្លាក់ទឹកចិត្ត នៅពេលដែលយើងប្រឈមមុខនិងការបាត់បង់ផ្សេងៗដូចជាបាត់បង់មនុស្សជាទីស្រឡាញ់ បាត់បង់កិត្តិយស កេរ្តិ៍ឈ្មោះ បាត់បង់ការងារ ទ្រព្យសម្បត្តិ ឬទទួលបរាជ័យក្នុងជិវិត...។ មូលហេតុផ្សេងទៀតនៃជំងឺធ្លាក់ទឹកចិត្តអាចបណ្តាលមកពីបុគ្គលនោះ ឆ្លងកាត់ព្រឹត្តិការណ៍គួរឲ្យអាម៉ាស់ណាមួយដូចជា ការមានផ្ទៃពោះ(ស្ត្រី)ខុសប្រពៃណី ការបែកបាក់ក្នុងជីវិតអាពាហ៍ពិពាហ៍ ឬ ត្រូវគេ បណ្តេញចេញពីការងារ ។ល។

ចំពោះយុវជន គេអាចជួបប្រទះបញ្ហាមួយចំនួន ដែលអាចធ្វើឲ្យធ្លាក់ទឹកចិត្តក្នុងកម្រិតស្រាលក្តី ឬអាចនិងទទួលរងនូវជំងឺធ្លាក់ទឹកចិត្តយ៉ាងធ្ងន់ធ្ងរដូចជា ៖

- ☞ ករណីធ្លាប់រៀនពូកែហើយបែរជាចាញ់គេក្នុងគ្រាណាមួយ ពេលដឹងថាប្រឡងធ្លាក់
- ☞ ពុំមានលទ្ធភាពបន្តការសិក្សាវែងឆ្ងាយបាន
- ☞ អត់ការងារធ្វើ

☞ គូស្នេហ៍បែកចិត្ត
☞ ជ្រុលជ្រួសក្នុងរឿងស្នេហារហូតមានផ្ទៃពោះ
☞ ពុំទទួលការស្រឡាញ់ពីអ្នកដែលខ្លួនស្រឡាញ់
☞ ទទួលសេចក្តីស្រឡាញ់ពុំស្មើគ្នា អំពីអាណាព្យាបាល
☞ ឪពុកម្តាយបដិសេធរៀបការនឹងគូស្នេហ៍ដែលខ្លួនស្រឡាញ់
☞ ទទួលរងការចាប់រំលោភបំពានផ្នែកផ្លូវភេទ
☞ មានជំងឺរ៉ាំរ៉ៃពុំអាចព្យាបាលបានជាដើម ។

តាមធម្មតា ប្រតិកម្មនៃការធ្លាក់ទឹកចិត្តអាចកើតមានក្នុងមួយរយៈពេល ប៉ុន្តែដោយសារការតាំងចិត្ត និងពេលវេលា បុគ្គលនឹងមានអារម្មណ៍ល្អជាប្រក្រតីឡើងវិញ ។ មនុស្សខ្លះអាចកើតមានការធ្លាក់ទឹកចិត្តរយៈពេលយូរថ្ងៃ (ច្រើនជាង២សប្តាហ៍)ដែលជាហេតុនាំឲ្យកើតមានជំងឺធ្លាក់ទឹកចិត្ត ។

ការស្រាវជ្រាវជាច្រើនឲ្យដឹងថា ការធ្លាក់ទឹកចិត្ត និងជំងឺធ្លាក់ទឹកចិត្តកើតមានចំពោះស្ត្រីច្រើនជាងបុរស ដោយហេតុថា ស្ត្រីប្រឈមមុខនឹងការគ្រប់គ្រងកូនចៅ ផ្ទះសម្បែង និងជីវភាពរស់នៅប្រចាំថ្ងៃហើយមិនមានឱកាសបញ្ចេញការតានតឹងចិត្តរបស់ខ្លួនបានល្អប្រសើរក្នុងមជ្ឈដ្ឋានដែលខ្លួនរស់នៅ ។

អាការៈនៃការធ្លាក់ទឹកចិត្ត និង ជំងឺធ្លាក់ទឹកចិត្ត

យើងអាចសម្គាល់ឃើញថា អ្នកដែលធ្លាក់ទឹកចិត្ត ឬអ្នកមានជំងឺធ្លាក់ទឹកចិត្ត តាមរយៈអាការៈមួយចំនួនដូចខាងក្រោមនេះ ៖

ក. មានអារម្មណ៍ស្រុតចុះជាមួយនឹងភាពក្រៀមក្រំ សោកសៅ និងបង្ហាញភាពអស់សង្ឃឹមដោយគិតថាជីវិតគ្មានន័យ ។

ខ. ពុំចាប់អារម្មណ៍ ឬពុំសប្បាយ រីករាយនឹងអ្វីៗដែលខ្លួនធ្លាប់ចូលចិត្ត (គ្មានភាពរីករាយក្នុងជីវិត) ។

ឃ.ពុំសូវចងចាំបានល្អ ភ្លាំងភ្លេចច្រើន ។

ង. ចូលចិត្តនៅឯកោ ជួនកាលពុំសូវចាប់អារម្មណ៍ក្នុងការថែទាំខ្លួនប្រាណ ។

ច. ទទួលទានដំណេកពុំសូវលក់ គ្មានកម្លាំងកំហែង បរិភោគអាហារពុំបាន ។

ឆ. អសកម្មក្នុងការសិក្សា ឬការងារផ្សេងៗក្នុងជីវិតប្រចាំថ្ងៃ ។

* ករណីធ្ងន់ធ្ងរបំផុត ចំពោះអ្នកជំងឺធ្លាក់ទឹកចិត្ត គឺគេច្រើនមានអារម្មណ៍ទុទិដ្ឋិនិយម អស់សង្ឃឹមក្នុងជីវិតហើយប៉ុនប៉ងធ្វើអត្តឃាត ។

មធ្យោបាយដោះស្រាយចំពោះអ្នកធ្លាក់ទឹកចិត្ត

អ្នកធ្លាក់ទឹកចិត្ត ជាទូទៅតែងតែមានគំនិតទុទិដ្ឋិនិយម មើលទៅជុំវិញខ្លួនក្នុងទស្សនៈអវិជ្ជមានមើលស្រាលខ្លួនឯងថា ជាអ្នកដែលគ្មានសមត្ថភាពក្នុងការដោះស្រាយបញ្ហា និងអស់សង្ឃឹមចំពោះអនាគត ។ ចំពោះអ្នកធ្លាក់ទឹកចិត្តកម្រិតស្រាល គេអាចមានលទ្ធភាពជួយខ្លួនឯងបាន ដោយខិតខំសាងកម្លាំងចិត្តឲ្យ រឹងមាំប្រកបដោយទស្សនៈវិជ្ជមាន និងគំនិតសុទិដ្ឋិនិយមក្នុងអនាគត រួមនឹងអនុវត្តវិធីផ្សេងៗទៀតដែលបានរៀបរាប់ក្នុងសៀវភៅនេះ ។

ចំពោះអ្នកធ្លាក់ទឹកចិត្តកម្រិតធ្ងន់ធ្ងរ ដែលអាចឈានទៅមានជំងឺធ្លាក់ទឹកចិត្ត ភាគច្រើនជាមនុស្សដែលមានកម្លាំងចិត្តទន់ខ្សោយក្នុងការប្រឈមមុខដោះស្រាយបញ្ហា ។ ដូចនេះ គេត្រូវការឲ្យអ្នកផងទាំងឡាយនៅជុំវិញខ្លួនគេយល់ពីអារម្មណ៍ និងបញ្ហាដែលគេកំពុងតែមាន ។

អ្នកធ្លាក់ទឹកចិត្ត និងអ្នកជំងឺធ្លាក់ទឹកចិត្ត ត្រូវការយ៉ាងខ្លាំងបំផុតនូវការគាំទ្រផ្នែកផ្លូវចិត្ត និងការលើកទឹកចិត្ត ឬផ្តល់កំលាំងចិត្តអំពីគ្រួសារ និងមិត្តភក្តិនៅជុំវិញខ្លួនគេ ។

ខាងក្រោមនេះជាមធ្យោបាយមួយចំនួនសម្រាប់ជួយគាំទ្រដល់អ្នកធ្លាក់ទឹកចិត្ត ឬអ្នកមានជំងឺធ្លាក់ទឹកចិត្ត ៖

១. ផ្តល់ការប្រឹក្សា

អ្នកធ្លាក់ទឹកចិត្ត ត្រូវការពិគ្រោះផ្តល់យោបល់លើបញ្ហាដែលគេកំពុងតែមាន ។ សមាជិកគ្រួសារ ឪពុកម្តាយ បងប្អូន ឬមិត្តភក្តិ គប្បីជួយផ្តល់ការគាំទ្រផ្លូវចិត្តដោយផ្តល់គំនិតយោបល់ល្អៗដល់អ្នកជំងឺ ។ ក្រៅពីការផ្តល់ប្រឹក្សាពីសំណាក់គ្រួសារ រួមនិងមិត្តភក្តិ អ្នកឯកទេសជំនាញខាងផ្តល់ប្រឹក្សាក៏អាចជួយលើកទឹកចិត្តអ្នកជំងឺឲ្យប្រសើរឡើងវិញ ព្រមទាំងជួយធ្វើឲ្យគេផ្លាស់ប្តូរគំនិត និងអាកប្បកិរិយាអវិជ្ជមាន ហើយគិតចាប់ធ្វើអ្វីៗដែលល្អសារជាថ្មី និងជាក្តីសង្ឃឹមសម្រាប់ជីវិតរបស់គេទៅថ្ងៃមុខ ។

២. ការព្យាបាល

ជំងឺធ្លាក់ទឹកចិត្ត ជាជំងឺដែលអាចព្យាបាលបាន ។ ចំពោះករណីធ្លាក់ទឹកចិត្តធ្ងន់ធ្ងរ គឺត្រូវនាំអ្នកជំងឺទៅពិគ្រោះ និងទទួលការពិនិត្យព្យាបាលពីសំណាក់គ្រូពេទ្យ ។ ក្រៅពីការផ្តល់ប្រឹក្សា គ្រូពេទ្យអាចព្យាបាលអ្នកជំងឺដោយឱសថកែរោគធ្លាក់ទឹកចិត្ត ។

៣. គាំទ្រពីគ្រួសារ និង សហគមន៍

ឪពុកម្តាយ បងប្អូន មិត្តភក្តិ និងអ្នកស្រុកភូមិ គប្បីយកចិត្តទុកដាក់ដល់អ្នកជំងឺធ្លាក់ទឹកចិត្ត ដោយផ្តល់ការគាំទ្រដល់ពួកគេឲ្យបានសមស្រប

និងទាន់ពេលវេលា ជៀសវាងការស្តីបន្ទោស ឬដាក់ទណ្ឌកម្មបន្ថែមដល់អ្នកមានបញ្ហា ដោយយើងគិតថាគេបានប្រព្រឹត្តកំហុស ឬការខុសឆ្គងអ្វីមួយ ដែលជាភាពអាម៉ាស់សម្រាប់គ្រួសារនិងសហគមន៍ ឬជាការអាម៉ាស់សម្រាប់ខ្លួនគេផ្ទាល់ ។

ក្រុមគ្រួសារគប្បីព្យាបាលនិងឃ្លាំមើលអ្នកជំងឺជាប្រចាំ ព្រោះអ្នកជំងឺអាចគិតខុស ហើយអាចធ្វើទុក្ខទោសចំពោះខ្លួនឯងបាន(ធ្វើអត្តឃាត) ក្នុងរយៈពេលមួយដ៏ខ្លី ។ ត្រូវយកវត្ថុ ឬរបស់ដែលអាចបង្កគ្រោះថ្នាក់ចេញឲ្យឆ្ងាយពីអ្នកជំងឺដូចជាខ្សែ កាំបិត កន្ត្រៃ ឬកាំភ្លើងជាដើម ដើម្បីបង្ការកុំឲ្យគេសម្លាប់ខ្លួន ។ គប្បីស្តាប់ដោយយកចិត្តទុកដាក់នូវរឿងរ៉ាវរបស់អ្នកមានបញ្ហាផ្លូវចិត្តដោយឲ្យគេនិយាយបានហូរហែអំពីមូលហេតុដែលនាំឲ្យគេធ្លាក់ទឹកចិត្ត ។ លើកទឹកចិត្តឲ្យអ្នកជំងឺបញ្ចេញអារម្មណ៍សោកសៅរបស់គេ ដូចជា បើនៅពេលគេយំ ត្រូវទុកឲ្យគេយំឲ្យអស់ចិត្ត ។ ត្រូវពោលពាក្យលួងលោម និងលើកទឹកចិត្តធ្វើឲ្យអ្នកជំងឺមានការគោរពជឿជាក់ចំពោះខ្លួនឯង ដោយយល់ថា ខ្លួនជាមនុស្សមានតំលៃ ។

ផ្នែកទី ៣

ផលប៉ះពាល់នៃគ្រឿងញៀនចំពោះផ្លូវចិត្ត និងផ្លូវកាយ

តើគ្រឿងញៀនជាអ្វី ?

គ្រឿងញៀនគឺជាសារធាតុគីមី ឬរុក្ខជាតិ នៅពេលដែលយើងប្រើទៅ វាមានឥទ្ធិពលរំញោចយ៉ាងខ្លាំងលើផ្លូវចិត្ត និងផ្លូវកាយដូចជាធ្វើឲ្យយើងមានអារម្មណ៍រវើយរវាយអណ្តែតអណ្តូង ឬក្លាហានខុសពីលក្ខណៈធម្មតាដែលមនុស្សគ្រប់រូបមាន អាចធ្វើឲ្យស្ពឹកស្រពន់ បំបាត់ភាពចុកចាប់ និងភាពអស់កម្លាំង ឬបង្កជារោគសញ្ញាផ្សេងៗទៀតជាច្រើន ។ អ្នកប្រើប្រាស់មានអាកប្បកិរិយាចំណុះគ្រឿងញៀនទាំងនោះ ។ នៅពេលដែលគេបានប្រើវាម្តងហើយ វាធ្វើឲ្យគេមានអារម្មណ៍ចង់ប្រើប្រាស់បន្តដោយអត់ទ្រាំពុំបាន ។

នៅប្រទេសកម្ពុជាយើង គេអាចប្រទះឃើញគ្រឿងញៀនធម្មជាតិមួយចំនួនដូចជា កញ្ឆា អាភៀន និងគ្រឿងញៀនសំយោគដែលមានរូបរាងបន្លំ ដូចជាឱសថដែលប្រើប្រាស់ក្នុងវេជ្ជសាស្ត្រមានឈ្មោះដូចជា អាំហ្វេតាមីន (AMPHETAMINE) អ៊ិចស្តាស៊ី (ECSTASY) អិលអេសឌី (LSD) កាតាមីន (KETAMINE) មេតាំហ្វេតាមីន (MATAMPHETAMINE) ។ល។ ក្រៅពីនេះ គេឃើញមានគ្រឿងញៀនធម្មជាតិពាក់កណ្តាលសំយោគ ដែល

មានឈ្មោះថា ហេរ៉ូអ៊ីន (HEROIN) ជាម្សៅ ឬគ្រាប់ រួមនិងម្សៅកូកាអ៊ីន (COCAIN) និងគ្រឿងញៀនផ្សេងៗមួយចំនួនទៀត ។

បុព្វហេតុដែលនាំឲ្យយុវវ័យប្រឡូកក្នុងគ្រឿងញៀន

នៅចុងទសវត្សទី ៩០ បាតុភូតគួរឲ្យព្រួយបារម្ភពីការកើតឡើងមានពីរចំណុច គឺ

- ទីមួយគឺ ការប្រើប្រាស់សារធាតុមេតាំហ្វេតាមីន និងថ្នាំញៀនប្រភេទលើកកម្លាំង អេធីស៊ី (ATC)បានកើនឡើងខ្លាំងក្នុងជួយយុវជនជាសិស្សសាលា អ្នករកស៊ីផ្លូវភេទ និងកម្មករ ។

- ទីពីរគឺ ការប្រើប្រាស់សារធាតុហិត (កាវ) និងថ្នាំលើកកម្លាំងដែលជាថ្នាំញៀនប្រភេទយ៉ាម៉ា ឬយ៉ាបា ដោយកុមារអនាថា និងកុមារប្រើកម្លាំងកាយដើម្បីស្វែងរកកម្រៃចិញ្ចឹមជីវិត មានចំនួនកាន់តែច្រើនឡើងក្នុងចំណោមជនក្រីក្រ ។ មានក្មេងអនាថាកាន់តែច្រើនឡើងកំពុងប្រើប្រាស់ម្ទុលចាក់ល្បាយអាភៀន ដែលជាសារធាតុញៀនបញ្ចូលទៅក្នុងសរសៃឈាម ។

មានហេតុផលជាច្រើនទៀតដែលជំរុញឲ្យយុវជននិងកុមារចាប់ផ្តើមប្រើប្រាស់គ្រឿងញៀនដូចជា ការបង្ខំពីមិត្តភក្តិ ការប្រើតាមគ្នា ការចង់ដឹង

(ដោយសាកល្បងម្តងហើយក៏ចាប់ផ្តើមញៀន) មានគេលួចដាក់ឲ្យប្រើដោយមិនដឹងខ្លួន ហើយក៏ចាប់ផ្តើមមានអារម្មណ៍ញៀន ។ ខ្លះទៀតប្រើគ្រឿងញៀដើម្បីភាពសប្បាយ រំភើបត្រេកត្រអាល ដើម្បីរំសាយទុក្ខ ដើម្បីធ្វើពលកម្មធ្ងន់ៗ បានយូរ បំបាត់ការស្រេកឃ្លានបង្កើនភាពងោកងុយ ឬបង្កកុំឲ្យដេកលក់ ជំរុញចិត្តឲ្យមានភាពក្លាហាន ឬដើម្បីបង្កើនអារម្មណ៍រួមភេទ ។ល។ ប៉ុន្តែមធ្យោបាយទាំងនេះ អាចបំផ្លាញសុខភាពក្នុងកម្រិតធ្ងន់ធ្ងរ ។

ផលប៉ះពាល់នៃគ្រឿងញៀនចំពោះផ្លូវចិត្ត

ការប្រើប្រាស់សារធាតុញៀន ធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះផ្លូវចិត្តរបស់អ្នកប្រើប្រាស់ដូចជា វង្វេងវង្វាន់ស្មារតី ការចងចាំថយចុះភ្លេចភ្លាំងច្រើន មានអារម្មណ៍រវើរវាយ អណ្តែតអណ្តូងសប្បាយ ឆេវឆាវ ឬស្ងាត់ស្ងៀម និយាយស្តីខុសពីធម្មតា ចប់អារម្មណ៍ក្នុងចិត្តស្រើបស្រាលនឹងបញ្ហា ផ្លូវភេទ ងោកងុយ ឬពុំដេកសោះតែម្តង និយាយប៉ប៉ាច់ប៉ប៉ោចពុំប្រាកដប្រជា ។ល។ និយាយជារួមនៅពេលដែលមនុស្សម្នាក់ស្រវឹងគ្រឿងញៀន ភាពវាងវៃ ការគិត វិញ្ញាណ ការសម្រេចចិត្ត ភាពរំជើបរំជួលចិត្ត និងអាកប្បកិរិយារបស់មនុស្សម្នាក់នោះផ្លាស់ប្តូរខុសពីធម្មតា តិច ឬច្រើនអាស្រ័យលើបរិមាណគ្រឿងញៀនដែលមនុស្សនោះបានប្រើប្រាស់ ។

ចំពោះអ្នកដែលប្រើប្រាស់គ្រឿងញៀននៅក្នុងបរិមាណខ្ពស់ និង យូរអង្វែង អាចមានជំងឺ វិកលចរិត ។

ផលប៉ះពាល់នៃគ្រឿងញៀនចំពោះផ្លូវកាយ

ការប្រើប្រាស់សារធាតុញៀន ក៏ធ្វើឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់រូបកាយទាំងមូលផងដែរដូចជា អស់កម្លាំងល្ហិតល្ហៃរាងកាយ ស្គាំងស្គម និងសរីរាង្គនានាដូចជា ភ្នែក ច្រមុះ ត្រចៀក បេះដូង ថ្លើម ខួរក្បាល សាច់ដុំ...ទ្រុឌទ្រោមចុះខ្សោយ និងងាយទទួលជម្ងឺផ្សេងៗ ដូចជា ក្អករ៉ាំរ៉ៃ រលាកទងសួត រលាកខួរក្បាល មហារីកសួត ខូចមុខងារបន្តពូជជាដើម ។ ការប្រើម្ជុលរួមគ្នាដើម្បីចាក់បញ្ចូលគ្រឿងញៀននៅក្នុងសរសៃឈាម និង អារម្មណ៍ស្រើបស្រាលផ្នែកផ្លូវភេទខុសពីធម្មតា បណ្តាលឲ្យអ្នកសេពគ្រឿងញៀនខ្វះការប្រុងប្រយ័ត្នក្នុងការរួមភេទដែលជាកត្តា នាំឲ្យឆ្លងជម្ងឺកាមរោគ និងមេរោគអេដស៍ ។

ផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀតរបស់គ្រឿងញៀន

ក្រៅពីផលប៉ះពាល់ចំពោះផ្លូវចិត្ត និងផ្លូវកាយ គ្រឿងញៀនបានធ្វើឲ្យមានផលវិបាកយ៉ាងធ្ងន់ធ្ងរផងដែរចំពោះសន្តិសុខផ្ទាល់ខ្លួន ពីព្រោះអ្នកសេពគ្រឿងញៀនអាចហ៊ានប្រព្រឹត្តអំពើហិង្សា ឧក្រិដ្ឋកម្ម អំពើមនុស្សឃាត

ឬបំពានផ្លូវច្បាប់ដែលអាចជាប់ពន្ធនាគារ ឬមានគ្រោះថ្នាក់ផ្សេងៗដល់ជីវិត ដូចជាគ្រោះថ្នាក់ចរាចរជាដើម ។

អ្នកសេពគ្រឿងញៀនក៏បង្កើតឲ្យមានផលវិបាកចំពោះគ្រួសាររបស់ខ្លួនផងដែរដូចជា បាត់បង់សមត្ថភាពក្នុងការរៀនសូត្រ សមត្ថភាពក្នុងការបំពេញការងារ បាត់បង់អាជីព ចំណូលគ្រួសារថយចុះ ប្រព្រឹត្តអំពើហិង្សាក្នុងគ្រួសារ កិត្តិយសគ្រួសារអាប់ឱន ។ល។ ក្រៅពីផលប៉ះពាល់ចំពោះសន្តិសុខផ្ទាល់ខ្លួន និងគ្រួសារ គ្រឿងញៀនបានបង្កឲ្យមានផលវិបាកផ្សេងៗទៀតដល់សហគមន៍ និងសង្គមជាតិ ដូចជាបង្កើនជម្ងឺ និងការចំណាយក្នុងសហគមន៍លើបញ្ហាសុខភាព បន្ថយសមត្ថភាពក្នុងការបំពេញការងារ បង្កឲ្យមានឧក្រិដ្ឋកម្ម ឃាតកម្ម ចោរកម្ម អសន្តិសុខ ហើយធនធានមនុស្សនៃសង្គមជាតិថយចុះ ការអភិវឌ្ឍន៍សង្គមមានការយឺតយ៉ាវ សីលធម៌សង្គមធ្លាក់ចុះទាប ប្រពៃណី វប្បធម៌ជាតិរេចរិល ប្រទេសជាតិទន់ខ្សោយ ។

យុវជនគួរជៀសវាងពីថ្នាំញៀន

ដើម្បីចៀសវាងនូវផលវិបាកទាំងឡាយដែលកើតឡើងដោយសារគ្រឿងញៀន យុវជនត្រូវស្វែងយល់ឲ្យបានច្បាស់អំពីផលប៉ះពាល់អវិជ្ជមានទាំងឡាយដែលកើតឡើងដោយសារគ្រឿងញៀន ។ វិធានការតែមួយគត់ដ៏មានប្រសិទ្ធភាពបំផុតដើម្បីបង្កាបញ្ហានេះគឺ យុវជនត្រូវចៀសវាង និងនៅ

ឲ្យឆ្ងាយពីគ្រឿងញៀន ។ ត្រូវប្រុងប្រយ័ត្នខ្លួនកុំឲ្យលង់ក្នុងការបោកបញ្ឆោត ឬការបង្ខិតបង្ខំឲ្យប្រើប្រាស់គ្រឿងញៀន ឬប្រើគ្រឿងញៀនក្នុងការដោះស្រាយបញ្ហាតានតឹងចិត្ត ។ និយាយរួមត្រូវកំណត់ឲ្យបានច្បាស់ថាការប្រើប្រាស់គ្រឿងញៀន ឬពាក់ព័ន្ធនឹងគ្រឿងញៀន គឺជាឧក្រិដ្ឋកម្ម និងជាការបាត់បង់អ្វីៗ**ចៀស**មិនផុត ។

២. ចង់ឲ្យជីវិតមានសេចក្តីសុខ

ការដែលមនុស្សធ្វើការយ៉ាងយ៉ាប់យឺន ត្រូវតស៊ូនឹងសេចក្តីលំបាកទីទ័លក្រដ៏សែនវេទនា សាច់ឈាមស្មើរខ្វាយ ភ្នែកស្មើរលៀន ក៏មានសេចក្តីប្រាថ្នាតែមួយ គឺសេចក្តីសុខរបស់ជីវិត ។ មិនដែលមាននរណាម្នាក់សោះក្នុងលោកនេះ ដែលមិនប្រាថ្នានូវសេចក្តីសុខកាយសប្បាយចិត្តនោះទេ ។ បើសិនគ្រប់ៗគ្នាត្រូវការសេចក្តីសុខសប្បាយដូច្នេះ ក៏ជាធម្មតាដែលគេទាំងនោះត្រូវតែព្យាយាមខ្វល់ខ្វាយ និងខ្នះខ្នែងស្វែងរកសេចក្តីសុខសប្បាយ ឲ្យដល់ខ្លួនឯងតាមសមត្ថភាពរបស់ខ្លួន ឬតាមដែលខ្លួនអាចនឹងធ្វើបាន ។ បើយើងគ្រប់គ្នាចង់បានសេចក្តីសុខ សេចក្តីសប្បាយដូច្នេះ យើងក៏ត្រូវតែព្យាយាមធ្វើ ព្យាយាមអត់ធន់គ្រប់កម្មវិធីគ្រប់មធ្យោបាយ ដើម្បីសេចក្តីចម្រើនរុងរឿងឲ្យដល់ខ្លួនឯងក្នុងបច្ចុប្បន្ននិងអនាគត ។ ចាប់តាំងពីកម្មកររកព្រឹកហូបល្ងាច រកល្ងាចស៊ីព្រឹក ដរាបដល់រដ្ឋបុរសដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញក្នុងពិភពលោក ។ បុគ្គលទាំងនេះ សុទ្ធតែបានព្យាយាម

ខ្វល់ខ្វាយស្វែងរកសេចក្ដីសុខ? សេចក្ដីសប្បាយ? ឲ្យដល់ខ្លួនឯងដោយប្ដូរផ្ដាច់នឹងដោយពេញសមត្ថភាព ។ នរណាអង្គុយឱបដៃ ឬរង់ចាំតែជោគវាសនា និងភព្វសំណាង ឬនរណាចាំតែបន់ស្រន់សូមឲ្យទេវតា ឥន្ទ្រ ព្រហ្ម ឬព្រះអាទិទេព ព្រះជាម្ចាស់ជួយនោះ ជារឿងផ្ដុកកំប្លែងគួរឲ្យអស់សំណើចពន់ពេកណាស់ ។

មនុស្សដែលបានក្លាយទៅជាអ្នកធំសម្បើម ឬក្លាយទៅជាមនុស្សសំខាន់ៗ មានកេរ្តិ៍ឈ្មោះល្បីល្បាញពេញសាកលលោកដូចជា អឡិកហ្សាន់ដឺរមហារាជចក្រពត្តិណាប៉ូឡេអុង ប៉ូណាបារត៍យ៉ជ ស្ទីវេនស័ន បេនហ្សាមិន ហ្វ្រែងក្លិន ។ល។ ក៏ព្រោះគេទាំងនោះអាស្រ័យកម្លាំងជំរុញនៃចិត្ត ដែលកើតមានមកពីសេចក្ដីប្រាថ្នានូវសេចក្ដីសុខសេចក្ដីសប្បាយដើម្បីខ្លួនឯង មែនឬទេ? ។ ក្រោមឧត្តមគតិរបស់មនុស្ស ក្នុងរបបសេរីនិយម (Liberalism) មនុស្សគ្រប់រូបត្រូវជួយខ្លួនឯងធ្វើទៅដើម្បីខ្លួនឯង រកសេចក្ដីសុខក្សេមក្សាន្តដល់ខ្លួនឯង ។ អ្នកណាជំអក់ទម្រន់ អ្នកណាខ្វះសមត្ថភាព អ្នកណាមិនអត់ធន់ឲ្យមុះមុត អ្នកណាខ្ជិលច្រអូស អ្នកណាមិនតស៊ូ ក៏ត្រូវបានទទួលសេចក្ដីលំបាកទុក្ខវេទនារហូតអស់ជីវិត ។ សូមចាំយ៉ាងខ្លីថា "ខ្ជិល គឺ វិនាស" ។

កាលបើសេចក្តីសុខ ជាសេចក្តីប្រាថ្នា ជាសេចក្តីត្រូវការរបស់មនុស្សទូទៅដូច្នេះហើយ ។ ទស្សនៈនៃជីវិតគឺ "ត្រូវធ្វើគ្រប់កម្មវិធី និងគ្រប់មធ្យោបាយជាកុសល ដើម្បីស្នេរភាពដល់ជីវិតខ្លួនឯង" ។

ការប្រាថ្នានូវសេចក្តីសុខ ទើបជាឥទ្ធិពលមួយជួយប្រានឲ្យ មនុស្សឧស្សាហ៍មានភាពខ្លាំងក្លាបំផុត ក្នុងការងារ ។ ដោយហេតុនេះបានហ៊ានពោល សេចក្តីប្រាថ្នានូវក្នុងឆាកជីវិត ក៏ជាមន្តឱសថមួយ ជួយជម្រុញរុញច្រានឲ្យមនុស្សបោះជំហានទៅមុខបាន ឬន័យមួយទៀតថា ការប្រាថ្នានូវសេចក្តី សុខនៃឆាកជីវិតនេះហើយ ចាត់ជាថាមពលជួយជំរុញឲ្យកើតភាពជា "អច្ឆរិយៈ" បាន ។

៣. ការបញ្ជ្រាបកម្មទស្សនៈទៅក្នុងសង្គម

ការបញ្ចូលទស្សនៈកម្មផលទៅក្នុងសង្គម គឺមានប្រសិទ្ធភាព និងមានប្រយោជន៍យ៉ាងសម្បើម សម្រាប់ពួកពុទ្ធសាសនិកជនទូទៅ ប្រសិនបើបុគ្គលបានយល់អំពីរចនាសម្ព័ន្ធរបស់ច្បាប់កម្មនេះ ឲ្យបានជ្រាលជ្រៅ វានឹងជួយផ្តល់នូវចំណេះដឹង ការស្វែងយល់ព្រះពុទ្ធឱវាទ ស្តីពីភាពក្រក្រី និងភាពសំបូររុងរឿង ដោយទ្រព្យសម្បត្តិកាន់តែច្បាស់ឡើងថែមទៀត ។ យោងតាមស័ព្ទក្នុងព្រះពុទ្ធសាសនា កម្ម ជាភាសាបាលី ឬកម៌ ជាភាសាសំស្រ្កឹត ស្មើនឹងពាក្យថា ទង្វើ ជាភាសាខ្មែរ ។ ទស្សនៈកម្មផលនេះ គឺដៅ

យកទង្វើគ្រប់យ៉ាង ដែលប្រកបដោយចេតនា ហើយវានឹងហុចផលដល់អ្នកធ្វើតាមផ្លូវណាមួយជាប្រាកដ ។ វិបាក(ផល)ខ្សោយ ឬខ្លាំង គឺអាស្រ័យលើដើមហេតុដែលប្រកបដោយចេតនានោះ ។ ប្រសិនបើចេតនារបស់បុគ្គលអ្នកធ្វើ មានកម្លាំងខ្លាំងក្លា បន្ទាប់មកចេតនានោះ នឹងបង្កើតនូវសកម្មភាពយ៉ាងខ្លាំងក្លា ហើយសកម្មភាពនោះ នឹងឲ្យផលកើនឡើងខ្លាំងដែរ ។ លើសពីនេះទៅទៀត យើងធ្វើកម្មដោយកាយ វាចា ចិត្ត ។ ជាការពិត កម្មជាច្បាប់ហេតុផល (Cause and Effect) ឬសកម្មភាព និងប្រតិកម្ម ។ ដូច្នេះទ្រឹស្តីកម្មផលមានលក្ខណៈខុសគ្នាពីទ្រឹស្តីយុត្តិធម៌ (Moral justice) ឬការប្រទានពរ និងការដាក់ទោស (Reward and Punishment) ដែលជាប់ទាក់ទង ជាមួយអាទិទេព (God)[៤] ។

ទ្រឹស្តីនៃយុត្តិធម៌ទាក់ទងនឹងទស្សនៈអាទិទេព មនុស្សជាច្រើនជឿថា ព្រះអាទិទេពជាអ្នកបង្កើតច្បាប់ ហើយនៅចាំកាត់ក្តីវិនិច្ឆ័យថា អ្វីត្រូវអ្វីខុស ។ល។ ទស្សនៈនៃការប្រទានពរនិងការដាក់ទោស គឺអាស្រ័យលើព្រះអាទិទេព ។ ផ្ទុយទៅវិញ កម្មជាច្បាប់ធម្មជាតិ ជាប់ជាមួយកម្មនេះ គឺជាសក្តានុពល[៥]នៃការឲ្យផលរបស់កម្ម ពោលគឺមានហេតុរមែងមានផល នេះជាច្បាប់របស់ធម្មជាតិ ។ កម្មប្រៀបបាននឹងគ្រាប់ពូជដែលតែងផ្តល់ផ្លែ

---

[៤] ទ្រឹស្តីដែលមាននិយាយនៅក្នុងសាសនាគ្រឹស្ត(មិនមែនយុត្តិប្រព័ន្ធតុលាការឡើយ ។

[៥] រថដែលនាំទៅដោយកម្លាំង ។

ព្រោះហេតុនេះ កម្មជាច្បាប់ធម្មជាតិមួយ ហើយគ្មានអ្វីជាប់ពាក់ព័ន្ធជាមួយទស្សនៈយុត្តិធម៌ ដែលគ្រប់គ្រងដោយព្រះអាទិទេព ឬវត្ថុសក្តិសិទ្ធិដទៃនោះទ្បើយ ។ ហេតុនេះ ចំពោះពុទ្ធសាសនិកជនទាំងឡាយវិញ ការស្គាល់ថានរណាជាអ្នកទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ទើបជាការសំខាន់ណាស់ប្រសើរជាងការដឹងថា នរណាជាអ្នកបង្កើតលោក ហើយលោកនេះកើតទ្បើងនៅពេលណា ។

មានការសាកសួរជាញឹកញាប់ថា តើហេតុអ្វីមនុស្សខ្លះមានទ្រព្យស្តុកស្តម្ភ មនុស្សខ្លះទីទ័លក្រ? ហេតុអ្វីបានជាធម្មជាតិតម្រូវឲ្យមានលក្ខណៈខុសៗគ្នាដូច្នេះ? ចំពោះសំនួរទាំងនេះ ទ្រឹស្តីរបស់ព្រះពុទ្ធសាសនាត្រង់ទស្សនៈកម្មផលបានលាតត្រដាងយ៉ាងពិស្តារ ។ ក្នុងព្រះពុទ្ធសាសនាមានសម្តែងថា គ្មាននរណាម្នាក់អាចកើតមកដោយគ្មានបុព្វហេតុ និងវត្តមាននៃបច្ច័យសំខាន់មួយចំនួននោះបានទេ ។ ដូច្នេះ ជីវិតបច្ចុប្បន្ន គឺជាប់ទាក់ទងនឹងជីវិតក្នុងអតីត ដោយមានហេតុនេះហើយ ទើបមានជាតិថ្មីបន្ទាប់ពីលះលោកនេះទៅ ។ ហេតុបច្ច័យនេះ ត្រូវបានគេស្គាល់តាមទ្រឹស្តីថា "បដិច្ចសមុប្បាទ" ។ ពុទ្ធសាសនិកជនមានជំនឿថា "អាក្រក់ ល្អ ស ខ្មៅ" របស់បុគ្គលណាមួយ គឺបានមកពីការសាងទ្បើងរបស់បុគ្គលនោះដោយផ្ទាល់ មានន័យថា បុគ្គលសាងសួគ៌ សាងនរកដោយខ្លួនឯងយ៉ាងពិតប្រាកដ ។ ព្រោះហេតុនេះ សង្គមពុទ្ធសាសនិក បានដាក់ទស្សនៈកម្មនេះ

យ៉ាងទូលំទូលាយចូលទៅក្នុងការងារ ពាណិជ្ជកម្ម ការអប់រំ បញ្ហាសង្គម និងការដំកល់ខ្លួនជាដើម ។ល។

៤. សុខរបស់គ្រហស្ថ

បុគ្គលជាគ្រហស្ថ រមែងប្រកបដោយសេចក្ដីសុខ ក្នុងការប្រើប្រាស់ចាយវាយទ្រព្យសម្បត្តិដែលខ្លួនមានដូចមានសម្ដែងទុកក្នុង

ព្រះសុត្តន្តបិដក អង្គុត្តរនិកាយ ចតុក្កនិបាត ភាគ៤២ ទំព័រ១៧០ ថា :

សុខរបស់គ្រហស្ថមាន ៤យ៉ាងគឺ

១. អត្ថសុខ សុខកើតអំពីការមានទ្រព្យ

២. ភោគសុខ សុខកើតអំពីការប្រើប្រាស់ទ្រព្យ

៣. អនណសុខ សុខកើតអំពីការមិនជំពាក់បំណុលគេ

៤. អនវជ្ជសុខ សុខកើតអំពីការងារប្រាសចាកទោស ។

សុខកើតអំពីការមានទ្រព្យ រីករាយក្នុងចិត្តព្រោះដឹងថា ខ្លួនមានភោគទ្រព្យ ជាទ្រព្យដែលបានមកដោយកម្លាំងព្យាយាមរបស់ខ្លួន ហើយតាមផ្លូវសុចរិតទៀងត្រង់ផង ។

សុខកើតអំពីការបរិភោគ ប្រើប្រាស់ចាយវាយនូវទ្រព្យសម្បត្តិ រីករាយក្នុងចិត្ត ព្រោះថាខ្លួនបានប្រើប្រាស់ទ្រព្យ ដែលបានមកដោយសុចរិតកម្ម ចិញ្ចឹមជីវិតខ្លួនឯងផង ចិញ្ចឹមមាតាបិតាភរិយាផង ចិញ្ចឹមអ្នកផងផ្សេងទៀតដែលគួរចិញ្ចឹមផង និងបំពេញនូវគុណប្រយោជន៍ ដោយធ្វើនូវអំពើល្អ គឺទក្ខិណាទានផង ។

គួរជ្រាបថា សេចក្ដីសុខទាំងពីរយ៉ាងនេះគឺ អត្ថសុខ និងភោគសុខ រមែងមានការជាប់ទាក់ទងជាមួយបុណ្យ ដែលខ្លួនបានធ្វើទុកហើយក្នុងកាលមុនផង ព្រោះបើខ្វះបុណ្យនោះ សូម្បីកំណើតជាមនុស្សនេះ យើងមិនដឹងជាទាមទារយ៉ាងម៉េចបានទេ ចាំបាច់ពោលថ្វីដល់សេចក្ដីសុខផ្សេងៗទៀតនោះ ។ ម៉្យាងទៀត បានកើតមកហើយបើខ្វះបុណ្យ សម្រាប់ធ្វើឲ្យមានអាយុវែង រមែងស្លាប់ទាំងនៅវ័យក្មេង ក៏មិនដឹងតវ៉ាជាមួយអ្នកណាដែរ ។

សុខកើតអំពីការមិនជំពាក់បំណុលគេ រីករាយក្នុងចិត្តឡិតមិនមានម្ចាស់បំណុលមកទាមទារ ។ ការជំពាក់បំណុលគេ រមែងតែងតែសង ម៉្យាងជំពាក់ប្រាក់ ម៉្យាងទៀតជំពាក់កម្ម ។ ការជំពាក់កម្ម ព្រោះការអត់សទ្ធា

ហើយប្រព្រឹត្តនូវបញ្ចវេរា គឺពៀរ ៥ប្រការ មានការសម្លាប់សត្វ លួចទ្រព្យគេជាដើម ។ សម្លាប់សត្វជំពាក់ជីវិត ធ្វើការលួចប្លន់ជំពាក់ទ្រព្យគេ ប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ជំពាក់សេចក្ដីសរសើរអ្នកដទៃ បើនិយាយកុហកជំពាក់ការងារដ៏ប្រពៃនៅក្នុងសង្គម ។ នៅក្នុងលោកនេះ រមែងមានការសងបំណុលច្រើនណាស់ ព្រោះអំពើអាក្រក់ដែលខ្លួនបានប្រព្រឹត្តហើយ ដូច្នេះហើយធ្វើជាមនុស្សត្រូវតែខំប្រឹងប្រែងដើម្បីខ្លួនឯង ជាអ្នកមិនជំពាក់បំណុលគេតទៅ ។

សុខកើតអំពីការងារប្រាសចាកទោស រីករាយក្នុងចិត្តត្បិតខ្លួនមានការប្រព្រឹត្តសុចរិត ចិញ្ចឹមដោយប្រពៃមិនធ្វើជាទាសៈនៃថៅកែបាប ពោលគឺមិនតាមបំរើចិត្តបាបរបស់ខ្លួនឯងឡើយ ។

បណ្ដាសុខទាំង ៤យ៉ាងនេះ សុខទី៤គឺ **អនវជ្ជសុខ** មានគុណតម្លៃប្រសើរដ៏ក្រៃលែង គឺប្រសើរជាងសុខ ៣ ខាងដើម ។ សូមមនុស្សទាំងឡាយ កុំមើលរំលងសេចក្ដីសុខទី ៤ នេះឲ្យសោះឡើយ ។

ដោយអាស្រ័យហេតុនេះហើយ បានជាព្រះសម្មាសម្ពុទ្ធទ្រង់បានបង្ហាត់បង្រៀនទាក់ទងដល់សេដ្ឋកិច្ច និងសីលធម៌ ដូចបានពោលមកនេះ ។ យើងអាចឆ្លើយនូវបញ្ហាដែលបុគ្គលមួយចំនួនបានពោលចោទថា ព្រះពុទ្ធសាសនាបង្រៀនឲ្យមនុស្សខ្ជិល ឲ្យរស់នៅដោយអាស្រ័យជំនួយទេវតា

ឲ្យដេកផ្សងព្រេងសំណាង ។ល។ ព្រះពុទ្ធសាសនាមិនបានបង្រៀនយ៉ាងនេះទេ សូម្បីត្រឹមតែមួយម៉ាត់ ក៏គ្មានផង ។ ក្រៃលែងជាងនេះ ព្រះពុទ្ធបរមគ្រូ ព្រះអង្គបានសម្ដែងអំពីធម្មសម្បត្តិ ក្នុងការប្រកបអាជីវកម្មប្រភេទខ្លះ ដូចការលក់ដូរ ដោយបានបញ្ជាក់យ៉ាងច្បាស់លាស់ថា អ្នកលក់ដូរ ប្រសិនបើខ្លួនគេបានប្រកបដោយធម្មសម្បត្តិ ៣ប្រការ គេមុខជានឹងមានកម្រៃយ៉ាងខ្ពស់ជាមិនខាន ។

ធម្មសម្បត្តិ ៣ ប្រការគឺ

១. គេជាបុគ្គលមានភ្នែកល្អ ឬភ្នែកភ្លឺ ៖ សំដៅយកសេចក្ដីចេះដឹងបិនប្រសប់ក្នុងមុខរបរជំនួញ ស្គាល់ដើមទុន ស្គាល់កម្រៃ ជាពិសេសចេះក្បួនសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

២. គេជាបុគ្គលមានសេចក្ដីព្យាយាមយ៉ាងមោះមុត ៖ សំដៅយកខំយ៉ាងទូលំទូលាយ ចេះស្ទង់ ចេះពិចារណា ចេះពិនិត្យកាលៈទេសៈ ។ មានគំនិតបច្ចេកទេស មានសេចក្ដីវៃឆ្លាត ក្រៅតម្រា ដឹងកិច្ច ដឹងកល ដូចជាដឹងថា ទៅទិញរបស់នៅកន្លែងណាមានតម្លៃថោក យកទៅលក់នៅផ្សារណាមានតម្លៃខ្ពស់ ជាពិសេសបើបានចំណេញច្រើន គេក៏មិនភ្លេចស្មារតី ខាតដើមទុនគេមិនសុខចិត្តលះបង់ចោល ឬរាងចាល ។

៣. គេជាបុគ្គលមានមនុស្សនិយមរាប់អានច្រើន គឺគេសម្បូណ៌មិត្តសម្លាញ់ ស្គាល់របៀបធ្វើខ្លួន ឲ្យជាមនុស្សគ្រប់មជ្ឈដ្ឋានទូទៅបាក់ចិត្តនិយមមានជំនឿ មានសេចក្តីទុកចិត្ត ទុកថ្លើមរហូតដល់ស៊ូខាត ស៊ូចំណេញជាមួយគ្នាទៀតផង ។

ការងារក្នុងទីនេះ ព្រះអង្គទ្រង់សំដៅដល់ការធ្វើទាំងផ្លូវកាយ ផ្លូវវាចា និងផ្លូវចិត្ត គឺកាយកម្ម វចីកម្ម និងមនោកម្ម ដែលមិនមានទោស មិនប្រព្រឹត្តទៅដើម្បីបៀតបៀនខ្លួនឯង និងអ្នកដទៃឡើយ ថែមទាំងជាគុណប្រយោជន៍ដល់ខ្លួនឯងនិងដល់អ្នកដទៃទាំងឡាយទៀតផង ។ ផលរបស់ការងារអាចស្ថិតនៅបានអស់រយឆ្នាំ ពាន់ឆ្នាំ សម្រេចជាប្រយោជន៍ដល់អ្នកក្រោយអស់កាលជាអង្វែង ។

យើងត្រូវចាប់យកសេចក្តីអំពីព្រះពុទ្ធដីកាថា៖ ការធ្វើនូវការងារដែលប្រាសចាកទោស ដោយកាយក្តី ដោយវាចាក្តី និងដោយចិត្តក្តី គឺមិនប្រព្រឹត្តទៅដើម្បីទុក្ខទេ មានតែប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងសេចក្តីសុខចម្រើនដល់ខ្លួនឯង និងអ្នកដទៃប៉ុណ្ណោះ ។ បើជាការងារដ៏ប្រសើរ អ្នកប្រកបនូវការងានោះ ក៏រមែងជាអ្នកប្រសើរទៅផងដែរ ។

មនុស្សយើងបានទៅជាអ្នកប្រសើរ ឬបានទៅជាអ្នកថោកទាប ក៏មកអំពីការងារដែលខ្លួនបានប្រព្រឹត្តធ្វើនោះឯង ដូចព្រះពុទ្ធអង្គទ្រង់ត្រាស់

ថា "បុគ្គលថោកទាប ឬប្រសើរខ្ពង់ខ្ពស់ ព្រោះជាតិត្រកូលនោះគឺពុំមែនឡើយ តាមពិតបុគ្គលដែលថោកទាប ឬប្រសើរខ្ពង់ខ្ពស់ ក៏ព្រោះមកអំពីការធ្វើរបស់ខ្លួនឯង" ។

ព្រោះហេតុដូច្នោះ មនុស្សយើងត្រូវតែមានជំនឿលើខ្លួនឯងឲ្យមាំទាំ ត្រូវយល់ឲ្យបានច្បាស់ថា ការងារគឺជារបស់ដ៏សំខាន់ក្នុងជីវិតមនុស្ស ។ យើងត្រូវជឿនៅលើការងារដែលយើងធ្វើ កុំជាមនុស្សទន់ខ្សោយ បណ្តោយខ្លួនតាមជោគវាសនា ឬគិតថាជាព្រហ្មលិខិតឲ្យសោះ ត្រូវប្រឹងប្រែងធ្វើការងារឲ្យបានល្អតទៅទៀត ទោះជាមានឧបសគ្គ ឬវិបត្តិក្នុងជីវិតយ៉ាងណាក៏ដោយ ។ ការងារល្អជាកុសលដែលយើងប្រឹងប្រែងធ្វើជាប់ជានិច្ចនោះនឹងបានជាមិត្តសម្លាញ់ ចិត្តមួយថ្លើមមួយរបស់យើង រួចហើយជួយឲ្យចិត្តយើងបាននូវសេចក្តីស្ងប់ ។ កាលណាចិត្តស្ងប់ហើយ ពន្លឺភ្លឺស្វាងក៏កើតមានក្នុងចិត្ត ពេលនោះ សេចក្តីពិតក៏បានប្រាកដឲ្យដឹងគ្រប់យ៉ាងថាអ្វីជាអ្វី ។ កាលបើសេចក្តីពិតប្រាកដឲ្យដឹងហើយសេចក្តីសុខចិត្តក៏បានចេញមកសម្តែងខ្លួន ដើរតួយ៉ាងសំខាន់ក្នុងជីវិត កម្ចាត់នូវតួអាក្រក់គឺតណ្ហាដែលនាំមកនូវការមិនសុខចិត្ត ។

សូមចងចាំ "គ្រឿងវាស់មនុស្សដែលពិតប្រាកដ គឺផលនៃការងារ" ។

៥. សីលធម៌គ្រួសារ

ការរស់នៅជាក្រុមឬជាពួក គឺជារឿងដែលមិនអាចចៀសផុតបាន ក្នុងនោះយើងសង្កេតឃើញក្រុម ពួក ឬគ្រួសារមួយចំនួនជួបនឹងរឿងរ៉ាវទំនាស់ទែង ប្រើអំពើហិង្សា បែកបាក់គ្នា គួរឲ្យភ័យខ្លាចជាទីបំផុត ។ ប៉ុន្តែបើយើងក្រឡេកមើលពីបំណងប្រាថ្នារបស់ក្រុមគ្រួសារនោះ សុទ្ធតែចង់បានសេចក្ដីសុខ ការយល់ចិត្ត ការមិនប្រើអំពើហិង្សា ការសន្ដោសប្រណីការគោរពស្រលាញ់ពីសមាជិកគ្រប់រូប ការគោរពសិទ្ធិគ្នាទៅវិញទៅមក ការឲ្យតម្លៃគ្នា ដើម្បីបាននូវសុភមង្គលក្នុងក្រុមគ្រួសារ ។ ដោយមានបំណងប្រាថ្នាទាំងនេះហើយ ទើបអត្ថបទគុណធម៌នីមួយៗក្នុងជំពូកនេះ បានបង្ហាញផ្លូវដ៏ល្អដើម្បីឲ្យសម្រេចបាននូវបំណងប្រាថ្នា សេចក្ដីសុខសុភមង្គលហើយចៀសវាងនូវចំណុចអវិជ្ជមានទាំងឡាយ ដែលជាហេតុបំផ្លាញក្ដីសុខនៅក្នុងគ្រួសារនោះ ។ សូមសមាជិកគ្រប់រូបពិនិត្យខ្លឹមសារគុណធម៌នីមួយៗដូចខាងក្រោមនេះ ៖

១~ សមាជិកគ្រួសារគប្បីមានចិត្តស្រលាញ់ និង ឈ្វេងយល់រវាងគ្នានិងគ្នា គោរពមតិគ្នាទៅវិញទៅមកនៃសមាសភាពក្នុងគ្រួសារនីមួយៗ (បងប្អូន) ចេះស្រលាញ់ និងគោរពគ្នា យកចិត្តទុកដាក់គ្នា ទោះមានពេលខ្លះ ខ្វែងគំនិតគ្នាក៏ដោយក៏ត្រូវឈ្វេងយល់ចិត្ត តាំងចិត្តអំណត់រក្សានូវក្ដីសុខសប្បាយក្នុងគ្រួសារយ៉ាងនេះ ទើបល្អប្រពៃ ព្រោះថាគ្រួសារដែល

ប្រកបដោយសុខដុមរមនា គឺស្ថិតនៅលើចិត្តមេត្តា ។ មេត្តាធម៌ សាងសុខក្នុងគ្រួសារ និងសន្តិភាពក្នុងលោក ។

២. សមាជិកគ្រួសារគប្បីប្រើគំនិតឆ្លុះមើលឲ្យវែងឆ្ងាយ បើក្លាយជាគ្រួសារហើយ គឺគប្បីជាអ្នកផ្តល់ចំណេះដឹង ជំនាញឥរិយាបថល្អ និងកិត្តិនាមទៅឲ្យកូនចៅជំនាន់ក្រោយ ។ ណែនាំកូនចៅឲ្យស្គាល់ពីសាសនា ត្រូវត្រង់ពី "បរមត្ថធម៌" ដែលខ្លួនកំពុងប្រតិបត្តិ ។ បង្ហាត់បង្ហាញឲ្យសមាជិកគ្រប់រូបយល់ច្បាស់ពីសិទ្ធិអំណាចនានា សេចក្តីសម្រេចចិត្តរបៀបរបបដឹកនាំភក្តីភាពចំពោះសមាជិកគ្រួសារ ព្រោះការធ្វើរបៀបនេះ ដើម្បីឲ្យគេយកទៅចូលរួមក្នុងសកម្មភាពនយោបាយរបស់សង្គម ។

៣. សមាជិកគ្រួសារ បើទទួលភារៈជាមេផ្ទះឬអ្នកគ្រប់គ្រងផ្ទះ គប្បីជាបុគ្គលឆ្លាតមិនត្រូវចងការងារ ឬប្រមូលកិច្ចការទាំងតូចធំក្នុងផ្ទះទុកសម្រាប់តែខ្លួនឯង ដោយចំពោះអ្នកណាៗធ្វើមិនត្រូវចិត្តនោះទេ ។ គួរបង្រៀនដល់អ្នកដែលគួរបង្រៀន ដូចជាកូនៗជាដើមឲ្យចេះដឹង ដើម្បីទទួលភារៈធ្វើនូវកិច្ចការនោះៗជំនួសខ្លួនទើបប្រពៃ ។ ដូច្នេះ ទើបរួចពីការរអ៊ូរទាំនិងនិយាយច្រំដែលៗទៀតផង ។

៤. សមាជិកគ្រួសារគប្បីខិតខំចិញ្ចឹមបីបាច់ថែរក្សាកូនឲ្យមានសុខភាពល្អកម្លាំងមាំមួន និងអប់រំកូនឲ្យប្រព្រឹត្តតែអំពើល្អស្គាល់អ្វីដែលល្អឬអាក្រក់

ខុសឬត្រូវ ចេះគោរព និងស្តាប់ដំបូន្មានចាស់ព្រឹទ្ធាចារ្យ ព្រោះការធ្វើបែបនេះ កូននឹងក្លាយខ្លួនទៅជាកូនល្អ មិត្តល្អ និងពលរដ្ឋល្អ ។

៥. សមាជិកគ្រួសារ(បុត្រធីតា)គប្បីខំប្រឹងប្រែងសិក្សារៀនសូត្រ ដើម្បីជីវិតខ្លួនឯងផ្ទាល់ ក៏ដូចជាជីវិតនៃគ្រួសារដែរ ព្រោះឪពុកម្តាយសប្បាយចិត្តណាស់ពេលបានឮថាកូនជាមនុស្សល្អមានសេចក្តីអត់ធន់ចេះតស៊ូចំពោះការងារ និងការសិក្សារៀនសូត្រចេះគិតដល់អនាគតនៃជីវិតខ្លួនឯងមិនបោះបង់ខ្លួនឯងចោល ។

៦. សមាជិកគ្រួសារគប្បីចេះគ្រប់គ្រងគ្រួសារឲ្យបានល្អជាមុនសិន ថាបើជាអ្នកចង់គ្រប់គ្រងប្រទេសជាតិឲ្យបានល្អប្រពៃនោះ ។ រីឯគន្លឹះនៃវិធីគ្រប់គ្រងគ្រួសារ គឺស្ថិតនៅលើការទូន្មានឲ្យកូនចៅមានកតញ្ញូតាធម៌ ព្រោះ "ធម៌កតញ្ញូជាឫសកែវនៃសេចក្តីស្មោះស្ម័គ្រ" ក៏ដូចជាឫសកែវនៃសីលធម៌ដែរ ។

៧. សមាជិកគ្រួសារគប្បីចាយវាយទ្រព្យសម្បត្តិដែលបានមកពីការងារប្រាសចាកទោសដោយសេចក្តីមិនប្រមាថ ត្រូវចិញ្ចឹមជីវិតខ្លួនដែរ ចិញ្ចឹមមាតាបិតា បុត្រភរិយា ទាសកម្មករ អ្នកដែលមកអាស្រ័យជាមួយនឹងញាតិមិត្ត ឬអ្នកដទៃណាៗដែលខ្លួនសមគួរនឹងចិញ្ចឹមឲ្យបានឆ្អែតរស់នៅជាសុខសាន្ត ។

៨. សមាជិកគ្រួសារគប្បីខិតខំឧស្សាហ៍ដឹកនាំពន្យល់ហេតុផលផ្សេងៗដល់បុត្រធីតា ឲ្យមានការប្រព្រឹត្តនូវអំពើល្អឲ្យមានការចេះដឹងកុំឲ្យមាននូវសេចក្តីសង្ស័យឡើយ ។ នេះជាកិច្ចមួយដ៏សំខាន់ សម្រាប់អ្នកប្រាថ្នានូវប្រយោជន៍ឲ្យដល់អ្នកដទៃបានសេចក្តីសុខ ព្រោះសេចក្តីសុខមិនមែនកើតឡើងដោយរស់នៅតែម្នាក់ឯងនោះទេ ។

៩. សមាជិកគ្រួសារគប្បីញុំាងសេចក្តីស្រលាញ់និងបណ្តុះភាពស្មោះស្ម័គ្ររួបរួមចិត្តគំនិតគ្នា គោរពសិទ្ធិគ្នាទៅវិញទៅមកផ្តល់ភាពកក់ក្តៅដល់គ្នានិងគ្នាក្នុងគ្រួសារ ។ បើមានភារៈទទួលបន្ទុកគ្រួសារហើយនោះ ទើបកូនប្រុសស្រីបានភាពកក់ក្តៅក្នុងជីវិត គឺថាបានភាពសុខសាន្តសម្រាប់កូនៗក្នុងអនាគតដ៏រុងរឿង ។

១០. សមាជិកគ្រួសារគប្បីអប់រំណែនាំអំពីសុខភាពនិងផ្តល់អាហារូបត្ថម្ភសម្រាប់ស្ត្រីមានគភ៌ ទារក និងកុមារ ហើយត្រូវលើកតម្កើងការបំបៅកូនដោយទឹកដោះម្តាយ ព្រោះការធ្វើរបៀបនេះ ជាវិធីដ៏ល្អសម្រាប់ការរស់រានមានជីវិតរបស់ទារក ។

១១. សមាជិកគ្រួសារគប្បីរៀបចំទីដេក ទីអង្គុយ ជូនមាតាបិតាឲ្យបានសមរម្យ ហើយមើលថែរក្សាបោសសម្អាតបោកគក់ មុង កន្ទេល ពូក ខ្នើយ ភួយ សម្លៀកបំពាក់ និងដេញស្រមោច ស្រមើល សង្កើច មូស រុយជាដើម ឲ្យបានស្អាតជានិច្ច ។ ធ្វើយ៉ាងណាកុំធ្វេសប្រហែស

បណ្ដោយឲ្យសម្លៀកបំពាក់មុងភួយខ្នើយមាតាបិតាប្រឡាក់ក្អែល និង ទឹកមាត់ស្លាកខ្វក់ឡើងពណ៌ដូចខ្មុកម្រ័ក្សណ៍ ព្រោះលោកចាស់ងងឹត មើលមិនឃើញ គ្មានកម្លាំងបោកគក់ ។

១២. សមាជិកគ្រួសារ បើអ្នកជាប្ដីគប្បីឲ្យកិត្តិយសដល់ប្រពន្ធរបស់ខ្លួន ព្រោះការឲ្យកិត្តិយសដល់ប្រពន្ធរបស់ខ្លួននេះឯង ឈ្មោះថាការផ្ដល់នូវសិទ្ធិ និងឱកាសដោយការគោរពស្រលាញ់ដល់ស្ត្រី ។

១៣. សមាជិកគ្រួសារ គប្បីធ្វើគម្រោងផែនការក្នុងការរៀបចំអាហារប្រចាំថ្ងៃ សម្រាប់គ្រួសារដែលត្រូវតែមានការយកចិត្តទុកដាក់ក្នុងការផ្គត់ផ្គង់អាហារ ដែលមានសារធាតុចិញ្ចឹមឲ្យបានគ្រប់គ្រាន់ដើម្បីជាទីសប្បាយរីករាយក្នុងគ្រួសារ ។

១៤. សមាជិកគ្រួសារ(បុត្រធីតា) គប្បីខិតខំរៀនសូត្រស្ដាប់ការទូន្មានរបស់ឪពុកម្ដាយ ជួយធ្វើកិច្ចការផ្ទះ សាលារៀន ឬសហគមន៍ មិនឈ្លោះប្រកែកគ្នាទេ ។ ត្រូវតែចេះយោគយល់អធ្យាស្រ័យឲ្យគ្នាទៅវិញទៅមក ដើម្បីញុំាងហឫទ័យនៃមាតាបិតា ឬសមាជិកគ្រួសារទទួលបាននូវភាពសប្បាយរីករាយ ។

១៥. សមាជិកគ្រួសារគប្បីបំពេញភារកិច្ចរបស់ខ្លួនឲ្យបានសម្រេចតាមការណែនាំរបស់មេគ្រួសារ ។ ក្នុងករណីខ្លះ គួរបញ្ចេញមតិយោបល់ជួយបំពេញចំណុចខ្វះខាតរបស់អាណាព្យាបាលដើម្បីការរីកចម្រើនដល់

គ្រួសារ ។ បើជាមេគ្រួសារវិញ ចាំបាច់ធ្វើយ៉ាងណាឲ្យសមាជិកគ្រួសារ មានសាមគ្គីរវាងគ្នានិងគ្នា ចេះស្តាប់និងប្តូរយោបល់គ្នាទៅវិញទៅមក ដើម្បីឈានទៅរកភាពរីកចម្រើន ។

១៦. សមាជិកគ្រួសារគប្បីមានស្មារតីប្រយ័ត្នប្រឹងប្រែងអនុវត្តតាមការណែនាំរបស់អាណាព្យាបាល ធ្វើឲ្យបានសម្រេចរាល់ភារកិច្ចដែលខ្លួនទទួលពីសាលានិងគ្រួសារ ដើម្បីអនាគតផ្ទាល់ខ្លួន និងដើម្បីបំពេញបំណងដ៏ល្អរបស់មាតាបិតា ព្រមទាំងសង្គមជាតិផងដែរ ។ ត្រូវចេះស្តាយពេលវេលាដែលកន្លងផុត ព្រោះវាមិនអាចត្រឡប់ក្រោយវិញបានឡើយ ។

១៧. សមាជិកគ្រួសារគប្បីចូលរួមចំណែកក្នុងការបង្កើនសេចក្តីស្រលាញ់គ្រួសារ ដោយចេះយោគយល់អធ្យាស្រ័យគ្នា ធ្វើយ៉ាងណាឲ្យគ្រួសារមានសុភមង្គលមានសាមគ្គីភាព ចូលរួមសហការក្នុងការងារគ្រួសារ ដើម្បីរកប្រាក់ចំណូលក្នុងគ្រួសារ មានអត្តចរិត អាកប្បកិរិយា សម្តីសុភាពរាបសាចំពោះគ្នាទៅវិញទៅមកព្រមជាមួយនឹងអ្នកដទៃផងដែរ ។

១៨. សមាជិកគ្រួសារគប្បីដឹងថា អ្នកមានតួនាទីជាមាតាបិតាលើកូនប្រុសស្រី ចំពោះគេហដ្ឋាន គប្បីលៃលកឲ្យមានតុកៅអី ។ បើមិនអាចបានទេ ឲ្យមានតែកន្លែងពិសេសមួយ ដែលមានពន្លឺច្បាស់ល្អឲ្យឃ្លាត ពីកន្លែងទទួលភ្ញៀវ ហើយរៀបចំឲ្យមានសិក្ខូបករណ៍សព្វគ្រប់មាន

សៀវភៅសរសេរ សៀវភៅអាន ដងប៉ាកកា ទឹកខ្មៅ ទឹកហ្វឺត ក្ដារខៀន ដីសជាដើម គប្បីកំណត់ពេលរៀន ពេលដេក ពេលលេងរបស់កូនឲ្យទៀងទាត់ ។ បើកូនមិនយល់ត្រូវជួយពន្យល់ណែនាំឲ្យបានយល់ច្បាស់លាស់គ្រប់មុខវិជ្ជាដែលកូនរៀន ។ ជាពិសេស បើខ្លួនជាមាតាបិតា មិនចេះឬមានភារៈរវល់ច្រើនមិនអាចមានពេលជួយបង្រៀនកូនបានទេ គប្បីពឹងពាក់អ្នកដទៃដែលចេះដឹងហើយសន្ដានចិត្តសប្បុរសទៀតឲ្យគេជួយបង្រៀន បើមានទ្រព្យអាចជួលគ្រូបានត្រូវតែជួលបង្រៀននៅផ្ទះថែមទៀតនៅពេលយប់ឬពេល ដែលកូនមិនបានទៅសាលា នោះទើបជាផ្លូវដ៏សមគួរសម្រាប់ខ្លួនជាមាតាបិតា ។

១៩. សមាជិកគ្រួសារ(ស្វាមី)គប្បីជាស្វាមីដ៏ល្អ គឺត្រូវមានពាក្យសម្ដីល្អទន់ផ្អែមទៅរកនាងជាភរិយាមិនត្រូវនិយាយសម្លុត គំហក កំហែង ជេរបញ្ឆោរ ឬវាយទាត់ធាក់ក្នុងពេលដែលថ្នាំងថ្នាក់ចិត្ត ទាស់អព្យាស្រ័យនោះឡើយ ។ ស្វាមីដ៏ល្អ មិនមែនជាស្វាមីដែលវាយទាត់ធាក់ភរិយាទេ តែជាស្វាមីដែលចេះមើលការខុសត្រូវក្រុមគ្រួសារ ។

២០. សមាជិកគ្រួសារ(ភរិយា)គប្បីជាភរិយាដ៏ល្អ គឺត្រូវរាប់អាន សង្គ្រោះដល់ញាតិរបស់ខ្លួន និងញាតិស្វាមី ដោយការរាក់ទាក់ស្មោះស្មើ មិនគប្បីលំអៀងម្ខាងៗ ទោះបីជាញាតិនោះខ្ពង់ខ្ពស់ក៏ដោយថោកទាបក៏ដោយ

។ ភរិយាដ៏ល្អ គឺជាភរិយាដែលចេះរៀបចំចាត់ចែងគ្រួសារ និងមិនប្រកាន់ឫកខ្លួនចំពោះញាតិខាងណាមួយឡើយ ។

២១. សមាជិកគ្រួសារប្រព្រឹត្តដោយប្រុងប្រយ័ត្នថាបើភ្ញៀវកំពុងមាននៅក្នុងផ្ទះ មិនត្រូវបញ្ចេញអាការៈអាក្រក់ដោយហេតុផ្សេងៗ ជាបច្ច័យប៉ះពាល់ដល់អារម្មណ៍អ្នកដទៃ គឺថា មិនត្រូវឈ្លោះប្ដីប្រពន្ធ ឬជេរវាយ កូនចៅ ស្ដីបន្ទោសទាសកម្មករជាដើម ឲ្យរំខានចិត្តភ្ញៀវ ក៏ព្រោះតែខ្លួននោះទេ ទោះជាមានហេតុយ៉ាងណាត្រូវអត់ទ្រាំឲ្យភ្ញៀវចេញទៅផុតសិន ។ ម៉្យាងទៀត ថាបើភ្ញៀវកំពុងមាននៅក្នុងផ្ទះគាប់ជួនឬចៃដន្យ មានជនណាមួយធ្វើឲ្យប៉ះទង្គិចធ្លាក់បែកបាក់ចានឆ្នាំងកែវជាដើម មិនត្រូវសម្ដែងអាការៈសោកស្ដាយស្ដីបន្ទោសគ្នីគ្នាទេ ទោះបីស្ដាយយ៉ាងណា ក៏ត្រូវមានអាការៈស្រស់ស្រាយដូចជាគ្មានចាប់អារម្មណ៍នឹងវត្ថុទាំងនោះ ។ ផ្ទុយទៅវិញ ត្រូវនិយាយបន្ធូរបរិយាកាស កុំឲ្យភ្ញៀវរំខានចិត្តមាននិយាយថា "របស់ទ្រព្យវាតែងតែបែកបាក់ខូចដូច្នេះឯង បើគ្មានការបែកបាក់ខូចទេ អ្នកធ្វើលក់ក៏គ្មានដែរ" ប៉ុណ្ណោះជាដើម ។

២២. សមាជិកគ្រួសារគប្បីដឹងថា មុននឹងអង្គុយក្នុងផ្ទះគេ ចាំម្ចាស់គេបង្ហាញអាសនៈសិន បើផ្ទះគេមានអាសនៈច្រើន បែបដូចជាកៅអី ក្ដារឿជាដើម ។ កុំចេះតែអង្គុយផ្ដេសផ្ដាសតាមចិត្តខ្លួននាំឲ្យខុសរបៀប ឬធ្វើឲ្យអាប់កិត្តិយសដល់ខ្លួន ។

២៣. សមាជិកគ្រួសារ គប្បីរក្សាចិត្តឲ្យនឹងធឹងប្រឹងទប់អារម្មណ៍ផ្ទង់ស្មារតីឲ្យបានល្អ បើឃើញរបៀបក្នុងផ្ទះគេមិនរៀបរយបណ្ដាលជាហេតុនាំឲ្យទាស់ភ្នែកដាច់ខាតកុំនិយាយ ឬថាកុំប្រើកិរិយាសម្លឹងញយៗថែមទាំងកុំនាំរឿងរ៉ាវថាផ្ទះអ្នកនេះ ផ្ទះអ្នកនោះគ្មានសណ្ដាប់ធ្នាប់មិនចេះរៀបចំជាដើមព្រោះអំពើទាំងនេះបណ្ដាលឲ្យម្ចាស់ផ្ទះកើតសេចក្ដីអៀនខ្មាសរង្កៀសចិត្តដោយសារខ្លួនតែប៉ុណ្ណោះ ។

២៤. សមាជិកគ្រួសារគប្បីត្រៀមលក្ខណៈដោយប្រុងប្រយ័ត្នជានិច្ចក្នុងពេលទៅផ្ទះគេ បើយកកូនឬទៅជាមួយចៅនោះ ក្រោយដែលខ្លួនសំពះឬចាប់ដៃគួរសមហើយ ត្រូវលៃលកយ៉ាងណានាំកូនឲ្យសំពះជម្រាបសួរជននោះផង ។ ម៉្យាងទៀត បើកូនចៅមិនស្គាល់ជននោះ ត្រូវរកគន្លឹះឬមធ្យោបាយប្រាប់ដល់កូនចៅថា នេះមា នេះមីងជាដើម ។ ធ្វើដូច្នោះរួចហើយឲ្យកូនចៅអង្គុយយ៉ាងសុភាពស្ងៀមស្ងាត់ក្បែរខ្លួនចៀសវាងកុំបណ្ដែតបណ្ដោយឲ្យរុះរើរបស់ទ្រព្យក្នុងផ្ទះគេ បើកូនចៅនោះ ធ្វើខុសឆ្គងបន្តិចបន្តួចនោះវិញ មិនគួរស្ដីបន្ទោសទះតប់ចំពោះមុខម្ចាស់ផ្ទះគេដូច្នោះទេ ។ ផ្ទុយទៅវិញ គួរគប្បីនិយាយសម្រួលឲ្យស្រួល ហើយលៃលកនិងឆាប់នាំកូនចៅលាគេមកផ្ទះវិញនោះ ទើបជាការល្អប្រពៃ ។

២៥. សមាជិកគ្រួសារគប្បីធ្វើឲ្យបានប្រសើរបើមានតួនាទីជាបងនៃប្អូនណាមួយ ត្រូវចេះស្រលាញ់រាប់អានប្អូនដោយភាពស្មោះត្រង់ មិនត្រូវ

ច្រណែនឈ្នានីសកំណាញ់កិបកេងតែប្រយោជន៍ផ្ទាល់ខ្លួនដូច្នោះទេ ព្រោះយើងសុទ្ធតែជាអ្នកកើតមកពីផ្ទៃតែមួយ មានជាតិលោហិតតែមួយដូចគ្នា ។ បើគ្រឿងឧបភោគបរិភោគត្រូវចែករំលែកឲ្យប្អូនបានបរិភោគប្រើប្រាស់ផង និងចេះជួយផ្គត់ផ្គង់ដល់ប្អូនឲ្យរៀនចំណេះវិជ្ជាឲ្យបានកើតជាពលរដ្ឋចេះដឹងមានសមត្ថភាពគ្រប់គ្រាន់ ម្យ៉ាងទៀត វេលាដល់ប្អូនមានស្វាមីភរិយាគួរតែចែកដើមទុនថែមទៀត តាមសមត្ថភាពរបស់ខ្លួន ដែលគួរលែលកចែកបាននោះ ទើបជាការគួរ ។

២៦. សមាជិកគ្រួសារគប្បីមានពាក្យសម្ដីល្អ ទឹកមុខរីករាយប្រកបដោយមេត្តា ករុណាចំពោះប្អូន កុំប្រើអំណាចរបស់ខ្លួនជាបង សម្លុតគំហកកំហែង ជេរបញ្ឆោរ ហៅអាម៉ឹងដាច់សាច់យ៉ាងដូច្នោះទេ ។ ផ្ទុយទៅវិញគួរលែលកហៅថា ប្អូន អូន លោកប្អូន ចីប្អូន ឬចីអូន នាង ស្រីអូន ឬក៏ហៅចំឈ្មោះថា ប្អូនសៃ ប្អូននាង ប្អូនស៊ាន ប្អូនហេនដូច្នេះជាដើម ។ មួយវិញទៀត បើមានប្អូនត្រឹមតែពីរបីនាក់គួរតែហៅថា ប្អូនប្រុស ប្អូនស្រី ឬបងប្រុស បងស្រីដូច្នេះ គ៏ជាការល្អប្រពៃសមរម្យម៉្យាងដែរ ។

២៧. សមាជិកគ្រួសារគប្បីជួយយកអាសាផ្ដល់ប្រយោជន៍ឲ្យប្អូនគឺជួយកិច្ចការផ្សេងៗ ដូចជាមានជួយបង្ហាត់បង្រៀននិយាយប្រាប់ហេតុផលឲ្យស្គាល់ខុសត្រូវ ល្អអាក្រក់ជាដើម តាមសមត្ថភាពខ្លួន ឲ្យប្អូនទទួលបានផលប្រយោជន៍សុខចម្រើនពីខ្លួនទើបសមគួរ ។

២៨. សមាជិកគ្រួសារគប្បីរាប់អានប្អូនដោយភាពស្មោះស្មើ សម្គាល់ថាជាប្អូនរបស់ខ្លួនបង្កើតមិនប្រកាន់ទោសពៃរ៍មើលបំណាំផ្គន្ធាផ្ទាញ់ផ្ទាលឲ្យវិនាសអន្តរាយដោយហេតុណាមួយនោះឡើយ ។ បើប្អូនប្រព្រឹត្តខុសឆ្គងមកលើខ្លួន ត្រូវតែលុបលាងទោសចោលកុំចងគំនុំចងកំហឹងចំពោះប្អូនឲ្យសោះនោះទើបប្រពៃ ។

២៩. សមាជិកគ្រួសារគប្បីតាំងចិត្តធ្វើឲ្យគាប់ប្រសើរថាបើមានតួនាទីជាប្អូនត្រូវស្រលាញ់រាប់អានបង ដោយសន្តានចិត្តស្មោះត្រង់ មិនច្រណែនឈ្នានីស កំណាញ់គិតតែប្រយោជន៍ផ្ទាល់ខ្លួនយ៉ាងដូច្នោះទេ ។ បើមានគ្រឿងឧបភោគបរិភោគ ដូចជាបាយទឹកនំចំណី សម្លៀកបំពាក់ជាដើម ត្រូវចែកជូនដល់រូបបងតាមសមត្ថភាពរបស់ខ្លួន ។ ម្យ៉ាងទៀត បើបងជាអ្នកទ័លក្រហើយខ្លួនជាអ្នកមានត្រូវតែជួយទំនុកបម្រុងបងកុំបីខាន ទោះតិចក្តី ច្រើនក្តី ដើម្បីឃឹតយោងបងកុំឲ្យរហេមរហាមដុនដាបជាងខ្លួនពេក នោះទើបជាការប្រសើរ ។

៣០. សមាជិកគ្រួសារគប្បីមានកាយវិការនិងពាក្យសម្តីសុភាពទន់ភ្លន់គោរពចំពោះបង កុំវាយឫកស្មើនឹងបង មានសភាពហាក់ដូចជាពួកម៉ាក ឬ មានហៅ អានេះ អានោះ មីនេះ មីនោះ ឬហៅតាមរូបភាពរបស់បងថា អាសម្គម មីសម្គម អាម៉ាប់ មីកន្ទាត់ជាដើម ដែលជាពាក្យព្រហើនឥតគួរសមដោយប្រការយ៉ាងនេះទេ ។ ផ្ទុយទៅវិញ ត្រូវទម្លាប់ហៅពាក្យ

ថា បង អ្នកបង ចីបង ឬក៏ហៅថាបងប្រុស បងស្រី ដូច្នោះក៏គួរសមម្យ៉ាងដែរ(បើមានបងប្អូនតិចមិនច្រឡំគ្នា) ដែលពិសេសបងប្អូនប្រុសស្រីមិនត្រូវនិយាយអ្វីៗដែលនាំឲ្យកើតការអៀនខ្មាសរវាងភេទនិងភេទទេ ។

៣១. សមាជិកគ្រួសារគប្បីជួយធ្វើប្រយោជន៍ឲ្យបងមានជួយហុចនេះហុចនោះ ឬទៅទិញអ្វីៗតាមដែលបងប្រើនិងជួយកិច្ចធុរៈរបស់បងមានជួយធ្វើការងារផ្សេងៗ ដែលខ្លួនអាចជួយបានកុំខ្ជិលច្រអូស កុំគិតតែទារថ្លៃឈ្នួលរង្វាន់អ្វីពីបង គឺត្រូវជួយផ្ដល់ផលប្រយោជន៍ឲ្យបងពិតៗឥតគិតនឹកនាអ្វីសោះឡើយ ។

៣២. សមាជិកគ្រួសារគប្បីរាប់អានបងស្មោះស្មើអស់ពីចិត្តថ្លើមដោយសម្គាល់ថាជាបងបង្កើតរួមឧទរ(គឺពោះ)ជាមួយនឹងខ្លួន មិនត្រូវបៀតបៀនប្រកាន់ខឹងចងគំនុំគុំគួនព្យាបាទប្រមាថមើលងាយទោះបីបងបានប្រព្រឹត្តខុសឆ្គាំឆ្គងជះឥទ្ធិពលមិនសមរម្យមកលើខ្លួន ទោះបីជាទ័លក្រគ្មានបុណ្យសក្តិក៏ដោយ សូមរាប់អានគោរពក្នុងឋានៈជាបងរបស់ខ្លួនជាដរាប ។

៣៣. សមាជិកគ្រួសារគប្បីព្យាយាមធ្វើខ្លួនឲ្យប្រសើរ បើជាអ្នកមានទ្រព្យសម្បត្តិច្រើនត្រូវតម្កល់ខ្លួនប្រកបដោយសុជីវធម៌ គឺរស់នៅក៏ឲ្យគាប់ងាប់ទៅក៏ឲ្យគួរ បានដល់ការចេះរកទ្រព្យ និងចេះចាយវាយទ្រព្យឲ្យសមតាមឋានៈកិត្តិយសខ្លួនដែលជាអ្នកមានទ្រព្យនិងត្រូវធ្វើបុណ្យទានចែក

រំលែកសង្គ្រោះដល់ជនដទៃកុំគិតតែពីសង្កត់កបឺតឈាមគេតាមអំណាច ទឹកប្រាក់ គឺត្រូវជួយសង្គ្រោះ ដោយគ្រឿងឧបភោគបរិភោគ រំលែកសេចក្តីសុខចែកដល់អ្នកក្រខ្សត់គ្នាបានសុខខ្លះដូចខ្លួនផងទើបជាការប្រពៃ ។

៣៤. សមាជិកគ្រួសារមិនគប្បីបរិភោគអាហារអាក្រាតខ្លួនដោយមិនពាក់អាវយ៉ាងដូច្នោះទេ ត្រូវស្លៀកពាក់ឲ្យមានខោអាវឬសារុង ប៉ុន្តែមិនត្រូវស្លៀកខោអាវណាដែលមានក្លិនឆ្អេះឆ្អាប ស្មោកគ្រោកកខ្វក់ដែលជាហេតុនាំឲ្យគេខ្ពើមរអើមនោះទេ ។

៣៥. សមាជិកគ្រួសារគប្បីរក្សាចិត្តឲ្យថ្លាស្រស់ស្រាយពេលកំពុងបរិភោគ បើមាននរណាមួយ គាប់ជួនជាអ្នកធ្វើឲ្យខុសចំពោះរឿងអ្វី ដូចជាកូនចៅវាញ៉ាំផ្តេសផ្តាសជាដើម មិនត្រូវជេរវាយទះតប់គំហកគំហែងទេ ត្រូវឲ្យបរិយាកាសល្អជានិច្ច នោះទើបប្រសើរ ។

៣៦. សមាជិកគ្រួសារគប្បីត្រៀមលក្ខណៈប្រុងប្រយ័ត្នជានិច្ច បើមានតួនាទីជាស្ត្រីមេផ្ទះ ថាបើត្រូវដើរ ឲ្យមានពេលម៉ោងទៀងទាត់ដែរ ដូចជាមានការដើរទៅរកអ្វីមួយ ត្រូវឆាប់ត្រឡប់មកវិញ កុំឲ្យហួសពេលម៉ោងចំអិនអាហារឬពេលបោកគក់សម្លៀកបំពាក់និងពេលរៀបចំផ្ទះសម្បែងជាដើម ។

៣៧. សមាជិកគ្រួសារគប្បីតាំងស្មារតីឲ្យល្អជានិច្ច បើជាមេគ្រួសារ(បុរស) បើធ្វើដំណើរទៅទីណាៗ មានទៅធ្វើការរកស៊ីជាដើម ត្រូវប្រញាប់មក

វិញឲ្យទាន់ពេលម៉ោងដែលខ្លួនបានប្រាប់គេ កុំឲ្យគេទទឹងមើលផ្លូវជាហេតុនាំឲ្យគេកើតភ័យព្រួយដោយសារខ្លួន គឺមិនត្រូវដើរផ្តេសផ្តាសតាមចិត្តឲ្យពេលវេលានោះឡើយ ។

៣៨. សមាជិកគ្រួសារគប្បីតាំងចិត្តឲ្យធ្ងន់ចំពោះបញ្ហាឲ្យបាន ។ បើចាប់ដៃគ្នាជាគូស្វាមីភរិយា បង្កើតជារង្វង់គ្រួសារហើយបើមានរឿងហេតុទាស់អធ្យាស្រ័យគ្នាក្នុងពេលដែលគេឈប់សំរាកដេកពួននោះ គប្បីអត់ទ្រាំសិន មិនត្រូវស្រែកជេរ បញ្ចោរវាយតប់កណ្តាលអធ្រាត្រឲ្យភ្ញាក់ផ្អើលអ្នកដទៃ ដែលនាំឲ្យថោកទាបខូចកិត្តិយសទេ ។

៣៩. សមាជិកគ្រួសារគប្បីធ្វើការអប់រំដោយប្រុងប្រយ័ត្ន បើស្តីបន្ទោសកូនចៅ មិនត្រូវជេរស្តី វាយប្រដៅឡូឡាក្នុងពេលគេត្រូវសម្រាកដេកពួននោះទេ ព្រោះជាហេតុញ៉ាំងឲ្យអ្នកដទៃ មិនបានសម្រាកដោយសារខ្លួន ។

៤០. សមាជិកគ្រួសារគប្បីហាត់រៀនវិធីសាងនូវភាពកក់ក្តៅ ការពេញចិត្ត និងការទុកចិត្តដោយមានជំនឿឬធ្វើទុកក្នុងចិត្តកំណត់ក្នុងអារម្មណ៍ តម្កល់ស្មារតីឬក៏ប្រើឧបាយដោយទំនង ដូច្នេះ គឺចេះលះបង់ មិនគួរឃើញតែខ្លួនឯង និយាយស្តីឲ្យល្អត្រឹមត្រូវបង្កជាប្រយោជន៍ចេះជួយទុក្ខ-ធុរៈអ្នកដទៃ ផ្តល់ជំនឿចិត្តឲ្យឃើញជាគ្នា ជាមួយមនុស្សគ្រប់គ្នា គ្រប់រូបគ្រប់ប្រភេទ គ្រប់ស្រទាប់វណ្ណៈ គ្រប់ស្ថាន មានកិរិយាមារយាទសុភាព

រាបសាររៀបរយស្លូតបូត ត្រឹមត្រូវ ទៀងត្រង់ មិនប្រកាន់ខ្លួន និងមិនអួតខ្លួនយ៉ាងនេះ ទើបបានភាពកក់ក្ដៅ ភាពពេញចិត្ត ភាពទុកចិត្ត និងការរក្សាជានិច្ចនូវសម្បត្តិមនុស្សល្អ មិនឲ្យសាបសូន្យចាកសម្បត្តិនេះឡើយ ។

៤១- សមាជិកគ្រួសារគប្បីព្យាយាមហ្វឹកហាត់អប់រំខ្លួនឯង ញ៉ាំងសេចក្ដីសុខស្ងប់ឲ្យដល់អ្នកដទៃ ធ្វើចិត្តរបស់ខ្លួនឲ្យសម្បូរទៅដោយគុណធម៌ និងមានការគ្រប់គ្រងដោយល្អ ព្រោះទង្វើទាំងអស់នេះជាបេះដូងរបស់អ្នកប្រាជ្ញ ។

៤២- សមាជិកគ្រួសារគប្បីធ្វើឲ្យជាម្លប់ដ៏ត្រជាក់ថា បើមានដំណើរជីវិតទៅតាមប្រក្រតី មិនត្រូវសាងសេចក្ដីក្ដៅក្រហាយឲ្យដល់ខ្លួនឯង និងគ្រួសារជាដើម លោកចាត់ថា ឬរាប់ថាជា "ជីវិតបានធ្វើបុណ្យរាល់ថ្ងៃ" ទៅហើយ ។

៤៣- សមាជិកគ្រួសារគប្បីធ្វើជាអាណាព្យាបាលដ៏ល្អ បើមានតួនាទីជាមាតាបិតាហើយ នោះគប្បីអប់រំកូនឲ្យចេះស្មោះត្រង់ ចេះគោរពច្បាប់ និងឲ្យក្លាយខ្លួនជាពលរដ្ឋល្អ ។

៤៤- សមាជិកគ្រួសារគប្បីញ៉ាំងវង្សត្រកូលឲ្យរុងរឿង បើមានតួនាទីជាបុត្រធីតាហើយនោះ គប្បីគោរពតាមដំបូន្មានល្អៗពីម្ដាយឪពុក មិនបង្កការលំបាកដល់លោកអ្នកមានគុណទាំងពីរធ្វើអ្វីៗគ្រប់បែបយ៉ាងដើម្បីជា

ប្រយោជន៍ដល់គ្រួសារ និងញាតិមិត្តជិតខាងព្រមទាំងជួយថែរក្សាទ្រព្យសម្បត្តិដែលម្តាយឪពុករកបានមក ដោយឧបាយមិនឲ្យធ្វេសប្រហែស ។

៤៥. សមាជិកគ្រួសារមិនគប្បីប្រព្រឹត្តល្មើសចំពោះមេថុនធម្ម ត្រូវចេះការសង្រួមក្នុងកាម ព្រោះពិចារណាទៅឲ្យឃើញថា កាមទាំងឡាយមានសេចក្តីសុខតិច តែមានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ។

៤៦. សមាជិកគ្រួសារគប្បីហាមចិត្តមិនធ្វើខ្លួនជាអ្នកទទួលតែម្យ៉ាងនោះទេ ត្រូវធ្វើខ្លួនជាអ្នកបរិច្ចាគ ពោលគឺចេះលះបង់ផង នោះទើបជាការប្រពៃពិតសម្រាប់សង្គមគ្រួសារ ។

គុណរបស់ទាន

និពន្ធដោយលោកអគ្គបណ្ឌិត ធម្មាចារ្យ ប៊ុត សាវង្ស

ទានចិញ្ចឹមបុត្របរិសុទ្ធក្នុងផ្ទៃ
រហូតដល់ថ្ងៃបុត្រថ្លៃចាកគត៌
ទានចិញ្ចឹមស្មោះទឹកដោះបវរ
កូនរស់បានល្អព្រោះធម៌សប្បុរស។
ទានថ្វាយដល់សង្ឃផ្ចង់ឧទ្ទិសទាន
ប្រេករួចពីឃ្លានព្រោះទានរំដោះ
ទានជាទេវធម៌លំអូរសប្បុរស
ទានមានចិត្តស្មោះសង្គ្រោះជីវិត ។
ទានគឺជាទ្រព្យជាប់តាមសន្តាន
ជាមិត្តរួមប្រាណឆ្លងភពងងឹត
ទានកាច់បំបាក់មោហៈក្នុងចិត្ត
បានត្រាស់ដឹងពិតដ្បិតទានបារមី។
ហៃកូនប្រុសស្រីគប្បីចាំទុក
គុណម្តាយឪពុកទានាធិបតី
កូនដឹងមង្គល ៣៨
ចៀសកម្មអប្រិយ៍ផុតភ័យអបាយ។

៤៧. សមាជិកគ្រួសារមិនគប្បីយកអំពើអាក្រក់ក្នុងត្រកូលទៅនិយាយ បរិយាយកេរ្តិ៍ប្រាប់អ្នកខាងក្រៅត្រកូល ឬយកពាក្យមិនល្អខាងក្រៅ មកប្រាប់ត្រកូលខាងក្នុង វៀរលែងតែមានហេតុ ។ សូមចងចាំថា "កុំនាំភ្លើងចេញក្រៅ និង នាំភ្លើងចូលក្នុង" ។

៤៨. សមាជិកគ្រួសារគប្បីរត់មកទទួលជួយកាន់ជួយទទួលយករបស់របរ និងសាកសួរពីការហត់នឿយផ្សេងៗចំពោះម៉ែឪក្នុងគ្រាដែលពួកគាត់អញ្ជើញមកដល់ផ្ទះហើយសម្លឹងឃើញខ្លួនជាកូនចៅ ។ ព្រោះកាលបើយើងធ្វើយ៉ាងនេះ សូម្បីមាតាបិតាធ្វើការនឿយហត់អស់កម្លាំងយ៉ាងណាក៏ដោយ ក៏លោកទាំងពីរបាត់នូវការនឿយហត់ទៅ ហើយនៅពេលឃើញមុខកូនខ្លួន ។

៤៩. សមាជិកគ្រួសារគប្បីបណ្តុះបណ្តាលនូវគុណធម៌ និង សីលធម៌ឲ្យកើតមានក្នុងខ្លួនកូន គឺក្នុងចិត្តសន្តានរបស់កូនដែលកំពុងនៅតូចៗ ព្រោះកាលបើកូនតូចមានគុណធម៌ សីលធម៌ក្នុងចិត្តសន្តានហើយ កូនទាំងនោះរមែងជាកូនកតញ្ញូមាននូវកតវេទិតាធម៌ (សេចក្តីតបគុណ) ចំពោះមាតាបិតា គោរពជឿស្តាប់ពាក្យរបស់មាតាបិតា ធ្វើតែការងារដ៏ប្រសើរដឹងសព្វកិច្ចការរាក់ជ្រៅ ថាបើមានបំណងប្រាថ្នាចង់បាននូវភាពរីករាយសប្បាយចិត្តនៅពេលដែលនឹកឃើញដល់រូបកូននោះ ។

ហេតុដូច្នេះហើយ យើងជាមាតាបិតាគប្បីយកចិត្តទុកដាក់ចំពោះបញ្ហាកូនៗ ឲ្យមែនទែន ទើបសម្រេចតាមគោលបំណងដែលមាតាបិតាគ្រប់រូបតែងតែប្រាថ្នាចង់បាននោះ ។

៥០. សមាជិកគ្រួសារគប្បីបញ្ញត្តិច្បាប់ទុកក្នុងត្រកូលដូចជាម៉ោងឬពេលវេលាប៉ុណ្ណោះ ត្រូវកំណត់ដឹងថា ជាពេលវេលាខុសកាលដោយមិនត្រូវឲ្យនរណាម្នាក់មកគោះហៅបើកទ្វារឬជនដទៃក្រៅត្រកូលក៏ដោយ វៀរលែងតែមានហេតុការណ៍ជាក់លាក់ពិតប្រាកដ ។

៥១. សមាជិកគ្រួសារគប្បីដឹកនាំត្រកូលខ្លួនឲ្យស្តាប់ឱវាទរបស់លោកអ្នកសប្បុរសទាំងឡាយ មានមាតាបិតាចាស់ព្រឹទ្ធាចារ្យ និងធម្មកថិកាចារ្យ ដោយផ្ទាល់ ឬតាមរយៈប្រព័ន្ធផ្សព្វផ្សាយដែលមានលក្ខណៈអប់រំចិត្តជាមូលដ្ឋានគ្រឹះប៉ុណ្ណោះជាដើម ក្នុងវេលាដែលសមគួរ ។ ម្យ៉ាងទៀត បើមាន ឱកាសអាចធ្វើទៅបាន គប្បីនិមន្តសមណព្រាហ្មណ៍(អ្នកបួស)មកផ្តល់ឱវាទ(ទេសនា)តាមកាលគួរ ឬថាបើក្នុងវត្តនោះ លោកមិនចេះឲ្យឱវាទទេ គប្បីបវរណាលោកឲ្យអានសៀវភៅធម៌ណា ដែលអាចស្តាប់យល់ចូលចិត្តបាន ។ ម៉្យាងទៀតគប្បីឲ្យមានសតិសម្បជញ្ញៈថាក្នុងថ្ងៃនេះអាត្មាអញបានធ្វើអំពើល្អអ្វីខ្លះ? ឬអំពើអាក្រក់អ្វីខ្លះ? បើឃើញថាអំពើទាំងពីរមិនស្មើគ្នា តួយ៉ាងដូចជាអំពើអាក្រក់ច្រើនជាងអំពើល្អ កុំ

សង្ឃឹមថានឹងបានឋានសួគ៌ឲ្យសោះ គឺថាមុខជា **អវិសិរោ** ក្បាលសំយ៉ុង ចុះទៅអបាយភូមិ៤ មាននរក ប្រេតជាដើមជាក់ជាពុំខាន ។

៥២. សមាជិកគ្រួសារអប់រំសមាជិកគ្រួសារខ្លួនឲ្យចេះយកចិត្តទុកដាក់ចំពោះការថែទាំការរៀបចំទុកដាក់ក្នុងគេហដ្ឋានខ្លួន កុំឲ្យមានគំនិតមើលបំណាំគ្នាឲ្យសោះ បើក្នុងនាមខ្លួនជាមេគ្រួសារ ព្រោះថាភាពជាអ្នករស់នៅក្នុងគេហដ្ឋានជាមួយគ្នា ត្រូវចេះជួយគ្នាដោយក្តីរាប់អាន យល់ច្បាស់ពីភារកិច្ចរៀងៗខ្លួននិងសហការក្នុងគ្រួសារដោយមិនមើលបំណាំគ្នា គឺពិតជាផ្តល់ឲ្យមានបរិយាកាសរីករាយជាទីបំផុតក្នុងគ្រួសារ ។ ការបណ្តុះទម្លាប់ល្អឲ្យកូនចៅ ចេះជួយការងារផ្ទះដោយមិនប្រកាន់ខ្លួនគឺជាការប្រសើរបំផុត ។

៥៣. សមាជិកគ្រួសារគប្បីព្យាយាមបំពេញប្រយោជន៍ បើមានតួនាទីជាមាតាបិតា គប្បីឧស្សាហ៍ណែនាំកូនកុំឲ្យធ្វើអំពើអាក្រក់ឲ្យកូនចេះប្រព្រឹត្តធ្វើនូវអំពើល្អ រក្សាសីល មានសីល៥ សីល៨ ឬ ឧបោសថសីល និងឲ្យខិតខំសិក្សារៀនសូត្រស្វែងរកចំណេះដឹងទូទៅ ។ បើមានតួនាទីជាលោកគ្រូអាចារ្យ គប្បីឧស្សាហ៍ណែនាំសិស្សឲ្យល្អខំបង្រៀនចំណេះវិជ្ជាដោយការយកចិត្តទុកដាក់ ។ បើមានតួនាទីជាបព្វជិតក្នុងព្រះពុទ្ធសាសនា គប្បីហាមប្រាមគ្រហស្ថត្រកូល កុំឲ្យធ្វើបាបណែនាំឲ្យតាំងនៅក្នុងសេចក្តីល្អ អនុគ្រោះពុទ្ធបរិស័ទដោយទឹកចិត្ត មេត្តាឲ្យបានស្តាប់ធម៌

ដែលមិនធ្លាប់បានស្តាប់ ឲ្យកាន់តែច្បាស់ឡើងនូវធម៌ដែលធ្លាប់បានស្តាប់ហើយបង្ហាញផ្លូវជីវិតឲ្យបានជួបប្រសព្វសេចក្តីសុខចម្រើននោះ ទើបដំណើរជីវិតប្រព្រឹត្តទៅយ៉ាងប្រសើរ ។

សិក្សាព្រះសូត្រ

ពោធិវគ្គ ទី១

ខ្ញុំបានស្តាប់មកយកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគបានត្រាស់ដឹងជាដម្បូង ទ្រង់គង់នៅក្បែរគល់ពោធិព្រឹក្ស ទៀបឆ្នេរស្ទឹងនេរញ្ជរា ក្នុងឧរុវេលាប្រទេស ។

សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់គង់ដោយបល្ល័ង្កតែមួយ សោយវិមុត្តិសុខអស់១សប្តាហ៍(៧ថ្ងៃ) ។ លុះអំណោះសប្តាហ៍នោះហើយ ព្រះមានព្រះភាគ ទ្រង់ចេញអំពីសមាធិនោះ ទ្រង់រំពឹងក្នុងព្រះហ្ឫទ័យចំពោះបដិច្ចសមុប្បាទធម៌ ជាអនុលោមគឺពិចារណាបណ្តោយ អស់រាត្រីបឋមយាម ដោយប្រពៃថា កាលបើបច្ច័យ[៦]នេះមាន ផលនេះក៏មាន ផលនេះ រមែងកើតឡើង ព្រោះការកើតឡើងនៃបច្ច័យនេះ គឺសង្ខារទាំងឡាយ កើតមាន ព្រោះអវិជ្ជា ជាបច្ច័យ វិញ្ញាណកើតមាន ព្រោះសង្ខារ ជាបច្ច័យ នាមរូប កើតមាន ព្រោះវិញ្ញាណ ជាបច្ច័យ សឡាយតនៈ កើតមាន ព្រោះនាមរូប ជាបច្ច័យ ផស្សៈ កើតមាន ព្រោះសឡាយតនៈ ជាបច្ច័យ វេទនា កើតមាន ព្រោះផស្សៈ ជាបច្ច័យ តណ្ហាកើតមាន ព្រោះវេទនា ជាបច្ច័យ ឧបាទាន កើតមាន ព្រោះតណ្ហា ជាបច្ច័យ ភពកើតមាន ព្រោះឧបាទាន ជាបច្ច័យ

[៦] ពាក្យថា បច្ច័យជាពាក្យផ្លាស់ផ្លូវគ្នានិងពាក្យថា ហេតុ

ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ ក៏រមែងកើតព្រម ការកើតឡើងនៃកងទុក្ខទាំងអស់នោះ រមែងមានយ៉ាងនេះឯង ។ លុះព្រះមានព្រះភាគ ទ្រង់ជ្រាបច្បាស់សេចក្តីនុ៎ះហើយ ទើបទ្រង់បន្លឺនូវឧទាននេះ ក្នុងវេលានោះថា ៖

យទា ហវេ បាតុភវន្តិ ធម្មា
អាតាបិនោ ឈាយតោ ព្រាហ្មណស្ស
អថស្ស កង្ខា វិបយន្តិ សព្វា
យតោ បជានាតិ សហេតុធម្មន្តិ ។

ធម៌ទាំងឡាយ រមែងប្រាកដដល់ព្រាហ្មណ៍ អ្នកមានព្យាយាមញ៉ាំងកិលេសឲ្យក្តៅ អ្នកដុតបង់នូវកិលេស ក្នុងកាលណា សេចក្តីសង្ស័យទាំងឡាយទាំងពួងរបស់ព្រាហ្មណ៍នោះ រមែងអស់ទៅ ក្នុងកាលនោះ ព្រោះដឹងច្បាស់នូវធម៌ព្រមទាំងហេតុ ។

ក៏បទថា តេន សមយេន ក្នុងបទមានជាអាទិ៍ថា **តេន ខោ បន សមយេន** ជាតតិយាវិភត្តិប្រើក្នុងអត្ថនៃសត្តមីវិភត្តិ ។ បទថា **ខោ បន** ជានិបាតអធិប្បាយថា **តស្មឹ សមយេ** ក្នុងសម័យនោះ ។ ក៏ក្នុងសម័យណា? គឺក្នុងសម័យដែលព្រះមានព្រះភាគត្រាស់ដឹងជាដំបូង ប្រថាប់នៅត្រង់គល់ពោធិ៍ជិតច្រាំងទន្លេនេរញ្ជរា ក្នុងតំបន់ឧរុវេលារហូតដល់អស់សម័យណា ក្នុងសម័យនោះ ។ បទថា **សត្តាហំ** ប្រែថា ៧ ថ្ងៃ គឺមួយសប្តាហ៍ ។ បទថា **សត្តាហំ** នេះ ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃអច្ចន្តសំយោគៈ ប្រែថា រហូតដល់អស់ ។ ព្រះដ៏មានព្រះភាគទ្រង់ប្រថាប់នៅដោយផលសមាបត្តិជាសុខ អស់

ចំណែកតែមួយដោយមិនដាច់រយៈរហូតដល់អស់សប្តាហ៍នោះ យ៉ាងណា លោកទើបពោលដោយទុតិយាវិភត្តិ ដោយអំណាចអច្ចន្តសំយោគៈថា **ស-ត្តាហំ** ប្រែថា ដល់អស់សប្តាហ៍ ក៏យ៉ាងនោះដែរ ។ បទថា **ឯកបល្លង្កេន** សេចក្តីថា ដោយគង់ប្រថាប់ចម្រើនសមាធិតែម៉្យាងប៉ុណ្ណោះ ទ្រង់មិនក្រោកឡើងត្រឹមតែម្តងតាំងពីវេលា ដែលប្រថាប់គង់លើវជិរាសនៈ ដែលជាអបរាជិតបល្ល័ង្កដ៏ប្រសើរក្នុងវេលាព្រះអាទិត្យមិនទាន់អស្តង្គត ក្នុងថ្ងៃវិសា-ខបុណ្ណមី ។

បទថា **វិមុត្តិសុខំ បដិសំវេទី** សេចក្តីថា ព្រះអង្គប្រថាប់គង់សោយវិមុត្តិសុខ គឺសុខកើតអំពីផលសមាបត្តិ ។ បណ្តាបទទាំងនោះ បទថា វិមុត្តិ បានដល់ វិមុត្តិ ៥ គឺ តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្ត ។ បណ្តាវិមុត្តិទាំង ៥ នោះ ការរួចផុតដោយរួចផុតពីធម៌ដែលជាសត្រូវនោះៗ ដោយអង្គនៃគុណនោះៗ មានការបរិច្ចាគទេយ្យធម៌ជាដើម និងដោយអង្គនៃវិបស្សនា មានការកំណត់នាមរូបជាដើម ដរាបដល់អង្គនោះៗ ប្រព្រឹត្តទៅដោយមិនមានការសាបសូន្យចាត់ជាបហានៈ ។ តើការលះមានអ្វីខ្លះ? គឺការលះមច្ឆរិយៈ និងលោភៈជាដើម ដោយការឲ្យទាន លះបាណាតិបាតជាដើម ដោយការរក្សាសីល លះសក្កាយទិដ្ឋិដោយការកំណត់នាមរូប លះទិដ្ឋិដែលមិនមានហេតុ និងមានហេតុមិនស្មើគ្នា ដោយការកំណត់បច្ច័យ និងធម៌ដែលមិនមែនបច្ច័យ លះភាពជាអ្នកសង្ស័យដោយការឆ្លងផុតសេចក្តីសង្ស័យ ដែលជាចំណែកដទៃរបស់នាមរូបនោះឯង លះការប្រកាន់ថាយើង ថារបស់យើង ដោយការពិចារណាដល់រូបកលាបៈ(រូបជាក្រុម ជាដុំ) លះសេចក្តីសម្គាល់ក្នុងធម៌ដែលមិនមែនមគ្គថាជាមគ្គ

ដោយការកំណត់ថា មគ្គ និងមិនមែនមគ្គ លះឧច្ឆេទទិដ្ឋិ ដោយការឃើញការកើតនៃនាមរូប លះសស្សតទិដ្ឋិ ដោយការឃើញការរលត់នាមរូប លះសេចក្ដីសម្គាល់ក្នុងវត្ថុដែលមានភ័យថាមិនជាភ័យ ដោយការឃើញថាជាភ័យ លះសេចក្ដីសម្គាល់ថា គួរត្រេកអរដោយ ការឃើញថាជាទោសពីសេចក្ដីសម្គាល់រូបថា គួរភ្លើតភ្លើនដោយការឃើញរូបថា គួរនឿយណាយ លះការមិនប្រាថ្នាដើម្បីនឹង ឲ្យរួចផុតដោយញាណ គឺការចម្រើនប្រាថ្នាដើម្បីប្រាថ្នានិងរួចផុត លះការមិនប្រងើយដោយឧបេក្ខាញាណ លះភាវៈដែលបដិលោម(គឺជំទាស់) ក្នុងធម្មចិតិ និងព្រះនិព្វានដោយអនុលោមញាណ និងផុតពីភាវៈ មានសង្ខារជានិមិត្ត ដោយគោត្រភូញាណ នេះឈ្មោះថា **តទង្គវិមុត្តិ** ។

ម្យ៉ាងទៀត សេចក្ដីរួចផុតដែលសំដៅដល់ការមិនកើតឡើងនៃនីវរណៈ មានកាមឆន្ទនីវរណៈជាដើម និងបច្ចនិកធម៌(ធម៌ដែលជាសត្រូវ) មានវិតក្កៈជាដើម ដោយសមាធិដែលផ្សេងដោយឧបចារសមាធិ និងអប្បនាសមាធិ ដរាបដល់សមាធិនោះប្រព្រឹត្តទៅដោយការមិនសាបសូន្យ នេះឈ្មោះថា **វិក្ខម្ភនវិមុត្តិ** ។

សេចក្ដីរួចផុតដោយអំណាចសមុច្ឆេទបហាន ដោយការមិនកើតឡើងម្ដងទៀត នៃក្រុមកិលេសជាចំណែកសមុទយៈ ដែលពោលទុកដោយន័យមានជាអាទិ៍ថា **ទិដ្ឋិគតានំ បហានាយ** ព្រោះលះទិដ្ឋិ តាមសមគួរក្នុងសន្តាននៃព្រះអរិយអ្នកតាំងនៅក្នុងមគ្គនោះៗ ព្រោះលោកធ្វើអរិយមគ្គ ៤ ឲ្យកើត នេះឈ្មោះថា **សមុច្ឆេទវិមុត្តិ** ។ ក៏ភាវៈនៃកិលេស ដែលស្ងប់រម្ងាប់ទៅក្នុងខណៈនៃផលចិត្ត នេះឈ្មោះថា **បដិបស្សទ្ធិវិមុត្តិ** ។ ចិត្តដែលរួចផុត

ពីសង្ខារទាំងពួង ឈ្មោះថា **និព្វាន** ព្រោះរលាស់សង្ខតធម៌ទាំងពួង នេះឈ្មោះថា **និស្សរណវិមុត្តិ** ។ តែក្នុងទីនេះ លោកប្រាថ្នាយកការរួចផុតដោយអំណាចនៃផលចិត្ត របស់ព្រះដ៏មានព្រះភាគ ដែលមានព្រះនិព្វានជាអារម្មណ៍ ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា **វិមុត្តិសុខំ បដិសំ-វេទី** សេចក្តីថា ព្រះអង្គគង់ប្រថាប់សោយវិមុត្តិសុខ គឺសុខដែលកើតអំពីផលសមាបត្តិ ។ ក៏បទថា **វិមុត្តិ** បានដល់ ភាវៈដែលចិត្តរួចផុតដោយអំណាចការស្ងប់រម្ងាប់ឧបកិលេស ។ ម៉្យាងទៀត គប្បីជ្រាបចិត្តនុ៎ះឯងថា រួចផុតហើយយ៉ាងនោះ ។ សុខដែលកើតឬសម្បយុត្តដោយវិមុត្តិនោះ ឈ្មោះថា **វិមុត្តិ-សុខ** ។ ក៏ក្នុងទីនេះ សូម្បីឧបេក្ខាក៏គប្បីជ្រាបថាសុខដូចគ្នា ព្រោះព្រះបាលីថា **យាយំ ភន្តេ ឧបេក្ខា សន្តេ សុខេ វុត្តា ភគវតា បពិត្រលោកដ៏ចម្រើនឧបេក្ខានេះណា ព្រះដ៏មានព្រះភាគទ្រង់ សម្តែងថា សុខដ៏ឧត្តម**[៧] ។ សមដូចពាក្យដែលលោកពោលទុកក្នុងអដ្ឋកថាសម្មោហវិនោទនីថា **ឧបេក្ខា បន សន្តត្តា សុខមិច្ចេវ ភាសិតា** ក៏ឧបេក្ខាលោកពោលថាសុខដូចគ្នា ព្រោះមានសេចក្តីស្អប់ ។ មែនពិត ព្រះដ៏មានព្រះភាគទ្រង់ចូលអរហត្តសមាបត្តិ ដែលប្រកបដោយឈានទី ៤ មិនមែនចូលសមាបត្តិដទៃទេ ។ ម្យ៉ាងទៀត ការចូលទៅស្ងប់សង្ខារទុក្ខ លោកហៅថា **សុខ** ដូចក្នុងប្រយោគមានជាអាទិ៍ថា **តេសំ វូបសមោ សុខោ** ការចូលទៅស្ងប់សង្ខារជាសុខយ៉ាងណា ចំពោះបដិ-ប្បស្សទ្ធិវិមុត្តិដែលបានក្នុងផលដ៏ប្រសើរ(អរហត្តផល) ព្រោះជាការស្ងប់ចាកកិលេសនិងទុក្ខទាំងអស់ គប្បីជ្រាបថា សុខក្នុងទីនេះដូច្នេះ ។ វិមុត្តិ-

[៧] សុត្តន្តបិដក មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ លេខ ២៣ ទំព័រ ១៦២

សុខនេះ នោះមាន ២ យ៉ាង ដោយការចែកការប្រព្រឹត្តទៅរបស់ផលចិត្ត គឺក្នុងមគ្គវិថី ១ ក្នុងកាលដទៃ ១ ។ ផលចិត្ត ៣ ឬ ២(ខណៈ) ដែលមានព្រះនិព្វានជាអារម្មណ៍ដែលជាផលរបស់វិមុត្តិសុខនោះៗ រមែងកើតឡើងក្នុងលំដាប់អរិយមគ្គតែម្យ៉ាង ព្រោះលោកុត្តរកុសល មានវិបាកក្នុងលំដាប់ ។ ក្នុងគ្រាដែលអនុលោមចិត្ត ២ ដួង កើតក្នុងជវនវារៈ ដែលអរិយមគ្គកើតឡើង ចិត្តដួងទី ៣ ចាត់ជាគោត្រភូចិត្តទី ៤ ចាត់ជាមគ្គចិត្ត តអំពីនោះទៅជាផលចិត្ត ៣ ដួង ។ តែក្នុងគ្រាដែលអនុលោមចិត្តកើតឡើង ៣ ដួង ចិត្តដួងទី ៤ ជាគោត្រភូចិត្តដួងទី ៥ ជាមគ្គចិត្ត បន្ទាប់ពីនោះទៅ ជាផលចិត្ត ២ ដួង ។ ចិត្តដួងទី ៤ ទី ៥ រមែងប្រព្រឹត្តទៅដោយអំណាចអប្បនា ដោយប្រការដូច្នេះ តអំពីនោះប្រព្រឹត្តទៅមិនបានព្រោះជិតចំពោះភវង្គចិត្ត ។ តែអាចារ្យពួកខ្លះពោលថា សូម្បីចិត្ត ដួងទី ៦ ក៏ជាអប្បនា ។ ពាក្យនោះលោកជំទាស់ទុកក្នុងអដ្ឋកថាហើយ ។ គប្បីជ្រាបផលចិត្តក្នុងមគ្គវថី ដោយប្រការដូច្នេះ ។ តែផលចិត្តក្នុងកាលដទៃរមែងប្រព្រឹត្តទៅដោយផលសមាបត្តិ និងកើតឡើងដល់បុគ្គលអ្នកចេញចាកនិរោធសមាបត្តិ លោកសង្គ្រោះយកផលសមាបត្តិនោះឯង ។ ក៏ផលសមាបត្តិនេះ នោះពោលអំពីអត្ថជាវិបាកនៃលោកុត្តរកុសលចិត្ត ដែលមានព្រះនិព្វានជាអារម្មណ៍ គប្បីជ្រាបថា ជាអប្បនា ។

សួរថា ផលសមាបត្តិនោះ តើបុគ្គលណាចូលបាន បុគ្គលពួកណាចូលមិនបាន? ឆ្លើយថា បុថុជ្ជនទាំងអស់ចូលមិនបាន ព្រោះមិនទាន់បានសម្រេច ។ ម្យ៉ាងទៀត ព្រះអរិយៈថ្នាក់ក្រោមក៏ដូចគ្នា ចូលផលសមាបត្តិថ្នាក់ខ្ពស់មិនបាន សូម្បីព្រះអរិយៈថ្នាក់ខ្ពស់ ក៏មិនចូលផលសមាបត្តិថ្នាក់

ក្រោមដូចគ្នា ព្រោះលោកស្ងប់រម្ងាប់ដោយការចូលដល់ភាពជាបុគ្គលដទៃ ។ ព្រះអរិយៈនោះៗ រមែងចូលផលសមាបត្តិរបស់ខ្លួនៗប៉ុណ្ណោះ ។ តែអាចារ្យពួកខ្លះពោលថា ព្រះសោតាបន្នបុគ្គល និងព្រះសកទាគាមីបុគ្គល រមែងមិនចូលផលសមាបត្តិ ព្រះអរិយបុគ្គលថ្នាក់ខ្ពស់ ២ ពួកប៉ុណ្ណោះរមែងចូលបាន ព្រោះលោកធ្វើឲ្យបរិបូណ៌ក្នុងសមាធិ ។ ប្រការនោះមិនមែនជាហេតុ សូម្បីបុថុជ្ជនក៏ចូល លោកិយសមាធិដែលខ្លួនបានហើយ ។ ម៉្យាងទៀត នឹងចាំបាច់ពោលទៅថ្វី ដោយការគិតដល់ហេតុក្នុងសេចក្តីនេះ ។ សមដូចដែលលោកពោលទុកក្នុងបដិសម្ភិទាមគ្គថា **កតមា ទស សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ** សង្ខារុបេក្ខា ១០ កើតឡើងដោយអំណាចវិបស្សនាតើដូចម្តេច[៨]? **កតមា ទស គោត្រភុធម្មា វិបស្សនាវសេន ឧប្បជ្ជន្តិ** គោត្រភូធម៌ ១០ ដូចម្តេចខ្លះ កើតឡើងដោយអំណាចវិបស្សនា[៩] ។ ក្នុងការដោះស្រាយបញ្ហាដូចពោលមកនេះ លោកពោលដល់ការចូលផលសមាបត្តិរបស់ព្រះអរិយៈទាំងនោះថា ដើម្បីប្រយោជន៍ដល់សោតាបត្តិផលសមាបត្តិ ។ ដើម្បីប្រយោជន៍ដល់សកទាគាមិផលសមាបត្តិ ។ ព្រោះដូច្នោះទើបព្រមព្រៀងគ្នាក្នុងសេចក្តីនេះថា ព្រះអរិយៈសូម្បីទាំងពួង រមែងចូលផលសមាបត្តិតាមដែលជារបស់ខ្លួន ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះអរិយៈទាំងនោះទើបចូលសមាបត្តិ? ឆ្លើយថា ដើម្បីនៅជាសុខក្នុងបច្ចុប្បន្ន ។ តួយ៉ាងដូចជាព្រះរាជាទាំងឡាយ

---

[៨] សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ១៩៥

[៩] សុត្តន្តបិដក ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ លេខ ៦៩ ទំព័រ ១៥៣

សោយសុខក្នុងរាជសម្បត្តិ ទេវតាទាំងឡាយសោយសុខជាទិព្វយ៉ាងណា ព្រះអរិយៈទាំងឡាយក៏ដូច្នោះ រមែងកំណត់កាលថា នឹងសោយលោកុត្តរសុខ ទើបចូលផលសមាបត្តិក្នុងខណៈដែលត្រូវការ ។

សួរថា ក៏ផលសមាបត្តិនោះ ចូលយ៉ាងណា តាំងនៅយ៉ាងណា ចាកចេញយ៉ាងណា? ឆ្លើយថា មុនការចូលផលសមាបត្តិមានអាការៈ ២ យ៉ាង គឺ ការមិនធ្វើទុកក្នុងចិត្តនូវអារម្មណ៍ដទៃពីព្រះនិព្វាន១ និងធ្វើទុកក្នុងចិត្តនូវព្រះនិព្វាន១ ។ សមដូចដែលព្រះសារីបុត្តពោលនឹងព្រះមហាកោដ្ឋិកៈថា ទ្វេ ខោ អាវុសោ បច្ចយា អនិមិត្តាយ ចេតោវិមុត្តិយា សមាបត្តិយា សព្វនិមិត្តានញ្ច អមនសិការោ អនិមិត្តាយ ច ធាតុយា មនសិការោ ម្នាលអាវុសោ អនិមិត្តចេតោវិមុត្តិសមាបត្តិមានបច្ច័យ ២ គឺការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង១ ការយកចិត្តទុកដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍១[១០] ។

ក៏ក្នុងទីនេះ មានលំដាប់ការចូលផលសមាបត្តិដូចតទៅនេះ ព្រះអរិយសាវកអ្នកត្រូវការផលសមាបត្តិទៅក្នុងទីកំបាំង ពួនសម្ងំនៅ គប្បីពិចារណាសង្ខារដោយឧទយព្វយញ្ញាណជាដើម ។ កាលលោកមាន វិបស្សនាញាណដោយលំដាប់ដែលប្រព្រឹត្តទៅយ៉ាងនេះ ចិត្តរមែងជាអប្បនាក្នុងនិរោធដោយអំណាចផលសមាបត្តិជាលំដាប់គោត្រភូញាណ មានសង្ខារជាអារម្មណ៍ ។ ក៏ផលចិត្តប៉ុណ្ណោះកើតដល់សេក្ខបុគ្គល មគ្គចិត្តមិនកើតសូម្បីដល់ព្រះសេក្ខបុគ្គលទេ ព្រោះលោកបង្អោនទៅក្នុងផលសមាបត្តិ ។

---

[១០] សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៨០

ចំណែកអាចារ្យពួកខ្លះពោលថា ព្រះសោតាបន្នគិតថា នឹងចូលផលសមាបត្តិរបស់ខ្លួនហើយចម្រើនវិបស្សនាជាព្រះសកទាគាមី និងព្រះសកទាគាមីគិតថា នឹងចូលផលសមាបត្តិរបស់ខ្លួន ហើយចម្រើនវិបស្សនាបានជាអនាគាមី ដូច្នេះ អាចារ្យទាំងនោះគប្បីពោលថា កាលបើសភាវៈដូច្នោះមានព្រះអនាគាមីក៏នឹងជាព្រះអរហន្ត ព្រះអរហន្តក៏នឹងជាព្រះបច្ចេកពុទ្ធ ព្រះបច្ចេកពុទ្ធក៏នឹងជាព្រះសទ្ធម្មដូច្នេះ ព្រោះដូច្នោះវិបស្សនាទើបឲ្យសម្រេចប្រយោជន៍តាមសេចក្តីត្រេកអរក្នុងចិត្តសន្តាន តាមអធ្យាស្រ័យ ព្រោះហេតុនោះ សម្រាប់ព្រះសេក្ខបុគ្គលក៏កើតតែផលចិត្តប៉ុណ្ណោះ មគ្គចិត្តមិនកើតឡើងទេ ។ ប្រសិនបើលោកសម្រេចមគ្គចិត្ត ដែលសម្បយុត្តដោយបឋមឈាន សូម្បីផលចិត្តដែលសម្បយុត្តដោយបឋមឈានប៉ុណ្ណោះ ក៏កើតដល់លោក ប្រសិនបើលោកសម្រេចមគ្គចិត្ត ដែលសម្បយុត្តដោយឈានយ៉ាងណាមួយ បណ្តាឈានទាំងឡាយ មានទុតិយឈានជាដើម ផលចិត្តដែលសម្រេចដោយឈានយ៉ាងណាមួយ បណ្តាឈានទាំងឡាយ មានទុតិយឈានជាដើមក៏រមែងកើត ។

សួរថា ព្រោះហេតុអ្វី ក្នុងទីនេះ គោត្រភូញាណទើបមិនមាននិព្វានជាអារម្មណ៍ ដូចញាណដែលជាបុរេចារិករបស់មគ្គញ្ញាណ? ឆ្លើយថា ព្រោះផលញាណមិនជានិយ្យានិកធម៌ ។ សេចក្តីពិត ធម៌ គឺអរិយមគ្គប៉ុណ្ណោះ ជានិយ្យានិកធម៌ ។ សមដូចពាក្យដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងទុកថា កតមេ ធម្មា និយ្យានិកា ចត្តារោមគ្គា អបរិយាបន្នា ពួកធម៌ ជានិយ្យានិកៈ

(ធម៌នាំសត្វឲ្យរួចចាកវដ្ដៈ) តើដូចម្ដេច[១១] ? ព្រោះដូច្នោះ ញាណដែលជាអនន្តរប្បច្ច័យនៃសភាវធម៌ ដែលជានិយ្យានិកៈដោយចំណែកតែមួយ ដែលប្រព្រឹត្តទៅដោយការចេញចាកទាំងពីរចំណែក គប្បីចេញពីនិមិត្តបាន ព្រោះដូច្នោះ គោត្រភូញាណនោះ មានព្រះនិព្វានជាអារម្មណ៍ទើបត្រឹមត្រូវ ប៉ុន្តែថា ញាណដែលជាបុរេចារិករបស់ផលញាណ ដែលមានសភាវៈមិនចេញទៅ ព្រោះមិនជានិយ្យានិកធម៌ ជាហេតុដែលមិនកាត់ផ្ដាច់កិលេស ដែលកំពុងប្រព្រឹត្តទៅដោយវិបាករបស់អរិយមគ្គនោះ ព្រោះបានចម្រើនអរិយមគ្គទុក សូម្បីពេលខ្លះនិងមានព្រះនិព្វានជាអារម្មណ៍ ក៏មិនគួរ ព្រោះអនុលោមញ្ញាណ ក្នុងទាំង ២ ចំណែកមានអាការៈមិនស្មើគ្នាទេ ។ មែនពិត អនុលោមញ្ញាណក្នុងអរិយមគ្គវិថីដែលដល់ការបរិបូណ៌យ៉ាងឧក្រិដ្ឋដោយលោកិយញ្ញាណ ដែលជាគ្រឿងទម្លាយគំនរលោភៈជាដើមដ៏សន្ធឹកសន្ធាប់ដែលមិនធ្លាប់ចាក់ធ្លុះពីមុនរហូតអនុលោមមគ្គញ្ញាណកើតឡើង ចំណែកផលសមាបត្តិវិថី អនុលោមញ្ញាណនោះៗ មិនមានសេចក្ដីខ្វល់ខ្វាយក្នុងអរិយមគ្គវិថីនោះ ព្រោះកាត់កិលេលនោះៗ បានជាសមុច្ឆេទ កើតត្រឹមតែជាបរិកម្មនៃការព្រមព្រៀងដោយសុខ ដែលកើតពីផលសមាបត្តិរបស់ព្រះអរិយទាំងឡាយតែម្យ៉ាង ព្រោះដូច្នោះ អនុលោមញ្ញាណទាំងនោះ ទើបមិនមានការចេញចាកបច្ច័យណាមួយ ព្រោះញាណក្នុងទីបំផុតនៃអនុលោមញ្ញាណទាំងនោះ ដែលមានសង្ខារជានិមិត្ត គប្បីមានព្រះនិព្វានជាអារម្មណ៍អំពីការចេញចាកសមាបត្តិ ។ ក៏ព្រោះធ្វើពាក្យអធិប្បាយដូច្នេះថា កាលព្រះ

---

[១១] អភិធម្មបិដក ធម្មសង្គណី លេខ ៧៩ ទំព័រ ២២០

សេក្ខបុគ្គលពិចារណាសង្ខារទាំងពួង ដោយឧទយព្វយញ្ញាណជាដើម ដើម្បីនឹងប្រើផលសមាបត្តិរបស់ខ្លួន ផលចិត្តប៉ុណ្ណោះទើបកើតឡើង ក្នុងលំដាប់វិបស្សនាញាណមគ្គមិនកើត ។ ព្រោះដូច្នោះ សេចក្តីដូចពោលមកនេះឯងទើបជាការគ្រប់គ្រាន់ហើយ ។ គប្បីជ្រាប ការចូលផលសមាបត្តិ ដូចពោលមកយ៉ាងនេះមុន ។

ក៏ផលសមាបត្តិនោះ មានការតាំងនៅដោយអាការៈ ៣ យ៉ាង ព្រោះព្រះបាលីថា ម្នាលអាវុសោ បច្ច័យដែលឲ្យអនិមិត្តាចេតោវិមុត្តិតាំងនៅបានយូរមាន ៣ ប្រការ គឺមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង១ ការយកចិត្តដាក់ចំពោះនិព្វានធាតុដែលប្រាសចាកអារម្មណ៍១ ការបានតាក់តែងទុកពីខាងដើម១[១២] ។ បណ្តាបច្ច័យ ៣ យ៉ាងនោះ បទថា បុព្វេ ច អភិសង្ខារោ បានដល់ការកំណត់វេលាក្នុងកាលមុនចូលសមាបត្តិ ។ ក៏ផលសមាបត្តិនោះ មិនមានការចេញដរាបដែលនៅមិនដល់វេលានោះ ព្រោះលោកកំណត់ទុកថា នឹងចេញក្នុងវេលាឯណោះ ។

ម៉្យាងទៀត ផលសមាបត្តិនោះ រមែងមានការចេញចាកដោយអាការ ២ យ៉ាង ព្រោះព្រះបាលីថា ម្នាលអាវុសោ បច្ច័យនៃការចេញអនិមិត្តាចេតោវិមុត្តិមាន ២ ប្រការ គឺការយកចិត្តទុកដាក់ចំពោះអារម្មណ៍ទាំងពួង១ ការបានតាក់តែងទុកពីខាងដើម១[១៣] ។ បណ្តាបច្ច័យ ២ យ៉ាងនោះ បទថា សព្វនិមិត្តានំ បានដល់ រូបនិមិត្ត វេទនានិមិត្ត សញ្ញានិមិត្ត សង្ខារនិមិត្ត និង

---

[១២] សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៨១

[១៣] សុត្តន្តបិដក មជ្ឈិមនិកាយ មូលបណ្ណាសកៈ លេខ ២២ ទំព័រ ២៨១

វិញ្ញាណនិមិត្ត ។ ព្រះយោគាវចរ មិនធ្វើទុកក្នុងចិត្តរួមគ្នានូវនិមិត្តទាំងនោះ ក៏ពិតមែនហើយ ក៏ប៉ុន្តែថា លោកពោលទុកយ៉ាងនោះដោយការរួមនិមិត្តទាំងពួង ។ ព្រោះដូច្នោះ អារម្មណ៍របស់ភវង្គចិត្តយ៉ាងណា ការចេញអំពីផលសមាបត្តិ រមែងមានដោយមនសិការដល់អារម្មណ៍នោះ គប្បីជ្រាបការចេញអំពីផលសមាបត្តិនោះ ដោយប្រការយ៉ាងនេះ ។ ដូចព្រះធម្មសង្គាហកាចារ្យពោលថា **វិមិត្តិសុខំ បដិ សំវេទី** ដូច្នេះ សំដៅយកការចូល ការតាំងនៅ និងការចេញចាកផលសមាបត្តិ ដូចពោលមកនេះ នោះចាត់ជាអរហត្តផល ដែលស្ងប់រម្ងាប់សេចក្ដីខ្វល់ខ្វាយ មានអមតៈជាអារម្មណ៍ ជាវន្តលោកាមិសសុខ[១៤] ស្ងប់ជាសាមញ្ញផលដល់ខ្ពង់ខ្ពស់បំផុត ។ ព្រោះហេតុនោះ លោកទើបពោលថា បទថា **វិមុត្តិសុខំ បដិសំវេទី** បានដល់ គង់ប្រថាប់សោយវិមុត្តិសុខ គឺសុខដែលកើតអំពីផលសមាបត្តិ ។

ស័ព្ទថា អថ ជានិបាតចុះក្នុងអត្ថនៃអធិការ ។ ស័ព្ទថា **ខោ** ជានិបាតចុះក្នុងអត្ថនៃបទបូរណៈ(ធ្វើបទឲ្យពេញ) ។ ក្នុងស័ព្ទថា **អថ ខោ** នោះ ដោយស័ព្ទថា អថ ដែលមានអធិការជាអត្ថនេះ លោកសម្ដែងដល់អធិការ(គឺភារកិច្ច)យ៉ាងដទៃពីការសោយវិមុត្តិសុខ ។ សួរថា ក៏អធិការដទៃនោះ គឺអ្វី? ឆ្លើយថា គឺការយកចិត្តទុកដាក់ក្នុងបដិច្ចសមុប្បាទ ។ ម្យ៉ាងទៀត ស័ព្ទថា **អថ** ជានិបាតចុះក្នុងអត្ថថា **បច្ឆា**(ខាងក្រោយ) ។ ព្រោះហេតុនោះ ស័ព្ទថា **អថ** នោះទើបបំភ្លឺអត្ថដែលកំពុងពោលដោយន័យថា កាលកន្លងទៅ ៧ ថ្ងៃ

---

[១៤] តណ្ហាសង្ខាតំ លោកាមិសំ វន្តំ ឆឌ្ឌិតំ ឯតេនាតិ វន្តលោកាមិសំ សេចក្ដីសុខដែលទាត់ចោល គឺកាត់ចោលនូវលោកាមិស ពោលគឺ តណ្ហាដោយសភាវៈនោះ ព្រោះដូច្នោះ សេចក្ដីសុខនោះ ឈ្មោះថា វន្តលោកាមិសសុខ ។ (បរមត្ថមញ្ជុសា មហាដីកាវិសុទ្ធិមគ្គ)

នោះ ។ បទថា **តស្ស សត្តាហស្ស** បានដល់ គង់ប្រថាប់អស់ ៧ ថ្ងៃ ។ បទថា **អច្චយេន** ប្រែថា ប្រាសចាកទៅ ។ បទថា **តម្හា សមាធិម្හា** បានដល់ ពីសមាធិដែលសម្បយុត្តដោយអរហត្តផល ។ តែក្នុងទីនេះ អាចារ្យពួកខ្លះពោលឲ្យពិស្តារនូវសប្តាហ៍ទាំងនោះទៅទៀតថា គប្បីសម្តែង ៧ សប្តាហ៍រៀងទៅដោយលំដាប់ ។ ក៏យើងទាំងឡាយ នឹងពណ៌នាសប្តាហ៍ទាំងនេះខាងមុខ ដោយវិធីសម្តែងដែលមិនខុសភ្លាត់ ក្នុងឧទានបាលីនេះ ដោយខន្ធកបាឋៈ ។ បទថា **រត្តិយា** ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថដែលសម្ព័ន្ធនឹងចំណែកផ្សេងៗ (របស់រាត្រី) ។ បទថា **បឋមំ** ជាទុតិយាវិភត្តិចុះក្នុងអត្ថថា **អច្ចន្តសំយោគៈ** ប្រែថា រហូតដល់អស់ ។ មែនពិត ព្រះមានព្រះភាគទ្រង់ ប្រកបដោយការធ្វើទុកក្នុងចិត្តនោះឯង រហូតដល់អស់បឋមយាមសូម្បីទាំងអស់របស់រាត្រីនោះ ។

បទថា **បដិច្ចសមុប្បាទំ** បានដល់ បច្ចយធម៌ ។ មែនពិត បច្ចយធម៌មានអវិជ្ជាជាដើម ឈ្មោះថា **បដិច្ចសមុប្បាទ** ។ បើមានពាក្យសួរថា ប្រការនេះនឹងគប្បីដឹងបានយ៉ាងណា? ឆ្លើយថា ដឹងបានព្រោះព្រះតម្រាស់របស់ព្រះដ៏មានព្រះភាគ ។ មែនពិត ព្រះមានព្រះភាគត្រាស់ទុកថា ម្នាលអានន្ទព្រោះហេតុដូច្នោះឯង ជាតិនេះទើបជាហេតុ ជានិទាន ជាសមុទ័យ ជាបច្ច័យនៃជរា មរណៈ ។ល។ អវិជ្ជានេះឯង ជាហេតុជានិទាន ជាសមុទ័យ ជាបច្ច័យនៃសង្ខារទាំងឡាយ[១៥] គឺអវិជ្ជា រួមសេចក្តីថា បច្ចយធម៌ មានអវិជ្ជា

---

[១៥] សុត្តន្តបិដក ទីឃនិកាយ មហាវគ្គ លេខ ១៦ ទំព័រ ១២១

ជាដើម ជាតួហេតុ ដូចយ៉ាងដែលលោកពោទុកថា បច្ច័យ ១២ គឺ បដិច្ចសមុប្បាទ ១២ ។

ក្នុងសេចក្តីនោះ មានវចនៈដូចតទៅនេះ ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះអាស្រ័យ គឺប្រាថ្នាដោយមុខចំពោះគ្នានិងគ្នា មិនបដិសេធសេចក្តីព្រមព្រៀងគ្នារបស់ហេតុ ឲ្យបច្ច័យដែលជួយសង្រ្គោះគ្នាកើតឡើង ។ ម្យ៉ាងទៀត ការអាស្រ័យបច្ច័យដែលជាបច្ច័យដែលត្រូវអាស្រ័យគ្នា ប្រព្រឹត្តទៅកើតការសម្ព័ន្ធគ្នា ដោយមិនវៀរបច្ច័យនោះ ឈ្មោះថា បដិច្ចសមុប្បាទ ។ ក៏ក្នុងពាក្យថា បដិច្ចសមុប្បាទនេះ បានដល់ ហេតុដែលប្រកបដោយសេចក្តីអាចក្នុងការឲ្យកើតផល ដែលនឹងដឹងបានដោយពាក្យ ដែលមានការកើតព្រមជាហេតុជិត មិនគប្បីជ្រាបត្រឹមតែអាស្រ័យគ្នាកើតឡើង ។

ម៉្យាងទៀង **បច្ច័យ** ឈ្មោះថា **បដិច្ចៈ** និងព្រោះជាទីអាស្រ័យចំពោះបណ្ឌិត ឈ្មោះថា **សមុប្បាទ** ព្រោះឲ្យកើតឡើងដោយប្រពៃដោយខ្លួនឯង ។ បដិច្ចៈ និងសមុប្បាទនោះ ជាបដិច្ចសមុប្បាទ គប្បីជ្រាបសេចក្តីក្នុងបដិច្ចសមុប្បាទនេះ ដោយប្រការដូចពោលមកនេះ ។

ពាក្យថា **អនុលោមំ** បានដល់ បច្ចយាការមានអវិជ្ជាជាដើម ដែលលោកពោលទុកដោយន័យមានអាទិ៍ថា **អវិជ្ជាបច្ចយា សង្ខារា** ព្រោះអវិជ្ជាជាបច្ច័យ ទើបកើតមានសង្ខារ លោកហៅថា **អនុលោម** ព្រោះដែលខ្លួនគួរធ្វើ ។ ម្យ៉ាងទៀត ឈ្មោះថា **អនុលោម** ព្រោះលោកពោលតាំងពីដើមដរាបដល់ទីបំផុត ឬព្រោះអនុលោមតាមការប្រព្រឹត្តទៅនូវអនុលោមនោះ ។ បទថា **សាធុកំ មនសាកាសិ** បានដល់ ធ្វើទុកក្នុងចិត្តដោយគោរព ។ អធិប្បាយថា បច្ច័យធម៌ណា។ ជាបច្ច័យដល់បច្ចយុប្បន្នធម៌ណា។ ដោយសេចក្តីជា

បច្ច័យមានហេតុប្បច្ច័យជាដើម ដោយប្រការណាៗ ព្រះដ៏មានព្រះភាគទ្រង់ធ្វើធម៌ទាំងអស់នោះៗ ទុកក្នុងព្រះទ័យមិនឲ្យវិបរិត មិនឲ្យថយចុះដោយទ្រង់ពិចារណាមិនឲ្យនៅសល់ ។ ក៏ដើម្បីនឹងសម្តែងប្រការដែលព្រះដ៏មានព្រះភាគទ្រង់ធ្វើទុកក្នុងព្រះទ័យនូវបដិច្ចសមុប្បាទ ជាអនុលោមដោយសង្ខេបមុន ទើបពោលពាក្យជាអាទិ៍ថា **ឥតិ ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **ឥតិ** ស្មើនឹង **ឯវំ** អធិប្បាយថា ដោយប្រការនេះ ។ បទថា **ឥមស្មឹ សតិ ឥទំ ហោតិ** សេចក្តីថា កាលបច្ច័យមានអវិជ្ជាជាដើមនេះមានផល មានសង្ខារជាដើមនេះក៏មាន ។ បទថា **ឥមស្សុ-ប្បាទា ឥទំ ឧប្បជ្ជតិ** សេចក្តីថា ព្រោះបច្ច័យមានអវិជ្ជាជាដើមនេះក៏រមែងកើត ផលមានសង្ខារជាដើមនេះ រមែងកើត ។ បទថា **ឥមស្មឹ អសតិ ឥទំ ន ហោតិ ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** សេចក្តីថា ព្រោះត្រាស់សេចក្តីមិនមានសង្ខារជាដើម ក្នុងកាលអវិជ្ជាជាដើមមិនមាន ទុកក្នុងសូត្រទី ២ និងត្រាស់សេចក្តីរលត់សង្ខារជាដើម ក្នុងកាលអវិជ្ជាជាដើមរលត់ ទុកក្នុង សូត្រទី ៣ ឈ្មោះថា ជាការសម្តែងការកំណត់លក្ខណៈនៃបច្ច័យខាងដើមនេះ ។ កាលបច្ច័យ មានអវិជ្ជាជាដើមនេះមាននៅ គឺមិនមែនមិនមានទេ ។ ព្រោះអវិជ្ជាជាដើមនេះកើតមាន គឺមិនមែនមិនកើតទេ ។ ព្រោះរលត់នុ៎ះឯង មិនមែនមិនរលត់ទេ ។ ព្រោះហេតុដូច្នេះ គប្បីឃើញថា លក្ខណៈនោះជាការកំណត់ដែលធ្លាក់ចុះក្នុងខាង គឺព្រះដ៏មានព្រះភាគត្រាស់ទុកក្នុងទីនេះ សម្រាប់បដិច្ចសមុប្បាទ ។ ម៉្យាងទៀត បទថា **និរោធោ** បានដល់ ការមិនកើតឡើង គឺការមិនប្រព្រឹត្តទៅទៀត ព្រោះសម្រេចសេចក្តីប្រាសចាកបច្ច័យមានអវិជ្ជា

ជាដើម ។ សមដូចដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកមានជាអាទិ៍ថា **អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ** ការរលត់ទៅនៃសង្ខារ ព្រោះរលត់អវិជ្ជាឥតមានសេសសល់ ។

ដោយពាក្យថា **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** នោះ លោកសម្តែងសេចក្តីនេះទុកថា ការមិនរលត់ ឈ្មោះថា ការកើត និងការកើតនោះ ក្នុងទីនេះលោកហៅថា **អត្ថិភាវោ**(សេចក្តីមាន) ដូច្នេះក៏មាន ។ មែនពិត លក្ខណៈថា **ឥមស្មឹ សតិ ឥទំ ហោតិ** នេះឯង កាលពោលអំពីបរិយាយដទៃ បទដំបូងជាការប្លែកចាកពីបទចុង ដែលពោលថា **ឥមស្ស ឧប្បាទា ឥទំ ឧប្បជ្ជតិ** ។ ព្រោះដូច្នោះ ពាក្យដែលលោកពោលថា **ឥមស្មឹ សតិ** សំដៅដល់ភាវៈដែលទ្រង់មិនគង់នៅប៉ុណ្ណោះ ។ បើតាមពិតទៅ ព្រះអង្គទ្រង់ជ្រាបនូវការមិនរលត់ដោយមគ្គ ។ ក៏ព្រោះហេតុដែលលោកពោលដល់និទ្ទេសនៃលក្ខណៈដែលលើកឡើងសម្តែងជា ២ យ៉ាង គឺ **ឥមស្មឹ អសតិ ឥទំ ន ហោតិ** (និង) **ឥមស្ស និរោធា ឥទំ និរុជ្ឈតិ** ដូច្នេះ ទើបពោលចំពោះសេចក្តីរលត់ដោយន័យមានជាអាទិ៍ថា អវិជ្ជាយ ត្វេវ អសេសវិរាគនិរោធា សង្ខារនិរោធោ ព្រោះហេតុនោះ ទើបលោកសម្តែងថា សូម្បីការមិនមាន ក៏គឺការរលត់នោះឯង ការដែលខុសចាកពីការមិនមាន ក៏គឺការមិនរលត់ ។ ព្រោះហេតុនោះ លោកទើបសម្តែង ការកើតឲ្យប្លែកដោយភាពមានពោលគឺ ការមិនរលត់ ។ ព្រោះហេតុនោះ ក្នុងទីនេះលោកទើបមិនប្រាថ្នាយកថា ការកើតឡើងត្រឹមតែភាពមានប៉ុណ្ណោះទេ បើតាមពិត លោកធ្វើឲ្យច្បាស់ដល់អត្ថនេះថា ការមានគឺការមិនរលត់ ។ កាលបើដូច្នោះ ការពោលដល់លក្ខណៈទាំង ២ នោះ

គប្បីជ្រាបថា មានប្រយោជន៍ ព្រោះជាលក្ខណៈដែលនឹងគប្បីឲ្យប្លែក ដោយសេចក្តីប្លែកនៃគ្នានិងគ្នា ។

សួរថា ក៏ឈ្មោះថា **អនិរោធៈ** ដែលហៅថា **អត្ថិភាវៈ** និងថា **ឧប្បាទៈ** នេះ គឺអ្វី? ឆ្លើយថា គឺភាវៈដែលនៅមិនលះ១ ភាវៈដែលគួរឲ្យកើតផល ដោយមិនលះភាវៈដែលគួរដល់ផលដែលមិនទាន់កើត១ ភាវៈដែលអកុសលធម៌ដែលនឹងគប្បីលះនោះ គឺអរិយមគ្គមិនទាន់បានដកចេញ១ ភាវៈនៃកុសលធម៌និងអព្យាកតធម៌ ដែលមិនត្រូវលះសំយោជនៈរបស់អ្នកមានអាសវៈមិនទាន់អស់ទៅ នូវមិនឲ្យអស់ទៅ១ ។ មែនពិត ការប្រព្រឹត្តទៅនៃខន្ធព្រមដោយសំយោជនៈទាំងអស់ ឈ្មោះថា បដិច្ចសមុប្បាទ ព្រោះភាវៈមានអនុស័យ មិនទាន់ដកចេញ ។ សមដូចដែលព្រះដ៏មានព្រះភាគត្រាស់ទុកមានជាអាទិ៍ថា

ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលដែលអវិជ្ជាណាបិទបាំងទុកផង ដែលតណ្ហាណាប្រកបទុកផង ទើបកាយនេះកើតឡើង បុគ្គលពាលមិនបានលះបង់អវិជ្ជានោះមិនទាន់អស់តណ្ហានោះផង ដំណើរនោះតើព្រោះហេតុដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលពាលមិនប្រព្រឹត្តមគ្គព្រហ្មចរិយៈ ដើម្បីការអស់ទៅនៃទុក្ខដោយប្រពៃទេ ព្រោះហេតុនោះ បុគ្គលពាល លុះបែកធ្លាយរាយកាយទៅហើយ ក៏ចូលទៅចាប់បដិសន្ធិកាយ (ផ្សេងទៀត) កាលបុគ្គលនោះ ចូលទៅចាប់បដិសន្ធិកាយ(ផ្សេងទៀត) រមែងមិនរួចស្រឡះចាកជាតិ ជរា មរណៈ[១៦] ។

---

១៦ សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ៥២

ក៏ព្រោះអវិជ្ជារបស់បុគ្គលអ្នកអស់សំយោជនៈ សង្ខារ ទើបមិនមាន តណ្ហានិងឧបាទានក៏មិនមាន ឧបាទាននិងភពក៏មិនមានដែរ ព្រោះហេតុនោះ ការកាត់ផ្តាច់នូវវដ្ដៈនឹងប្រាកដ ។ ព្រោះហេតុនោះនុ៎ះឯង ព្រះដ៏មាន-ព្រះភាគទ្រង់ត្រាស់ពាក្យមានជាអាទិ៍ថា

ម្នាលផគ្គុន ឯការរលត់នៃផស្សៈព្រោះការរលត់ឥតមានសេសសល់នៃផស្សាយតនៈទាំង៦ការរលត់នៃវេទនា ព្រោះការរលត់នៃផស្សៈ[17]។

មែនពិត តាំងពីសម្រេចព្រះអរហត្តមគ្គដរាបដល់បរិនិព្វាន អាយត-នៈ ៦ ជាដើម តែងប្រព្រឹត្តទៅ ។ បើតាមពិត លោកពោលដល់និរោធ ព្រោះភាវៈដែលមិនមានភាវៈដែលគួរពោលស័ព្ទនិរោធ ការអស់ទៅនៃសំយោជនៈ ។ ម៉្យាងទៀត កម្មសូម្បីបុគ្គលធ្វើទុកយូរហើយចាត់ថា រមែងជាកម្មដែលគួរឲ្យផល ព្រោះផលមិនទាន់កើត និងព្រោះមិនទាន់លះអាហារ គឺមិនមែនផលដែលកើតហើយ ទាំងមានអាហារមិនទាន់លះផង ។ ភាវៈជាបច្ច័យឲ្យកើតផល មានអវិជ្ជានិងសង្ខារជាដើម ជាបច្ច័យគួរដល់ផលដោយន័យដូចពោលហើយនុ៎ះឯង គប្បីជ្រាបថា **អនិរោធ** (មិនរលត់) ។ មែនពិត ក៏ព្រោះបច្ច័យដែលឲ្យកើតផលយ៉ាងនោះមិនទាន់រលត់ វៀរហេតុណាចេញផលមិនកើត ហេតុនោះ មានអតីតហេតុជាដើម ដែលលោកពោលដោយពាក្យថា **ឥមស្មឹ សតិ** នេះ ។ ក៏ព្រោះហេតុនោះឯង ការកើតឡើងនៃបច្ច័យដែលដល់ការមិនប្រព្រឹត្តទៅរបស់អ្នកមិនទាន់នៅក្នុងព្រហ្មចរិយៈ លោកពោលថា **ឥមស្ស ឧប្បាទា** ដោយការមិនត្រឡប់មកដោយមិនប៉ះពាល់ដល់

---

17 សុត្តន្តបិដក សំយុត្តនិកាយ និទានវគ្គ លេខ ៣១ ទំព័រ ៣០

ប្រភេទរបស់កាល ។ ម៉្យាងទៀត ក្នុងសេចក្ដីដល់ព្រមរបស់បច្ច័យ ដែលនៅសល់ភាវៈដែលបច្ច័យសូម្បី នឹងមិនមានក៏ដូចមាន នឹងពោលទៅថ្វីដល់ហេតុរបស់បច្ច័យ ដែលមានឲ្យកើតផលនោះ លោកហៅថា **ឥមស្ស ឧប្បាទា** ។ ពិតយ៉ាងនោះ ផលរមែងកើតអំពីហេតុនោះ ព្រោះហេតុនោះទើបឈ្មោះថា **តទវត្ថុ** បានដល់ ហេតុសូម្បីមិនមាននៅ ក៏ឈ្មោះថា **តទវត្ថុ** ព្រោះដូច្នោះ ភាវៈដែលជា **តទវត្ថុ** គប្បីជ្រាបថា **ឧប្បាទៈ** ។

បណ្ដាបទទាំងនោះ ដោយបទថា **សតិ** នេះ ព្រះថេរៈកាលនឹងពោលដល់ភាវៈដែលជាបច្ច័យដោយត្រឹមតែការដែលមាននៅ ទើបសម្ដែងដល់ភាពនៃបដិច្ចសមុប្បាទមិនខ្វល់ខ្វាយ ។ ដោយបទថា **ឧប្បាទា** នេះ ព្រះថេរៈ កាលនឹងសម្ដែងការកើតឡើងជាធម្មតា និងភាវៈដែលមិនប្រព្រឹត្តទៅគ្រប់កាល និងភាវៈដែលប្រាថ្នាចំពោះការកើតផល ទើបសម្ដែងដល់ភាវៈនៃបដិច្ចសមុប្បាទជា **អនិច្ចតា** ។ ក៏ព្រះថេរៈសម្ដែងដល់បដិច្ចសមុប្បាទមានហេតុ មានសមុទយៈមានជាតិ និងមានដែនកើត ដែលសម្រេចដោយសត្តមីវិភត្តិ និងបញ្ចមីវិភត្តិដែលប្រើក្នុងអត្ថរបស់ហេតុដោយពាក្យថា **សតិ ន អសតិ ឧប្បាទា ន និរោធា** ។ លោកកំណត់ភាវៈនៃផល ដែលមានដោយមិនវៀរចាកក្នុងហេតុ ព្រោះភាវៈនៃសត្តមីវិភត្តិចុះក្នុងអត្ថនៃហេតុ គប្បីជ្រាបការប្រព្រឹត្តទៅក្នុងហេតុនោះ ដូចពាក្យថា កាលបើព្រះមហាក្សត្រ មិនទ្រង់ព្រះរាជទានព្រះរាជទ្រព្យដល់អ្នកក្សត់ទ្រព្យដូច្នេះ សេចក្ដីទ័លក្រក៏មានច្រើនឡើង និងពាក្យថា កាលបើស្រូវសម្បូរ ភិក្ខារកបានដោយស្រួល ។ សូម្បីបញ្ចមីវិភត្តិក៏ចុះក្នុងអត្ថនៃហេតុ ឈ្មោះថា ប្រព្រឹត្តទៅបានក្នុងដែនកើត និងក្នុងសេចក្ដីប្រក្រតីរបស់ផល ដូចពាក្យថា **កលលរូប** មកកើតជា

អម្ពុទរូប តពី**អម្ពុទរូប**មក កើតជា**បេសិរូប** និងពាក្យថា ទន្លេគង្គាកើតពីភ្នំហេមពាន្ត ស្រះកើតពីទន្លេសរភូ ។ ក៏ក្នុងភាវៈមាននៃវិជ្ជាជាដើមមាន លោកទើបកំណត់ភាវៈនៃផល មានសង្ខារជាដើម ព្រោះភាវៈដែលមិនវៀរចាកអវិជ្ជាជាដើមនោះ និងផល មានសង្ខារជាដើមកើតពីបច្ច័យ មានអវិជ្ជាជាដើម និងដែលបច្ច័យមានអវិជ្ជាជាដើមក៏កើតឡើង ព្រោះដូច្នោះ បច្ច័យមានអវិជ្ជាជាដើមនោះទើបជាដែនកើត និងជាប្រក្រតីរបស់ផល មានសង្ខារជាដើមនោះ ព្រោះដូច្នោះ ដើម្បីសម្ដែងអត្ថនោះ លោកទើបធ្វើនិទ្ទេសសត្តមីវិភត្តិ និងបញ្ចមីវិភត្តិ ក្នុងអត្ថនៃហេតុថា **ឥមស្មឹ សតិ ឥមស្ស ឧប្បាទា** ព្រោះវត្ថុនេះ មានព្រោះវត្ថុនេះកើត ។

ក៏ព្រោះក្នុងសេចក្ដីនេះ បដិច្ចសមុប្បាទដែលលើកឡើងសម្ដែងដោយសង្ខេបថា **ឥមស្មឹ សតិ ឥទំ ហោតិ ឥមស្សុប្បាទា ឥទំ ឧប្បជ្ជតិ** មាននិទ្ទេសជាដើមថា **អវិជ្ជាបច្ចយា សង្ខារា** ដូច្នោះ ភាវៈដែលមាននៅនិងការកើតឡើងតាមដែលពោលហើយ រមែងឲ្យដឹងបានថា ជាបច្ច័យនៃបច្ចុប្បន្នធម៌នោះៗ ។ មែនពិត ភាវៈដែលជាបច្ច័យយ៉ាងដទៃ រមែងមិនមាន ព្រោះចុះអត្ថិភាវៈ និងឧប្បាទៈពោលគឺ សេចក្ដីមិនរលត់ សេចក្ដីមិនវិលត្រឡប់ជាសភាព ឬសេចក្ដីតាំងនៅរបស់សមុទយៈ(ការកើត) ដែលលោកពោលទុកដោយពាក្យដែលកំណត់ពិតប្រាកដនៅខាងក្នុងថា **សតិឯវ នាសតិ ឧប្បទា ឯវ ន និរោធា** ដូច្នេះ ព្រោះដូច្នោះ គប្បីជ្រាបថា ភាវៈដែលមាននៅនិងឧប្បាទៈ ការកើតឡើងដូចពោលហើយ ជាតួបច្ច័យ ។ សូម្បីបច្ច័យ ២៤ មានហេតុប្បច្ច័យជាដើម ដែលមកក្នុងបដ្ឋានបករណ៍នោះ គប្បីជ្រាបថា បច្ច័យពិសេសនៃបច្ច័យនោះនុ៎ះឯង ។ ព្រោះហេតុដូច្នោះ ដើម្បីនឹងសម្ដែង

ប្រការដែលព្រះអង្គទ្រង់មនសិការ ដល់អនុលោមបដិច្ចសមុប្បាទដោយពិស្តារ ទើបត្រាស់ពាក្យមាន ជាអាទិ៍ថា **យទិទំ អវិជ្ជាបច្ចយា សង្ខារា** ដូច្នោះ ។

បណ្ដាបទទាំងនោះ បទថា **យទិទំ** ជានិបាត បទថា **យទិទំ** នោះមានអត្ថថា **យោ អយំ**។ ក្នុងបទថា **អវិជ្ជាបច្ចយា** ជាដើមមានវិនិច្ឆ័យដូច តទៅនេះឈ្មោះថា **អវិជ្ជា** ព្រោះប្រសព្វវត្ថុដែលគួរប្រសព្វ មានកាយសុចរិតជាដើម ។ ឈ្មោះថា **អវិជ្ជា** ព្រោះញ៉ាំងសភាវៈនៃធម៌ដែលមិនវិបរិត មិនឲ្យដឹងច្បាស់ឈ្មោះថា **អវិជ្ជា** ព្រោះញ៉ាំងសត្វឲ្យត្រាច់ទៅក្នុងភពជាដើម ក្នុងសង្សារដែលវៀរចាកទីបំផុត ។ ឈ្មោះថា **អវិជ្ជា** ព្រោះត្រាច់ទៅក្នុងវត្ថុដែលមិនមាន មិនត្រាច់ទៅក្នុងវត្ថុដែលមាន។ ម្យ៉ាងទៀត ឈ្មោះថា **អវិជ្ជា** ព្រោះជាបដិបក្ខចំពោះវិជ្ជា ។ អវិជ្ជានោះគប្បីជ្រាបថា មាន ៥ យ៉ាង ដោយន័យមានជាអាទិ៍ថា ទុក្ខេ អញ្ញាណំ សេចក្ដីមិនដឹងទុក្ខ ។ ឈ្មោះថា **បច្ច័យ** ព្រោះអាស្រ័យទៅគឺកើតឡើង និងប្រព្រឹត្តទៅមិនវៀរផល។ ម្យ៉ាងទៀត ធម៌ដែលមានការគាំទ្រជាអត្ថ ឈ្មោះថា **បច្ច័យ** ។ អវិជ្ជាផង បច្ច័យផង ជាអវិជ្ជានិងបច្ច័យព្រោះហេតុនោះទើបឈ្មោះថា **មានអវិជ្ជាជាបច្ច័យ** ។ ឈ្មោះថា **សង្ខារ** ព្រោះតាក់តែង ។ បានដល់កុសលចេតនា និងអកុសលចេតនាជាលោកិយៈ កុសលចេតនា និងអកុសលចេតនានោះ គប្បីជ្រាបថាមាន ៣ យ៉ាង គឺ**បុញ្ញាភិសង្ខារ ១ អបុញ្ញាភិសង្ខារ ១ អានេញ្ជាភិសង្ខារ ១** ។ ឈ្មោះថា **វិញ្ញាណព្រោះដឹងច្បាស់** ។ វិញ្ញាណនោះមាន ៣២ (គឺអហេតុកវិបាក ១៥ មហាវិបាកចិត្ត ៨ មហគ្គតវិបាក ៩) ដោយអំណាចវិបាកវិញ្ញាណចំណែកលោកិយៈ ។

ឈ្មោះថា **នាម** ព្រោះបង្អោនទៅបានដល់ នាមខន្ធ ៣ មានវេទនាជាដើម ។ ឈ្មោះថា **រូប** ព្រោះអត្ថថារលាយទៅបានដល់ភូតរូប៤ និងឧបាទាយរូប ២៤ មានចក្ខុបសាទរូបជាដើម ។ ឈ្មោះថា **អាយតនៈ** ព្រោះជាទីត និងនាំសត្វទៅកាន់សង្សារទុក្ខ ។ ឈ្មោះថា **ផស្សៈ** ព្រោះពាល់ត្រូវ ។ ឈ្មោះថា **វេទនា** ព្រោះសោយ (អារម្មណ៍) ។ សូម្បីទាំងពីរនោះ ពោលអំពីទ្វារមាន ៦ ពោលអំពីវិបាកមាន ៣៦ ។ ឈ្មោះថា **តណ្ហា** ព្រោះតក់ស្លុត។ តណ្ហានោះ ដោយសង្ខេបមាន ៣ មានកាមតណ្ហាជាដើម និងដោយពិស្តារមាន ១០៨ ។ ឈ្មោះថា **ឧបាទាន** ព្រោះប្រកាន់មាំ ឧបាទាននោះមាន ៤ យ៉ាង មានកាមុបាទានជាដើម។ ឈ្មោះថា **ភព** ព្រោះជាទីកើត ឬញុំាងសត្វឲ្យកើត ។ ភពនោះមាន ២ គឺ**កម្មភព** និង**ឧបត្តិភព** ។ ការកើត ឈ្មោះថា **ជាតិ** ។ ការចាស់គ្រាំគ្រា ឈ្មោះថា **ជរា** ។ ឈ្មោះថា **មរណៈ** ព្រោះជាហេតុស្លាប់នៃសត្វ ។ សេចក្តីសោកសៅ ឈ្មោះថា **សោកៈ** ។ សេចក្តីខ្សឹកខ្សួល ឈ្មោះថា **បរិទេវៈ** ។ ឈ្មោះថា **ទុក្ខ** ព្រោះទ្រាំបានដោយលំបាក ម្យ៉ាងទៀត ឈ្មោះថា **ទុក្ខ** ព្រោះមាន ២ ខណៈគឺទុក្ខក្នុងខណៈកើត និងទុក្ខក្នុងខណៈតាំងនៅ ។ ភាវៈនៃសេចក្តីខូចចិត្ត ឈ្មោះថា **ទោមនស្ស** ។ សេចក្តីចង្អៀតចង្អល់ចិត្តក៏ក្រៃលែង ឈ្មោះថា **ឧបាយាសៈ** ។ បទថា **សម្ភវន្តិ** ប្រែថា រមែងកើត ។ សេចក្តីពិត មិនមែនប្រកបដោយបទ មានសោកៈជាដើមតែ ម្យ៉ាងប៉ុណ្ណោះទេ ដោយពិតគប្បីប្រកបបទថា **សម្ភវន្តិ** គ្រប់ៗបទ។ ក៏កាល បើដូច្នេះ រមែងជាការសម្តែងការកំណត់បច្ចយធម៌ និងបច្ចយុប្បន្នធម៌ ដោយពាក្យថា **អវិជ្ជាបច្ចយា សង្ខារា សម្ភវន្តិ** ។ ក្នុងបទទាំងពួង ក៏ន័យនេះ។

បណ្ដាធម៌ទាំងនោះ **អវិជ្ជា** មានសេចក្ដីមិនដឹងជាលក្ខណៈ មានសេចក្ដីវង្វេងជាកិច្ច មានការបិទបាំងជាអាការប្រាកដ មានអាសវៈជាហេតុជិត ។ សង្ខារមានការតាក់តែងជាលក្ខណៈ មានការប្រមូលមកជាកិច្ច មានការចាត់ចែងជាអាការប្រាកដ មានអវិជ្ជាជាហេតុជិត។ វិញ្ញាណ មានការដឹងច្បាស់ជាលក្ខណៈ មានភាពជាប្រធានជាកិច្ច មានបដិសន្ធិជាអាការប្រាកដ មានសង្ខារជាហេតុជិត ឬមានវត្ថុនិងអារម្មណ៍ជាហេតុជិត ។ នាម មានការបង្អោនទៅជាលក្ខណៈ មានសម្បយោគជាកិច្ច មានការមិនបែកពីគ្នាជាអាការ ប្រាកដមានវិញ្ញាណជាហេតុជិត ។ រូប មានការរលាយទៅជាលក្ខណៈ មានការមិនដឹងអារម្មណ៍ជាកិច្ច មានភាវៈជាសម្បយោគជាអាការប្រាកដ មានវិញ្ញាណជាហេតុជិត ។ សឡាយតនៈ មានការចំពោះជាលក្ខណៈ មានការឃើញជាដើមជាកិច្ច មានភាវៈជាវត្ថុនិងទ្វារជាអាការ ប្រាកដមាននាមរូបជាហេតុជិត ។ ផស្សៈ មានការពាល់ត្រូវជាលក្ខណៈ មានការប៉ះខ្ទប់ជាកិច្ច មានការជួបប្រសព្វជាអាការប្រាកដ មានសឡាយតនៈ មានជាហេតុជាតិ ។ វេទនា មានការសោយអារម្មណ៍ជាលក្ខណៈ មានការ បរិភោគរសនៃអារម្មណ៍ជាកិច្ច មានសុខ និងទុក្ខជាអាការប្រាកដ មានផស្សៈ ជាហេតុជិត ។ តណ្ហា មានសេចក្ដីជាតួហេតុ ជាលក្ខណៈមានសេចក្ដីភ្លើតភ្លើនជាកិច្ច មានសេចក្ដីមិនឆ្អែតជាអាការប្រាកដ មានវេទនាជាហេតុជិត។ ឧបាទាន មានការប្រកាន់មាំជាលក្ខណៈ មានការមិនបញ្ចេញដាក់ជាកិច្ច មានទិដ្ឋិ គឺសេចក្ដីប្រកាន់មាំដោយអំណាចតណ្ហា ជាអាការប្រាកដមានតណ្ហាជាហេតុជិត ។ ភព មានកម្ម និងផលនៃកម្មជាលក្ខណៈមានការកើតនិងការឲ្យកើតជានិច្ច មានកុសល អកុសល និងអព្យាក្រិតជាអាការប្រាកដ

មានឧបាទានជាហេតុជិត ។ ជាតិមានការកើត មុនក្នុងភពនោះៗជាលក្ខណៈ មានការពង្រីកចេញទៅជាកិច្ច មានការកើតក្នុងភពនេះ ពីអតីតភពជាអាការប្រាកដ ឬក៏មានភាពវិចិត្រនៃទុក្ខជាអាការប្រាកដ ។ ជ រា មានសេចក្តីជោរនៃខន្ធជាលក្ខណៈ មានការនាំទៅរកសេចក្តីស្លាប់ជាកិច្ច មានការធ្វើភាពជាកម្លោះក្រមុំឲ្យវិនាសជាអាការប្រាកដ ។ មរណៈ មានចុតិជាលក្ខណៈ មានការការបបូតប្រាសចាកជាកិច្ច មានការនៅប្រាសចាកគតិជាអការប្រាកដ ។ សោកៈ មានសេចក្តីឆេះក្នុងខាងក្នុងជាលក្ខណៈ មានសេចក្តីទុក្ខក្នុងចិត្តជានិច្ច មានសេចក្តីសោកសៅដល់ជាអាការប្រាកដ ។ បរិទេវៈ មានសេចក្តីរអ៊ូរទាំជាលក្ខណៈ មានការនិយាយដល់គុណ និងទោសជានិច្ច មានសេចក្តីតក់ស្លុតជាអាការប្រកាដ ។ ទុក្ខ មានការបៀតបៀនកាយជាលក្ខណៈ មានការធ្វើឲ្យខូចចិត្តដល់បុគ្គលអ្នកមានបញ្ញាខ្សោយជាកិច្ច មានអាពាធផ្លូវកាយជាអាការប្រាកដ ។ ទោមនស្ស មានការបៀតបៀនចិត្តជាលក្ខណៈ មានសេចក្តីចង្អៀតចង្អល់ចិត្តជាកិច្ច មានព្យាធិផ្លូវចិត្តជាអាការប្រាកដ ។ ឧបាយាសៈ មានសេចក្តីទុក្ខព្រួយក្នុងចិត្តជាលក្ខណៈ មានការរួញរាដកចិត្តចេញជាកិច្ច មានការប្រាសចាកសេចក្តីរីករាយជាអាការប្រាកដ ។ បច្ចយ-ធម៌ មានអវិជ្ជាជាដើមទាំងនោះ គប្បីជ្រាប សូម្បីដោយលក្ខណៈជាដើមដោយប្រការយ៉ាងនេះឯង ។ ក្នុងទីនេះ មានសេចក្តីសង្ខេបត្រឹមតែប៉ុណ្ណោះ ចំណែកសេចក្តីពិស្តារ អ្នកប្រាថ្នាវិនិច្ឆ័យដែលសម្បូរដោយប្រការទាំងពួង គប្បីមើលក្នុងអដ្ឋកថាវិភង្គ ឈ្មោះ សម្មោហវិនោទនី ។

បទថា **ឯវំ** ជាបទសម្តែងខែដល់ន័យដែលបានសម្តែងមកហើយ ។ ដោយបទថា **ឯវំ** នោះលោកសម្តែងអំពីហេតុ មានអវិជ្ជាជាដើមនោះឯងមិន

មែនសម្ដែងដោយហេតុមាននិម្មិត របស់ឥស្សរជនជាដើម ។ បទថា **ឯតស្ស** បានដល់តាមដែលពោលហើយ ។ បទថា **កេវលស្ស** បានដល់មិនច្របូកច្របល់គឺទាំងអស់ ។ បទថា **ទុក្ខក្ខន្ធស្ស** បានដល់ប្រជុំទុក្ខ មិនមែនសត្វ មិនមែនជីវៈ ទាំងមិនមែនជាស្រស់ស្អាត និងសុខជាដើមទេ ។ បទថា **សមុទយោ ហោតិ** បានដល់កើតគឺកើតព្រម ។

បទថា **ឯតមត្ថំ វិទិត្វា** សេចក្ដីថា ការដឹងច្បាស់នូវសេចក្ដីនោះដែលពោលទុកថា កងទុក្ខមានសង្ខារជាដើម រមែងកើតដោយអវិជ្ជាជាដើម ដោយអាការទាំងពួង ។ បទថា **តាយំ វេលាយំ** បានដល់ក្នុងវេលាដែលដឹងច្បាស់នូវអត្ថនោះ ។ បទថា **ឥមំ ឧទានំ ឧទានេសិ** សេចក្ដីថា បន្លឺនូវឧទាននេះដែលសម្ដែងអានុភាពនៃការដឹងហេតុ និងធម៌ ដែលកើតពីហេតុក្នុងកាលស្គាល់ផលនោះ ដែលជាសមុដ្ឋាននៃញាណ ដែលសម្បយុត្តដោយសោមនស្សមានជាអាទិ៍ថា **យទា ហវេ បាតុភវន្តិ** អធិប្បាយថា បន្លឺនូវព្រះវាចាជាទីគាប់ព្រះទ័យ។

ឧទាននោះមានអធិប្បាយដូច្នេះ បទថា **យទា** ប្រែថា ក្នុងកាល ណា ។ ស័ព្ទថា **ហវេ** ជានិបាត ចុះក្នុងអត្ថនេះថា **ព្យត្តំ** ជាក់ច្បាស់ ។ តែអាចារ្យពួកខ្លះពោលអធិប្បាយថា ស័ព្ទថា **ហវេ** ប្រែថា ក្នុងសង្គ្រាម គឺការប្រយុទ្ធ ។ ក៏លោកអាចារ្យទាំងនោះមានសេចក្ដី ដែលលោក សំដៅយកថា ក្នុងសម័យច្បាំងនឹងកិលេសមារ ដោយព្រះបាលីថា យោធេថ មារំ បញ្ញាវុធេន បុគ្គលគប្បីច្បាំងនូវមារដោយអាវុធ គឺបញ្ញា។ បទថា **បាតុភវន្តិ** ប្រែថា កើតឡើង ។ បទថា **ធម្មា** បានដល់ពោធិបក្ខិយធម៌ ដែលឲ្យសម្រេច ការចាក់ធ្លុះបច្ចយាការដោយអនុលោម ។ ម្យ៉ាងទៀត បទថា **បាតុភវន្តិ** បានដល់ប្រកាស គឺធ្វើ

ឲ្យជាក់ច្បាស់គឺ ប្រាកដដោយការត្រាស់ដឹង ។ បទថា **ធម្មា** បានដល់ ធម៌គឺអរិយស-ច្ចៈ ៤ ។ បទថា អាតាប ហៅថា សេចក្តីព្យាយាម ព្រោះអត្ថថាដុត កម្តៅនូវកិលេស ។ បទថា **អាតាបិនោ** បានដល់ មានសេចក្តីព្យាយាមគឺសម្មប្បធាន ។ បទថា **ឈាយតោ** បានដល់ សម្លឹងដោយអារម្មណូ បនិជ្ឈាននិងលក្ខណូបនិជ្ឈាន ។ បទថា **ព្រាហ្មណស្ស** បានដល់ ព្រះខីណាស្រពអ្នកមានបាបបន្សាត់ហើយ ។ បទថា **អថស្ស កង្ខា វបយន្តិ សព្វា** សេចក្តីថា គ្រាដែលព្រាហ្មណ៍នោះមាន ធម៌ប្រាកដយ៉ាងនេះហើយ សេចក្តីសង្ស័យក្នុងបច្ចយាការ ដែលត្រាស់ទុកដោយ ន័យមានជាអាទិ៍ថា បពិត្រព្រះអង្គដ៏ចម្រើន នរណាហ្ន៎ តែងពាល់ត្រូវព្រះដ៏មានព្រះភាគត្រាស់ថាប្រស្នានេះ មិនត្រឹមត្រូវទេ ដោយន័យមានអាទិ៍ថាបពិត្រព្រះអង្គដ៏ចម្រើនជាជរានិងមរណៈតើដូចម្តេចហ្ន៎ មួយទៀត ជរានិងមរណៈនេះឯងជារបស់នរណា ។ ព្រះដ៏មានព្រះភាគត្រាស់ថា ប្រស្នានេះមិនត្រឹមត្រូវទេ ។ និងសេចក្តី សង្ស័យ ១៦ ប្រការដែលមកដោយន័យមានជាអាទិ៍ថា **អហោសឹ នុខ្វាហំ អតីតមទ្ធានំ** អាត្មាអញបានកើតហើយក្នុង អតីតកាលដែលឬហ្ន៎ ក្នុងអតីតកាល យើងបានមានហើយឬហ្ន៎ ព្រោះមិនទាន់ចាក់ធ្លុះបច្ចយាការនុ៎ះឯង ។ សេចក្តីសង្ស័យទាំងអស់នោះ រមែងបាត់ទៅប្រាសចាក ទៅរលត់ទៅ ។ ព្រោះហេតុណា ព្រោះដឹងទូទៅនូវធម៌ព្រមទាំងហេតុ អធិប្បាយថាដឹងច្បាស់ ដឹងទូទៅ គឺចាក់ធ្លុះនូវធម៌ គឺកងទុក្ខទាំងអស់ មានសង្ខារជាដើមនេះ ដែលដល់ព្រមដោយហេតុ មានអវិជ្ជាជាដើម។

ក៏ពោធិបក្ខិយធម៌ ឬចតុសច្ចធម៌ប្រាកដកើតឡើង គឺជាក់ច្បាស់ដល់ព្រាហ្មណ៍នោះ ។ ក្នុងកាលណា ក្នុងកាលវិបស្សនាញាណ និងមគ្គញ្ញាណ

កើតឡើង ។ បណ្តាញាណ ២ យ៉ាងនោះ គប្បីជ្រាបថាវិបស្សនាញាណកើតមុន។ ធម៌ទាំងឡាយមានសតិជាដើម ដែលសម្បយុត្តដោយវិបស្សនាញាណ និងវិបស្សនាញាណ កាលលះសុភសញ្ញាជាដើម ដោយអំណាចតទង្គបហានក្នុងអារម្មណ៍របស់ខ្លួន ទើបកើតឡើងជាចំណែកៗ ដោយអនុបស្សនាមានកាយានុបស្សនា ជាដើម ។ ក៏ក្នុងខណៈមគ្គកើតឡើង ធម៌ទាំងនោះកាលប្រទាញយក ព្រះនិព្វាន និងធម៌ដែលជាបដិបក្ខដោយសមុច្ឆេទបហាន កើតឡើងតែម្តងប៉ុណ្ណោះ ដោយអំណាចនៃការចាក់ធ្លុះមិនវង្វេងក្នុងអរិយសច្ច ទាំង ៤ ។ ក្នុងសេចក្តីនេះ គប្បីជ្រាបថា ពោធិបក្ខិយធម៌ប្រាកដដោយអត្ថថា កើតឡើងដោយប្រការដូច្នេះមុន ។

ក៏គប្បីជ្រាបថា អរិយសច្ចធម៌ជាចំណែកនៃលោកិយៈប្រាកដ ដោយការធ្វើវិបស្សនាឲ្យជាអារម្មណ៍ ក្នុងខណៈវិបស្សនា គប្បីជ្រាប ថា អរិយសច្ចធម៌ជាចំណែកនៃលោកុត្តរៈប្រាកដ ដោយភាវៈដែល បង្អោនទៅក្នុងលោកុត្តរធម៌នោះ គប្បីជ្រាបថា និរោធសច្ចៈ ប្រាកដដោយការត្រាស់ដឹងអារម្មណ៍ក្នុងខណៈមគ្គ និងគប្បីជ្រាបថាទាំងអស់ ប្រាកដដោយអត្ថថា ជាក់ច្បាស់ ប្រាកដច្បាស់ ដោយអំណាចនៃការ ត្រាស់ដឹងកិច្ច ។

សូម្បីកាលធម៌ទាំងអស់ ប្រាកដដល់ព្រះញាណរបស់ព្រះអង្គដោយអាការទាំងពួង ព្រះដ៏មានព្រះភាគទ្រង់ពិចារណា បច្ចយាការនោះ ព្រោះបច្ចយាការជាសភាពល្អិតជ្រាលជ្រៅ និងឃើញបានដោយលំបាក ជាហេតុទ្រង់ធ្វើសេចក្តីតាំងចិត្តមាំ ក្នុងវិបស្សនាដោយបដិច្ច សមុប្បាទជាប្រមុខ ទ្រង់កើតសោមនស្សយ៉ាងខ្លាំងក្លា ទើបទ្រង់បន្លឺ នូវឧទានក្នុងសេចក្តី

នេះ ដែលសម្តែងដល់អានុភាពនៃការត្រាស់ដឹង បច្ចយាការនោះរបស់ព្រះអង្គ ព្រមដោយជាបច្ច័យកាត់បដិបក្ខធម៌ បានដាច់ខាត ។

ព្រះបាលីថា **អយម្បិ ឧទានោ វុត្តោ ភគវតា ឥតិ មេ សុតំ** នេះប្រាកដក្នុងគម្ពីរត្រង់កន្លែងខ្លះ ។ បណ្តាបទទាំងនោះ បិ-ស័ព្ទ ក្នុងបទ ថា **អយម្បិ** ជា សម្បិណ្ឌនត្ថៈ ដូចក្នុងប្រយោគថា **ឥទម្បិ ពុទ្ធេ រតនំ ប-ណីតំ អយម្បិ បារាជិកោ ហោតិ** សូម្បីនេះជារតនៈដែលប្រណីតក្នុងព្រះពុទ្ធ ភិក្ខុសូម្បីនេះ ជាបារាជិក ។ ព្រោះហេតុនោះ បិ-ស័ព្ទនោះ រមែងប្រមូលពាក្យមុនៗ មក ។ **វុត្តៈ** ស័ព្ទនេះក្នុងបទថា **វុត្តោ** ប្រាកដ ក្នុងពាក្យមានជាអាទិ៍ថា **កេសោហារណៈ វបនៈ វាបសមីករណៈ ជីវិតវុត្តិ បមុត្តភាវៈ បាវចនភាវេនបវត្តនៈ អជ្ឈេសនៈ** និង **កថនៈ** ។ ពិតយ៉ាងនោះ **វុត្តៈ** ស័ព្ទនោះ មកក្នុង **កេសោហារណៈ** (ការកោរសក់) ក្នុងប្រយោគមានជាអាទិ៍ថា មានមាណពកំលោះម្នាក់ឈ្មោះកាដិកៈ មានក្បាលកោរ ។ មកក្នុង **វបនៈ** (ការព្រោះពូជ) ក្នុងប្រយោគមានជា អាទិ៍ថា

កាវោ តស្ស បជាយន្តិ ខេត្តេ វុត្តំ វិរូហតិ
វុត្តានំ ផលមស្នាតិយោ មិត្តានំ ន ទុព្ភតិ ។

បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ គោទាំងឡាយរបស់ បុគ្គលនោះសម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះសាបព្រោះ ក្នុងស្រែរមែងដុះដាលបុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ ។

មកក្នុង **វាបសមីករណៈ** (ការធ្វើពូជដែលព្រោះឲ្យស្មើគ្នា) ដោយប្រើរនាស់ជាដើម ក្នុងប្រយោគមានជាអាទិ៍ថា **នោ ច ខោ បដិវុត្តំ** ស្រែគេមិន

ទាន់ព្រោះទេ ។ មកក្នុង **ជីវិតវិត្តិ** (ការចិញ្ចឹមជីវិត) ក្នុងប្រយោគមានជាអាទិ៍ថា **បន្នលោមោ បរទវុត្តោ មិគភូតេន ចេតសា វិ-ហរាមិ** ខ្ញុំជាមនុស្សសម្លបបុសឥតព្រឺតព្រួចរោម ចិញ្ចឹមជីវិតដោយ បច្ច័យដែលអ្នកដទៃឲ្យ នៅដោយមានចិត្តដូចជាពួកម្រឹគ ។ មកក្នុង បមុត្តភាវៈ (សេចក្ដីរបូតចាកពីទង) ក្នុងប្រយោគមានជាអាទិ៍ថា **បណ្ឌុ-បលាសោ ពន្ធនា បវុត្តោ អភព្វោ ហរិត្តាយ** ធម្មតាស្លឹកឈើទុំដែលជ្រុះចាកទងហើយ មិនអាចទៅត្រឡប់ជាមានពណ៌ខៀវវិញបានទេ ។ មកក្នុង **បាវចនភាវេនបវត្តនៈ** (សេចក្ដីប្រព្រឹត្តទៅដោយប្រាប់ពោល គ្នាមក) ក្នុងប្រយោគមានជាអាទិ៍ថា **កីត បវុត្តំ សមិហិតំ** (លំអាននៃ មន្តបុរាណនេះ) ដែលពួកឥសីណាបានច្រៀង (ស្វាធ្យាយ) មកហើយ បានសូត្រមកហើយ បានសន្សំមកច្រើនហើយ ។ មកក្នុង **អជ្ឈេសនៈ** (សេចក្ដីគោរពអញ្ជើញ) ក្នុងប្រយោគមានជាអាទិ៍ថា **វុត្តោ កុណោ វុត្តោ បារាយនោ** សេចក្ដីគោរពអញ្ជើញចាកគុណ សេចក្ដីគោរពអញ្ជើញចាកសេចក្ដីសាបសូន្យ ។ មកក្នុង **កថនៈ** (ការពោល) ក្នុង ប្រយោគមានជាអាទិ៍ថា នេះជាព្រះពុទ្ធដីកា ដែលព្រះដ៏មានព្រភាគ ទ្រង់ត្រាស់ហើយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរយកធម៌ តថាគតជាមរតក កុំយកអាមិសជាមរតកឡើយ ។ សូម្បីក្នុងទីនេះ គប្បីជ្រាបថា វុត្ត-ស័ព្ទប្រើក្នុងការពោលប៉ុណ្ណោះ ។ អធិប្បាយថា សូម្បីឧទានជាភាសិត គឺព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហើយ ដោយ ព្រះតម្រាស់នេះ ។ ឥតិ-ស័ព្ទនេះស្មើនឹង ឯវំ ។ សេចក្ដីរបស់បទទាំង ពីរថា **មេ សុតំ** បានពោលទុកក្នុងអដ្ឋកថា និទានដោយអាការទាំងពួងនោះឯង ។ មែនពិត ក្នុងកាលមុនសេចក្ដីរបស់បទទាំងពីរថា ឯវម្មេ សុតំ បានពោលទុកដោយអំណាចពាក្យចាប់ផ្ដើម ក្នុងទី

នេះ ពោលទៀតថា **ឥតិ មេ សុតំ** ដោយអំណាចនៃនិគមនៈ ពាក្យចុងមិនមែនការពោលដដែលដល់អត្ថដែលពោលហើយនោះឯង **ឯវម្មេ សុតំ** នេះ ព្រោះ ឥតិ-ស័ព្ទ មានអត្ថស្មើនិង ឯវំ-ស័ព្ទ និងការប្រកបសេចក្តី របស់ ឥតិ-ស័ព្ទ ប្រកាសទុកហើយក្នុងអដ្ឋកថា ឥត្ថិវិត្តកៈនោះឯង ព្រោះហេតុនោះ គប្បីជ្រាបដោយន័យតាមដែលពោលហើយក្នុងអដ្ឋ កថានោះ ដូច្នេះឯង ។

បឋមពោធិសុត្តវណ្ណនា និដ្ឋិតា ។

ចប់ បឋមពោធិសូត្រ នៃឧទានសំវណ្ណនា ។

ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស

(*បិដកលេខ ៦៦ ទំព័រ ២៣៧-២៣៩*)

ពុទ្ធោតិ យោ សោ ភគវា សយម្ភូ អនាចរិយកោ បុព្វេ អននុស្សុតេសុ ធម្មេសុ សាមំ សច្ចានិ អភិសម្ពុជ្ឈិ តត្ថ ច សព្វ-ញ្ញុតំ បត្តោ ពលេសុ ច វសីភាវំ បត្តោ ។

ពាក្យថា **ពុទ្ធោ** គឺព្រះដ៏មានព្រះភាគអង្គណា ព្រះមានព្រះភាគអង្គនោះជាព្រះសយម្ភូ ទ្រង់ត្រាស់ដឹងដោយព្រះអង្គឯង មិនមាននូវគ្រូអាចារ្យឡើយ ទ្រង់ត្រាស់ដឹងដោយប្រពៃក្រៃលេង នូវសច្ចៈក្នុងធម៌ទាំងនោះដោយព្រះអង្គឯង ពុំបានស្តាប់ពីមុនមកឡើយ ព្រះអង្គទ្រង់ដល់នូវសព្វញ្ញុតញ្ញាណក្នុងធម៌ទាំងឡាយផង ទ្រង់ដល់នូវភាពជំនាញក្នុងពលៈទាំងឡាយផង ។

ពុទ្ធោតិ កេនដ្ឋេន ពុទ្ធោ ពាក្យថា **ពុទ្ធោ** តើ **ពុទ្ធោ** ដោយអត្ថដូចម្តេច ?

១. **ពុជ្ឈិតា សច្ចានីតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសច្ចៈទាំងឡាយ ។

២. **ពោធេតា បជាយាតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គញុំាងពពួកជនឲ្យត្រាស់ដឹងផង ។

៣. **សព្វញ្ញុតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវធម៌ទាំងពួង ។

៤. **សព្វទស្សាវិតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គឃើញនូវធម៌ទាំងពួងដោយញាណចក្ខុ ។

៥. **អនិញ្ញេយ្យតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមានអ្នកដទៃណាដឹកនាំព្រះអង្គឡើយ ។

៦. **វិកសិតាយ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមាននូវស្មារតីដ៏វិសេស ។

៧. **ខីណាសវសង្ខាតេន ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាអស់ទៅនូវអាសវៈ ។

៨. **និរុបក្កិលេសសង្ខាតេន ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គដល់នូវការរាប់ថាមិនមានឧបក្កិលេស ។

៩. **ឯកន្តវីតរាគោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវរាគៈដោយដាច់ខាត ។

១០. **ឯកន្តវីតទោសោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវទោសៈដោយដាច់ខាត ។

១១. **ឯកន្តវីតមោហោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គប្រាសចាកនូវមោហៈដោយដាច់ខាត ។

១២. **ឯកន្តនិក្កិលេសោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គមិនមាននូវកិលេសដោយដាច់ខាត ។

១៣. **ឯកាយនមគ្គំ គតោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គយាងទៅក្នុងផ្លូវតែមួយ ជាផ្លូវទៅកាន់ព្រះនិព្វាន បានដល់សតិប្បដ្ឋាន ៤ ។

១៤. **ឯកោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោតិ ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គត្រាស់ដឹងនូវសម្មាសម្ពោធិញ្ញាណដ៏ប្រសើរមួយព្រះអង្គឯង ។

១៥. **អពុទ្ធិវិហតត្តា ពុទ្ធិប្បដិលាភត្តា ពុទ្ធោ** -ទ្រង់ព្រះនាមថា **ពុទ្ធោ** ព្រោះព្រះអង្គកម្ចាត់បង់នូវការមិនមានបញ្ញា ដោយការបាននូវបញ្ញា ។

ពុទ្ធោតិ នេតំ នាមំ មាតរា កតំ ន បិតរា កតំ ន ភាតរា កតំ ន ភគិនិយា កតំ ន មិត្តាមច្ចេហិ កតំ ន ញាតិសាលោហិតេហិ កតំ ន សមណព្រាហ្មណេហិ កតំ ន ទេវតាហិ កតំ វិមោក្ខន្តិកមេតំ ពុទ្ធានំ ភគវន្តានំ ពោធិយា មូលេ សហ សព្វញ្ញុតញ្ញាណស្ស បដិលាភា សច្ឆិកា បញ្ញត្តិ យទិទំ ពុទ្ធោតិ ។

ព្រះនាម **ពុទ្ធោ** នេះ មិនមែនជាព្រះនាមដែលព្រះមាតាថ្វាយទេ មិនមែនព្រះបិតាថ្វាយទេ មិនមែនបងប្អូនប្រុសថ្វាយទេ មិនមែនបងប្អូនស្រីថ្វាយទេ មិនមែនមិត្តអាមាត្យថ្វាយទេ មិនមែនញាតិសាលោហិតថ្វាយទេ មិនមែនសមណព្រាហ្មណ៍ថ្វាយទេ មិនមែនទេវតាថ្វាយទេ ទ្រង់ព្រះនាម **ពុទ្ធោ** នេះជាវិមោក្ខន្តិកនាម គឺព្រះនាមដែលមានក្នុងទីបំផុត នៃអរហត្តផល របស់

ព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះភាគ ជាសច្ចិកាបញ្ញត្តិ គឺបញ្ញត្តិព្រោះការជាក់ច្បាស់ក្នុងធម៌ទាំងពួង ដែលបានកើតព្រមគ្នាជាមួយនឹងសព្វញ្ញុតញ្ញាណនៅគល់ព្រះពោធិព្រឹក្ស ។

(ពុទ្ធោ នាគល់ព្រះពោធិព្រឹក្ស ចប់)

នាទីកំណាព្យ

ការសិក្សានិងស្នេហា

(បុរាណភាសិត)

កិច្ចសិក្សា	ត្រូវចាត់ថា	ជាទីមួយ
ត្រូវបោះពួយ	គឺប្រឹងប្រែង	ឲ្យណាស់ណា
កុំស្រវឹង	ពុលជ្រមុជ	នឹងស្នេហា
ត្រូវសិក្សា	ឲ្យចេះសិន	សឹមគិតក្រោយ ។
ប្រុសមិនខ្វះ	ស្រីមិនក្រ	ល្អគរគោក
នៅងងោក	ក្បាលងងុយ	មិនខ្វះសោះ
ចាំទទួល	អ្នកសិក្សា	រៀនសូត្រនោះ
ដោយស្ម័គ្រស្មោះ	អស់ពីពោះ	ពិតមិនខាន ។
បើយើងគិត	តែពីរឿង	ស្នេហាវិញ
មិនចំណេញ	នូវចំណេះ	ផេះចង្រ្កាន
ក្រវិជ្ជា	ដូចក្រអ្វី	គ្រប់ៗឋាន
យើងគ្រប់ប្រាណ	គួរសិក្សា	រៀនសូត្រអើយ ៕

សុខពិតប្រាកដ

-ថ្ងៃមួយបាត់ទៅថ្ងៃមួយចូលមក កន្លងរហូតគ្មានពេលវិលក្រោយ
យប់កន្លងទៅថ្ងៃចូលមកហើយ កន្លងគ្មានស្បើយនៅលើលោកនេះ ។
-អាយុសង្ខារមនុស្សតិចតួចណាស់ គួរតែដឹងច្បាស់កុំធ្វេសប្រហែស
ខំប្រឹងធ្វើល្អទុកជាជំនិះ ជាស្ពានជាយានឆ្លងទៅឋានសុខ ។
-នៅក្នុងភពបីគ្មានអ្វីអស្ចារ្យ វិលវល់អាត្មាប្រៀបដូចកងចក្រ
វិលចុះវិលឡើងគ្មានអ្វីឲ្យច្បាស់ គួរអនិច្ចាណាស់ឱសព្វសត្វអើយ ។
-ធ្វើល្អបានល្អក៏ទៅឋានសុខ រស់នៅស្រណុកបានមួយគ្រាដែរ
ពេលណាអស់បុណ្យស្បុតមកដដែរ វិលវល់គ្មានល្ហែគួរឲ្យពិចារណា ។
-បើធ្វើអាក្រក់វិញគឺត្រូវរងទុក្ខ គឺមិនស្រណុកនៅក្នុងអាត្មា
លំបាកខ្លាំងណាស់សព្វខ្លួនកាយា វេទនាខ្លោចផ្សារឈឺចាប់ឥតល្ហែ ។
-ដូចនេះយើងគួរស្វែងរកក្តីសុខ ដែលពិតប្រាកដដែរមិនកាឡា
សុខក្នុងត្រៃភពក្លែងក្លាយទេណា សុខក្នុងតណ្ហាគួរឲ្យរអើមណាស់ ។
-សុខពិតប្រាកដគឺព្រះនិព្វាន គ្មានទុក្ខរុករានអ្វីសោះឡើយណា
ព្រះពុទ្ធជាម្ចាស់ទ្រង់ត្រាស់ប្រាប់ថា **នត្ថិ សន្តិ បរំ សុខំ** ។
-គ្មានសុខណាក្រៅពីសេចក្តីស្ងប់ឡើយ នេះហើយគឺជាព្រះពុទ្ធដីកា
គួរខំប្រតិបត្តិតាមធម៌ព្រះសស្តា នោះទើបហៅថាបរិស័ទល្អ ៕

និពន្ធដោយ **កញ្ញា ៥ ចល័ក្ខ**

ពាក្យរំលឹកគុណគ្រូ

បពិត្រលោកគ្រូដ៏ឧត្តម លោកអ្នកនាំខ្ញុំក្រេបវិជ្ជា
លោកគ្រូមានគុណឥតគណនា សិស្សសូមវន្ទាដោយជ្រះថ្លា ។
សិស្សសូមឱកាសបានថ្លាថ្លែង រៀបរាប់សម្តែងនូវគុណា
ដែលលោកគ្រូមានលើសិស្សា ប្រៀបដូចសុរិយាភ្លឺចាំងចែង ។
ដើមឈើមានមែកគួរជ្រះថ្លា មានផ្លែមានផ្កាគួរស្ញប់ស្ញែង
តែងញ៉ាំងពួកជនដែលចំបែង ព្រោះតែសូរ្យសែងឲ្យសុខា ។
ម៉ែឪមានគុណធំពេកពិត គ្មានប្រាជ្ញបណ្ឌិតគិតឧបមា
ទាំងព្រះសម្ពុទ្ធទ្រង់ទេសនា ពុំមានកូនណាអាចសងបាន ។
ចំណែកលោកគ្រូគឺអាចារ្យ គុណលើសិស្សាគ្រប់ៗប្រាណ
គុណនេះក៏ធំពុំប្រមាណ គុណគ្រូថ្កើងថ្កានឧត្តមក្រៃ ។
សិស្សបានចេះដឹងក៏ព្រោះគ្រូ ចេះគិតចេះគូរចេះលកលៃ
ចេះពោលវាចាល្អប្រពៃ ព្រោះគ្រូនេះន័យអ្នកណែនាំ ។
ពេលបង្រៀនសិស្សក្នុងសាលា បរិយត្តិសិក្សាគ្រូខិតខំ
បកស្រាយសេចក្តីសែនសាកសម ប្រៀនប្រដៅខ្ញុំដោយករុណា ។
ពេលសិស្សស្ទើរស្ទាក់រាក់គំនិត រូបគ្រូនេះពិតមានមេត្តា
បកស្រាយសេចក្តីតាមធម៌អារ្យ បាលីភាសាឥតស្ទើរស្ទាក់ ។
ចិត្តសិស្សមិននឹងគ្រូពោលធម៌ ឲ្យសិស្សបានយល់ពីធម្មៈ
គ្រូពោលពិរោះល្អឥតរាក់ លើកសាធកៈឃើញជាក់ស្តែង ។
ពាក្យរបស់គ្រូមានបែបបទ មាំមួនម៉ត់ចត់គួរស្ញប់ស្ញែង
ពោលត្រូវតាមធម៌ព្រះសម្តែង ថ្លាថ្លែងគាថាចារសេចក្តី ។

សរសេរកាត់បទកំណត់ពាក្យ គ្រូពុះគ្រូច្រៀកពាក្យបាលី
មិនមានសេលសល់ឲ្យសង្ស័យ ប្រាប់អត្ថប្រាប់ន័យសេចក្តីនោះ ។
ពេលសិស្សធ្វើខុសគ្រូមិនខឹង មិនមែនសម្លឹងយកតែទោស
តែងតែយោគយល់អនុគ្រោះ ប្រដៅដោយស្មោះព្រោះអាណិត ។
ពេលសិស្សធ្វើល្អគ្រូត្រេកក្រៃ ព្រោះឃើញស្នាដៃល្អពិសិដ្ឋ
សិស្សរៀនពីគ្រូមានគំនិត សិស្សឲ្យគ្រូពិតមានកិត្តិយស ។
គេថាសិស្សល្អព្រោះគ្រូចេះ គ្រូមានចំណេះប្រសើរខ្ពស់
ទើបអាចញ៉ាំងសិស្សឲ្យមានឈ្មោះ មានសក្តិមានយសមានប្រាជ្ញា ។
ពាក្យពេចន៍លោកគ្រូថ្លៃសែនថ្លៃ មិនអាចឧបមេយ្យនិងឧបមា
ពាក្យពេចន៍លោកគ្រូសែនអស្ចារ្យ ស្តាប់ហើយជ្រះថ្លាចិត្តត្រេកអរ ។
សិស្សស្តាប់ពាក្យគ្រូធូរគំនិត ធូរកាយធូរចិត្តជ្បិតបានយល់
ចេះដឹងសព្វគ្រប់ឈប់លែងឆ្ងល់ ព្រោះឃើញហេតុផលប្រាកដស្តែង ។
រៀបរាប់យ៉ាងណាក៏មិនអស់ មិនចេះចប់សោះពាក្យថ្លាថ្លៃ
ព្រោះគ្រូមានគុណមិនអាចបែង មិនអាចចារចែងឲ្យអស់ន័យ ។
ពេលនេះរូបសិស្សសូមដឹងគុណ សិស្សសូមចែកបុណ្យដល់គ្រូថ្លៃ
ជាចំណែកគុណសាងបារមី ឆ្លងផុតទុក្ខភ័យវដ្តសង្សារ ។
សូមគ្រូមេត្តាអនុគ្រោះ ព្រោះសិស្សត្រង់ស្មោះឥតមុសា
ចែកបុណ្យដល់គ្រូមានករុណា សូមគ្រូជ្រះថ្លា អនុមោទនា ។
ពោលគុណគ្រូហើយមិនបង្អស់ ហត្ថាឆ្ពោះត្រង់ផ្ទង់អក្ខរា
អក្ខរៈគ្រប់ឃ្លាច្រើនត្រៀបត្រា ត្រៀមនឹងចចារតាមហេតុពិត ។
ហេតុណាដែលលោកអ្នកមហាជន អស់ប្រាជ្ញជាន់មុនពីព្រេងព្រឹទ្ធ

តែងតែរៀបរាប់ឥតប្រឌិត ប្រដៅឲ្យគិតនឹងឃើញគុណ ។
គុណពុកគុណម៉ែឲ្យជីវិត ដល់កូនៗពិត ជាគុណធ្ងន់
ចំណែកគុណគ្រូក៏ពេកពន់ មកលើសិស្សគុណគ្រប់អង្គា ។
ចំណែកអស់ពួកសាមណេរា មានត្រៃសរណាព្រោះឧបជ្ឈាយ៍
ភារៈភិក្ខុគ្រប់ៗគ្នា មានព្រោះឧបជ្ឈាយ៍ដ៏ថ្លៃថ្លា ។
កាលដែលឧបជ្ឈាយ៍ចាប់ដៃខ្ញុំ ទាំងពីរប្រណម្យឲ្យកេសា
ក្នុងន័យឲ្យខ្ញុំពិចារណា នូវកាយសង្ខារដែលមិនស្អាត ។
ឧបជ្ឈាយ៍ប្រៀបបាននឹងម៉ែឪ មើលការខុសត្រូវឲ្យឱវាទ
ប្រដៅប្រាប់ថាកុំប្រមាទ ចូរខំសង្វាតក្នុងសិក្ខា ។
ពេលដែលយើងខ្ញុំសូមធ្វើវត្ត លោកតែងហាមឃាត់ដោយវាចា
ថាអ្នករាល់គ្នាគ្រប់អាត្មា ខ្វល់ខ្វាយកិច្ចការតិចតួចចុះ ។
ចូរអ្នកប្រឹងប្រែងក្នុងសិក្ខា ធ្វើតាមសាស្តាកុំឲ្យខុស
កុំឲ្យមានឆ្គងអ្វីទាំងអស់ ទើបជនស្រីប្រុសគេជ្រះថ្លា ។
ឱវាទឧបជ្ឈាយ៍មានតម្លៃ មិនអាចឧបមេយ្យនិងឧបមា
ឱវាទឧបជ្ឈាយ៍មានខ្លឹមសារ ប្រសើរអស្ចារ្យដល់យើងខ្ញុំ ។
ពេលខ្លះឧបជ្ឈាយ៍ស្តីបន្ទោស មិនមែនយកខុសនោះជាធំ
តែងតែទូន្មានដល់យើងខ្ញុំ ឲ្យចេះអប់រំកាយវាចា ។
ពេលខ្លះឧបជ្ឈាយ៍ពោលសរសើរ ព្រោះឃើញដំណើរដ៏ថ្លៃថ្លា
ទឹកមុខញញឹមមានករុណា ព្រោះឃើញសិស្សាប្រព្រឹត្តត្រូវ ។
ភេទជាអ្នកបួសសែនថ្លៃថ្លា ឧបជ្ឈាយ៍ផ្តាំថាអ្នកចូរនៅ
អាស្រ័យភេទនេះឲ្យត្រឹមត្រូវ ធ្វើដំណើរទៅកាន់និព្វាន ។

ពាក្យពេចន៍ឧបជ្ឈាយ៍ច្រើនពេកណាស់ ច្រើនក្រៃច្រើនក្រាស់ពាក្យទូន្មាន
ពេលនេះមិនអាចពោលអស់បាន ព្រោះមានប្រមាណវេលាខ្លី ។
សទ្ធិវិហារិកគ្រប់កាយា សូមលើកបុញ្ញាដ៏ច្រើនក្រៃ
ដែលបានសន្សំទាំងយប់ថ្ងៃ សីលក្ដីទានក្ដីក្នុងសាសនា ។
សូមប្រគេនដល់ព្រះឧបជ្ឈាយ៍ សូមបុណ្យបានជាគុណថ្លៃថ្លា
ឆ្លងផុតទុក្ខទោសក្នុងសង្សារ សូមទានមេត្តា អនុមោទនា ៕

និពន្ធដោយ **ភិក្ខុ ចិសេសោ ទ៉ា ប៉ាទី**

(ក្នុងឱកាសបុណ្យរំលឹកគុណគ្រូវត្តសុណ្ណបទុម ព.ស.២៥៥៨)

ព្រះព្រហ្មរបស់កូន

គុណពុកម៉ែថែទាំបុត្រដុតកាយ គុណនេះណាថ្លាថ្លៃពិតដិតដកជាប់
លោកទាំងពីរទីទ្រនំធំគួរគាប់ កូនមានភ័ព្វជាប់បានរស់ព្រោះគុណា ។
លោកទាំងពីរទីពឹងពិតចិត្តដូចព្រហ្ម សាកសមរម្យពុំអាចផ្ទៀបប្រៀបឧបមា
ព្រះសម្តែងថ្លែងរៀបរាប់គាប់អស្ចារ្យ បួនប្រការប្រាកដពិតចិត្តម៉ែឪ ។
ចិត្តមេត្តាថ្លាពេលពោរដោរពេញប្រាណ តែងរាប់អានបាននៃបនិត្យគិតតម្រូវ
ចង់ឲ្យកូនសូន្យពីគ្រោះរស់ត្រង់ផ្លូវ គ្មានសត្រូវសូវឲ្យសុខមុខប្រពៃ ។
ករុណាអាសូរបុត្រផុតលើសជន តែងគយគន់ធ្ងន់ក្នុងការអាណិតក្រៃ
ពេលឃើញកូនសូន្យពីធនស៊ុនស្ទើរក្បែ ក្នុងដួងចៃលៃពិនិត្យគិតគ្រប់គ្នា ។
មុទិតាប្រាកដណាស់ច្បាស់ជាគុណ តែងទោរទន់ជន់លើអ្នកជាប់ពិតជា
សប្បាយចិត្តដ្បិតឃើញបុត្រផុតវេរា បានសុខជារៀវចាកគ្រោះរស់សប្បាយ ។
ឧបេក្ខាការពិនិត្យគិតគ្រប់សព្វ មិនចេះស្អប់កប់ក្នុងចិត្តឥតក្លែងក្លាយ
ស្រលាញ់ស្មើដើរយ៉ាងត្រង់ផ្ទង់ចិត្តកាយ ឪពុកម្តាយក្លាយជាព្រហ្មធំជាងគេ ។
ជនគ្រប់គ្នាជាបណ្ឌិតគិតស្រេចហើយ មិនកន្តើយឡើយណាអ្នកជាក់រិះរេ
បម្រើព្រហ្មពុំមានស្រាកផ្អាកទំនេរ ពាលនោះទេរេគំនិតគិតមិច្ឆា ។
ប្រសិនអ្នកជាក់ជាមនុស្សទ្រុស្តនឹងព្រហ្ម នឹងត្រូវយំពុំមានស្បើយល្ហើយកាយា
រងវេទនាជាប្រាកដអត់សុខា ទើបស្រវាការពិនិត្យគិតស្តាយក្រោយ ។
អ្នកប្រសិនមិនជាមនុស្សទ្រុស្តនឹងព្រហ្ម បានសុខុមធំពេកពិតដ្បិតផលឲ្យ
ម៉ែនិងពុកទុកជាធំកុំបណ្តោយ អ្នកនឹងសោយដោយសារតែថៃព្រហ្មា ។

និពន្ធដោយ **ភិក្ខុ វិសេសោ វ៉ា ប៉ាវី**

(ក្នុងឱកាសបុណ្យរំលឹកគុណគ្រូវត្តសុណ្ណបទុម ព.ស.២៥៥៨)

ព្រះរាហុលដ៏មានអាយុពោលថា

នាហំ អតិណ្ហសំវាសា អវជានាមិ បណ្ឌិតំ

ឱក្កាធារោ មនុស្សានំ និច្ចំ អបចិតោ មយា ។

ខ្ញុំព្រះអង្គមិនមើលងាយអ្នកប្រាជ្ញព្រោះតែនៅរួមគ្នារឿយៗទេ

បុគ្គលអ្នកទ្រោលគប់ភ្លើងបំភ្លឺដល់ពួកមនុស្ស

ខ្ញុំព្រះអង្គកោតក្រែងជានិច្ច ។